ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ឧត្តមសេនីយ៍ឯក ចន សាន់ជីសុន អតីតមេបញ្ជាការកងកម្លាំងអង្គការសហប្រជាជាតិ របស់អាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ នៅអន្លង់វែង

◆ កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ និង អភិបាលស្រុកជាំក្សាន្ត លើគម្រោងសុខភាព និងប្រវត្តិសាស្ត្រ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៩ ខែឧសភា ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៩ ខែឧសភា ឆ្នាំ ២០២២

## មាតិកា

### សំបុត្រ


- ឧត្ដមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំងអន្ដរការសហប្រជាជាតិ ..១


### ផ្នែកឯកសារ


- ទូត រ៉ែត ៖ ប្រធានក្រុមផ្សំជីធម្មជាតិ ........ ៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ២០ ឧសភា ២០២២ ប្រជាជនឃុំតាភេមទទួលបានសំណង់និម្មិតរូប និងការអប់រំ............ ៨
- ការប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ...១១
- ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ................ ១៥
- គរុសិស្ស២៧ នាក់មកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ..................... ២០
- ទស្សនកិច្ចរបស់និស្សិតសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច.......២៣
- កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយមេបញ្ជាការតំបន់ប្រតិបត្តិការ......២៥
- ឈឹម ឡុក៖ កងចល័តនៅក្នុងរបប....... ២៨
- ញឹម លាម ៖ រឿងរ៉ាវជីវិត................. ៣១
- ពុធ សារឿន ៖ កងចល័តនៅក្នុងរបប ....៣៣


### វេទិកាប្រវត្តិសាស្ត្រគ្រួសារ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)


- នៅឃុំមហាលាភ ស្រុកកោះសូទិន .......៣៥
- នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ........... ៤០




អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម នៅគុកសន្ទ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាសាធារណៈ

### វេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)


- និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅខេត្តព្រៃវែង........................... ៤៩
- ចូលរួមដោយសិស្សវិទ្យាល័យសម្ដេចតេជោហ៊ុន សែន បឹងកុក............................៥៤


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- «ទួលពិឃាដ» (ត) ........................ ៥៧



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** លី សុខឃាង, ដារ៉ារដ្ឋ មេត្តា, ផេង ពង្សរ៉ាស៊ី, ស៊ាង ចិន្ដា, គាត ស្រីឡែន, ទូច វណ្ណេត, សោម ប៊ុនថន, សូ ហាន់, ទូច វណ្ណេត, អេង វណ្ណីកា, មេក វិន, ហ៊ាន ពិសី, សួត វិចិត្រ និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន

## អតីតមេបញ្ជាការកងកម្លាំងអង្គការសហប្រជាជាតិ របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ នៅអន្លង់វែង

លី សុខឃាង



ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំង របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ និងភរិយាអមដំណើរដោយបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើទស្សនកិច្ចនៅសារមន្ទីរផ្ទះតាម៉ុក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបរាប់ពីស្តាំ៖ ឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង, ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន និងភរិយា និង បណ្ឌិត លី សុខឃាង ថតរូបជុំគ្នា បន្ទាប់ពីទស្សនកិច្ចអតីតផ្ទះប្រជុំរបស់តាម៉ុកនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នគឺជាទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២២ ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំងរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិបនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ បានធ្វើទស្សនកិច្ចពិសេសមួយទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដោយសារមានការគាំទ្រជាចម្បងពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានផ្តោតការងាររបស់ខ្លួនទៅលើការអប់រំអំពីអំពើប្រល័យពូជសាសន៍ដល់យុវជន។ ការអប់រំអំពីអំពើប្រល័យពូជសាសន៍គឺជាប្រធានបទដ៏លំបាកមួយ ជាពិសេសនៅអន្លង់វែង ដោយសារតែប្រវត្តិរឿងរ៉ាវដ៏ស្មុគ្រស្មាញនៅតាមគ្រួសារនីមួយៗ ដែលបាននិងកំពុងបន្តនិយាយ និងពាំនាំទៅកាន់មនុស្សជំនាន់

ក្រោយៗទៀត។ អស់រយៈពេលជាង២០ឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បាននិងកំពុងធ្វើកិច្ចការនេះដោយមានការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឲ្យប្រាកដថា ប្រវត្តិសាស្ត្រនេះត្រូវបានបង្រៀនសម្រាប់មនុស្សគ្រប់ជំនាន់នាពេលអនាគត។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺ សុន បានទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ព្រមទាំងបានជួបជាមួយអតីតទាហានខ្មែរក្រហមដែរ។ ដំណើរទស្សនកិច្ចរបស់ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ទៅកាន់អន្លង់វែង ត្រូវបានធ្វើឡើងជាលើកដំបូងបង្អស់ ចាប់តាំងពីការដួលរលំតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម កាលពីជាង២០ឆ្នាំមុន។ លោកឧត្តមសេនីយ៍ឯក ក៏ត្រូវបានអមដំណើរដោយភរិយារបស់លោក ព្រមទាំងលោកឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង ដែរ។

ដំណើរទស្សនកិច្ចបានចាប់ផ្តើមដោយមានការបង្ហាញពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំក៏បានរៀបរាប់ប្រាប់អំពីសកម្មភាពការងារផ្សេងៗរបស់មជ្ឈមណ្ឌល ដោយរាប់ទាំងកម្មវិធីអប់រំស្តីពីសន្តិភាពនិងសិទ្ធិមនុស្ស ដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានផ្តល់ជូនដល់កូនចៅរបស់អតីតសមាជិកខ្មែរក្រហម។ អន្លង់វែងមានប្រជាជនចំនួនប្រមាណជិត៦ម៉ឺននាក់ ដែល៨០ភាគរយនៃប្រជាជននៅទីនោះគឺជាអតីតសមាជិកខ្មែរក្រហម។ អន្លង់វែងបានធ្វើសមាហរណកម្មមកក្នុងសង្គមជាតិវិញនៅក្នុងឆ្នាំ១៩៩៨ ដែលមានរយៈពេល៥ឆ្នាំ ក្រោយពីអ៊ុនតាក់បានបញ្ចប់បេសកកម្មរបស់ខ្លួន។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ក៏បានផ្តោតការចាប់អារម្មណ៍លើផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលដែរ ដែលមានបង្ហាញរូបភាពនិងព័ត៌មានស្តីពីដំណើរមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនកម្ពុជាកាលពីសម័យអ៊ុនតាក់។ នៅក្រោមការគ្រប់គ្រងរបស់អ៊ុនតាក់ ជនភៀសខ្លួនបានវិលត្រឡប់មកកាន់ភូមិឋានរបស់ខ្លួនវិញតាមរទេះភ្លើង ដែលបានដាក់តាំងបង្ហាញនៅលើពិព័រណ៍មួយផ្ទាំង។ ចំណែកឯ



លោក វង់ សារ៉ន ពេលបំពេញការងារជាមួយកងកម្លាំងរបស់អ៊ុនតាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន និងភរិយា ជួបជាមួយលោក វង់ សារ៉ែន (រូបទី២ រាប់ពីស្ដាំ) ដែលជាអតីតទាហានខ្មែរក្រហម និងធ្លាប់ជាសហការីរបស់លោកនៅក្នុងសម័យអ៊ុនតាក់ នៅឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន អតីតមេបញ្ជាការកងកម្លាំង របស់អាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣ ទស្សនកិច្ចទីតាំងបូជាសពប៉ុល ពត នៅលើខ្នងភ្នំដងរែក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិព័រណ៍មួយទៀតបានពណ៌នាអំពីរូបភាព ដែលបានសរសេរថា៖ «Benny Widyono ឈរក្នុងចំណោមកងទ័ពខ្មែរក្រហមនៅប៉ៃលិនដែលជាទីស្នាក់ការកណ្ដាលរបស់ខ្មែរក្រហម នៅជាប់ព្រំដែនថៃ ជាតំបន់មួយដែលមមាញឹកជាមួយនឹងការជួញដូរត្បូងមានតម្លៃ និងព្រៃឈើជាមួយឈ្មួញជនជាតិថៃ។ ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ បានអញ្ជើញ Benny Widyono អមដំណើរជាមួយទ្រង់ ដើម្បីត្រួតពិនិត្យតំបន់ខ្មែរក្រហម នៅខែកញ្ញា ឆ្នាំ១៩៩២»។ លោកឧត្តមសេនីយ៍ឯក បានចាប់អារម្មណ៍ពិព័រណ៍ទាំងនេះ ដោយសារតែបានរំឭកឡើងវិញពីសម័យកាលដែលលោកឧត្តមសេនីយ៍ឯក ដឹកនាំកងកម្លាំងអ៊ុនតាក់។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន បានធ្វើដំណើរទៅកាន់ទីតាំងប្រវត្តិសាស្ត្រមួយចំនួនដែរ ដោយរាប់បញ្ចូល ទាំងអតីតផ្ទះប្រជុំរបស់តាម៉ុក និងទីតាំងបូជាសពប៉ុល ពត។ អតីតផ្ទះប្រជុំរបស់តាម៉ុក គឺជាគោលដៅទីមួយ ដែលបច្ចុប្បន្នគឺជាទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ មជ្ឈមណ្ឌលនេះបានប្រែក្លាយអតីតផ្ទះប្រជុំនេះឲ្យទៅថ្នាក់រៀនសម្រាប់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។ ដោយមានទីតាំងនៅលើខ្នងភ្នំដងរែក ថ្នាក់រៀននេះគាំទ្រដល់ការអប់រំពីអំពើប្រល័យពូជសាសន៍ដល់សិស្ស និងនិស្សិតប្រមាណជា៥០០នាក់ នៅក្នុងប្រទេសកម្ពុជា ព្រមទាំងនិស្សិតបរទេសដែរ។ កន្លងមក និស្សិតបរទេសប្រមាណជាជាង១០នាក់ នៃសកលវិទ្យាល័យម៉ូណាសរបស់ប្រទេសអូស្ត្រាលី បានមកបំពេញបេសកកម្មសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រ ការផ្សះផ្សា និងជំងឺផ្លូវចិត្ត ព្រមទាំងព័ត៌មានស្ដីអំពីបរិស្ថាន និងធនធានរ៉ែនៅក្នុងមូលដ្ឋានទៀតផង។ និស្សិតទាំងអស់នោះក៏បានស្ដាប់ពុការនិយាយរៀបរាប់ផ្ទាល់ពីអតីតសមាជិកខ្មែរក្រហម និងបានពិភាក្សា ព្រមទាំងរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រវត្តិសាស្ត្រនៅក្នុងតំបន់។

គោលដៅទី២នៃដំណើរទស្សនកិច្ចគឺជាទីតាំងបូជាសពប៉ុល ពត អតីតមេដឹកនាំខ្មែរក្រហម និងជាអតីតនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ដែលបានស្លាប់នៅក្នុង ខែមេសា ឆ្នាំ១៩៩៨។ ខ្ញុំក៏បានជម្រាបត្រួសៗជូនលោកឧត្តមសេនីយ៍ អំពីទីតាំងប្រវត្តិសាស្ត្រ

និងរឿងរ៉ាវមួយចំនួនរហូតដល់ការស្លាប់របស់ ប៉ុល ពត។ បន្ទាប់ពីការដួលរលំជាផ្លូវការរបស់របបខ្មែរក្រហម នៅក្នុងឆ្នាំ១៩៧៩ ប៉ុល ពត និងសមាជិកទាំងឡាយ បានបន្តការតស៊ូប្រដាប់អាវុធនៅតាមបណ្តោយព្រំដែនកម្ពុជាថៃ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។

នៅដើមទសវត្សន៍ឆ្នាំ១៩៩០ ចលនារបស់ ប៉ុល ពត បានទទួលរងនូវភាពឯកោជាលំដាប់ ហើយការគាំទ្រពីអន្តរជាតិចាប់ផ្តើមកាត់ផ្តាច់ ដែលស្របទៅនឹងសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១។ ប៉ុល ពត បានបន្តដកថយពីតំបន់តស៊ូនានា មកកាន់តំបន់អន្លង់វែងនៅឆ្នាំ១៩៩៣ ឬ ១៩៩៤។ ប៉ុល ពត បានរួមកម្លាំងជាមួយ ឈិត ជឿន ហៅ តាម៉ុក ដែលជាមេបញ្ជាការនៅតំបន់អន្លង់វែង។ នៅទីបំផុត មេដឹកនាំទាំងពីរបានវាយប្រយុទ្ធគ្នា ដែលកាន់តែធ្វើឲ្យចុះខ្សោយដល់ចលនាខ្មែរក្រហម។ ក្រោយមក ប៉ុល ពត ត្រូវបាននាំយកទៅកាត់ទោសនៅក្នុងតុលាការប្រជាជន និងដាក់ឲ្យនៅឃុំខ្លួនក្នុងផ្ទះរហូតដល់គាត់ស្លាប់។

ឧត្តមសេនីយ៍ឯក ចន សាន់ដឺសុន ក៏បានជួបជាមួយ វង់ សារ៉ន ដែលជាអតីតទាហានខ្មែរក្រហម និងធ្លាប់ជាសហការីរបស់លោកនៅក្នុងសម័យអ៊ុនតាក់។ ចលនាខ្មែរក្រហមនៅតែជាបញ្ហា បន្ទាប់ពីសម័យអ៊ុនតាក់។ ប្រទេសកម្ពុជាបានចំណាយពេលប្រាំឆ្នាំក្រោយមកទៀតដើម្បីបញ្ចប់នូវរាល់កម្លាំងសេសសល់របស់ចលនាខ្មែរក្រហម។

អន្លង់វែងបានក្លាយជាតំបន់តស៊ូចុងក្រោយនៃចលនានេះដែលបានធ្វើសមាហរណកម្មចូលមកក្នុងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ១៩៩៨ នៅក្រោមគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងឱកាសនោះដែរ វង់ សារ៉ន ក៏បានសម្តែងនូវសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានជួបជាមួយលោកឧត្តមនីយ៍ឯក ចន សាន់ដឺសុន នៅអន្លង់វែង។ អ្នកទាំងពីរបាននិយាយគ្នាប្រកបដោយភាពស្និទ្ធស្នាលរីករាយ ដោយរាប់ចាប់តាំងពីរយៈកាលដែលបានជួបគ្នា រហូតដល់គ្រាលំបាកដែលខ្មែរក្រហមធ្វើពហិការមិនអនុវត្តតាមកិច្ចព្រមព្រៀង។ អ្នកទាំងពីរបានអង្គុយជជែក និងចែករំលែកសាច់រឿងនៃទំព័រប្រវត្តិសាស្ត្រកម្ពុជា និងប្រវត្តិសាស្ត្ររបស់អាស៊ីអាគ្នេយ៍។



រូបឈរពាក់មួកនៅកណ្តាល៖ លោក វង់ សារ៉ន ជាមួយកងកម្លាំងរបស់អ៊ុនតាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបរាប់ពីស្តាំ៖ ឯកអគ្គរាជទូតអូស្ត្រាលី ប៉ាប្លូ កាង, បណ្ឌិត លី សុខឃាង, ឧត្តមសេនីយ៍ឯក ចន សាន់ និង លោក វង់ សារ៉ន នៅឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទួត រ៉ែត ៖ ប្រធានក្រុមផ្សព្វផ្សាយជីវិតធម្មជាតិ របស់តំបន់៥ ភូមិភាគពាយ័ព្យ

ជាវ៉ារដ្ឋ មេត្តា



កងចល័តនៅក្នុងរបបខ្មែរក្រហមកំពុងប្រមូលចំបើង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទួត រ៉ែត គឺជាជនជាតិខ្មែរ មានអាយុ ៨២ឆ្នាំ(នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំកើតនៅភូមិពាមបួន ឃុំវិលទ្រុង ស្រុកស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម។ នៅពេលខ្ញុំមានអាយុ៦ឆ្នាំ ខ្ញុំមករៀននៅវត្តនួនមណីយរាម ហៅ វត្តថាន់ នៅក្រុងភ្នំពេញ។ នៅឆ្នាំ១៩៥៧ ខ្ញុំប្រឡងចូលរៀននៅអនុវិទ្យាល័យព្រះយុគន្ធរ ថ្នាក់ទី៦ទំនើប ហើយនៅឆ្នាំ១៩៦០ ខ្ញុំរៀនដល់ថ្នាក់ទី៤ទំនើប។ នៅក្នុងឆ្នាំ១៩៦០ ខ្ញុំបានជួប ម៉ែន ជុន។ ម៉ែន ជុន អប់រំខ្ញុំឲ្យមានការស្រឡាញ់ចូលចិត្តរស់នៅតាមរបៀបរបបលោកសេរី មានសិទ្ធិនិងសេរីភាពធ្វើអ្វីបានគ្រប់យ៉ាង មិនមែនដូចរបបកុម្មុយនីស្ត។ ថ្ងៃមួយ ម៉ែន ជុន នាំខ្ញុំទៅជួបគ្រូបង្រៀនខាងកីឡាករម្នាក់ឈ្មោះ សូជល បង្ហាត់នៅសាលាយុគន្ធរដើម្បីឲ្យខ្ញុំចូលរួមអង្គការ សេ-អ៊ី-អា។ នៅពេលខ្ញុំទៅដល់ទីនោះខ្ញុំបានជួប ចាប ប៉ាង គឺជាសិស្សថ្នាក់ទី៣សាលាយុគន្ធរដែរ។ ដំបូង សូជល ប្រកាសប្រាប់អ្នកចូលរួមឲ្យគោរពទង់ជាតិអាមេរិកដែលមានផ្កាយជាង៤០ និងទង់អង្គការ សេ-អ៊ី-អា។ បន្ទាប់មកទៀតមានការប្ដេជ្ញាចិត្តស្មោះត្រង់នឹងអង្គការ បម្រើអង្គការ សេ-អ៊ី-អា។ សូជល បានប្រគល់ភារកិច្ចឲ្យ

ខ្ញុំគឺ១) ឃោសនាប្រឆាំងជាមួយនឹងកុម្មុយនីស្ត ២) អប់រំដើម្បីប្រមូលកម្លាំងថែមទៀត។ ជារៀងរាល់មួយអាទិត្យម្តង ខ្ញុំត្រូវរាយការណ៍អំពីសកម្មភាពដែលបានបំពេញជាមួយ ចាប ប៉ាង ទៅឲ្យបង សូផល។

នៅក្នុងឆ្នាំ១៩៦១ សូផល បាត់ខ្លួនមិនដឹងទៅណា ហើយនៅពេលដែលខ្ញុំទៅធ្វើការនៅមន្ទីរពេទ្យឈ្មោះ សុនម៉ម, ម៉ែនដុន ក៏ដឹកនាំខ្ញុំបន្ត។ នៅក្នុងឆ្នាំដដែល ខ្ញុំអប់រំបានកម្លាំងពីរនាក់ឲ្យមានជំនឿជឿជាក់លើរបបសេរី មានឈ្មោះ ដារី គឺជាអតីតសិស្សថ្នាក់ទី៣ នៅសាលាយុគន្ធរ និង សូក្វាង គឺជាអតីតសិស្សថ្នាក់ទី៤នៅសាលាយុគន្ធរ។

នៅក្នុងឆ្នាំ១៩៦២ ខ្ញុំកសាងកម្លាំងបានចំនួនពីរនាក់ទៀតឈ្មោះ លិម ហួតប្រាជ គឺជាគ្រូបង្រៀននៅសាលាព្រែកប្ញស្សី និង ទុំ សុត គឺជាគ្រូបង្រៀននៅសាលាព្រែកប្ញស្សី ដោយបានចាត់តាំងពីរនាក់នេះ គឺជាអ្នកតាមដានសកម្មភាពខ្មែរក្រហមនៅសាលាព្រែកប្ញស្សី។ នៅក្នុងឆ្នាំ១៩៦៣ ខ្ញុំកសាងកម្លាំងបានចំនួនពីរនាក់បន្ថែមទៀត រួមមាន៖ ហួត លី គឺជាគ្រូពេទ្យនៅមណ្ឌលសុខភាពតាខ្មៅ និង សេង គឺជាគ្រូបង្រៀននៅសាលាវត្តក្រពើហា។ ខ្ញុំអប់រំពួកគេទាំងពីរនាក់ឲ្យចូលចិត្តរស់នៅសប្បាយ សេរី មានចិត្តចង់ប្រមូលកម្លាំងប្រឆាំងជាមួយរបបកុម្មុយនីស្ត។ ថ្ងៃមួយខ្ញុំបាននាំទាំងពីរនាក់ទៅជួប ម៉ែន ដុន ដើម្បីទទួលស្គាល់ និងបញ្ចូលជា សេ-អុី-អា។ ក្រោយពីតែងតាំងហើយ ម៉ែនដុនចាត់តាំង ហួតលីឲ្យធ្វើសកម្មភាពឃោសនា និងប្រមូលកម្លាំងប្រឆាំងនឹងសកម្មភាពរបស់ខ្មែរក្រហមនៅមណ្ឌលសុខភាពតាខ្មៅ ហើយ សេង គឺធ្វើសកម្មភាពនៅសាលាដែលខ្លួនបង្រៀន។

នៅឆ្នាំ១៩៦៤ ម៉ែនដុនបាននាំ អោម បូរី គឺជាសាស្ត្រាចារ្យនៅសាលាយុគន្ធរ ទៅជួបខ្ញុំនៅតាខ្មៅ។ នៅពេលជួបគ្នា ម៉ែន ដុន និយាយបញ្ជាក់ប្រាប់ខ្ញុំថា គាត់ត្រូវទទួលភារកិច្ចចូលទៅក្នុងតំបន់រំដោះចំណែកការងារអ្វីផ្សេងទៀតត្រូវទាក់ទងជាមួយ អោម បូរី។ នៅឆ្នាំ១៩៦៨ ខ្ញុំបានផ្តល់ព័ត៌មានទៅឈ្មោះ អោម បូរី ឲ្យបានដឹងថា នៅវិទ្យាល័យតាខ្មៅមានកូនសិស្សបះបោរប្រឆាំងជាមួយចាងហ្វាងសាលា។ ក្រោយមក អោម បូរី ទៅពិនិត្យមើលហើយរាយការណ៍ទៅក្រុមនគរបាលនៅតាខ្មៅទៅចាប់កូនសិស្សមួយចំនួនដែលជាអ្នកដឹកនាំការបះបោរយកទៅឃុំឃាំង។

នៅឆ្នាំ១៩៦៩ ខ្ញុំ និង អោម បូរី ទៅប្រជុំផ្ទះស័ក្តិប្រាំម្នាក់ឈ្មោះ ចំរើន សុិន មានទីតាំងនៅបឹងព្រលិត។ នៅពេលទៅដល់ អោម បូរី ណែនាំខ្ញុំ ដែលជាសមាជិក សេ-អុី-អា នៅតាខ្មៅទៅកាន់ ចំរើន សុិន។ អោម បូរី បន្តថា «សព្វថ្ងៃនេះកម្លាំងខ្មែរក្រហមនៅ ខេត្ត ក្រុងមានការផុសផុល ខ្ញុំមកនេះដើម្បីចង់ចូលទៅជួបលោក លន់ នល់» ។ ចំរើន សុិនបានតបថា «ខ្ញុំមានយោបល់ដូចគ្នាដែរ។ សូមចាំបន្តិច កាលណាខ្ញុំទទួលបានដំណឹងយ៉ាងណាខ្ញុំនឹងប្រាប់វិញ»។ នៅពេលសកម្មភាពរបស់ខ្មែរក្រហមកាន់តែរីកដុះដាលស្ទើរគ្រប់ទិស ខ្ញុំនឹងសមាជិក សេ-អុី-អា បែកមុខសញ្ញាចុះតាមភូមិដែលអាចធ្វើសកម្មភាពបាន ដោយអប់រំប្រជាជនជួយរួមគ្នាប្រឆាំងទប់ទល់ជាមួយសកម្មភាពរបស់ខ្មែរក្រហម។

នៅចុងឆ្នាំ១៩៦៩ អោម បូរី ប្រាប់ខ្ញុំឲ្យប្រមូលសមាជិក សេ-អុី-អា នៅតាខ្មៅឲ្យចូលរួមប្រជុំនៅផ្ទះរបស់ លន់ នល់។ នៅពេលដែលក្រុមរបស់ខ្ញុំទៅដល់ អោម បូរី បាននាំខ្ញុំទៅអង្គុយនៅកន្លែងប្រជុំ។ អ្នកដែលបានចូលរួមប្រជុំនៅពេលនោះមានឈ្មោះ១) សូស្តែន, ២) ចំរើន សុិន, ដៀន ដែល អតីតនាយទាហាន, ឈិម ឈួនគឺជាអតីតនាយទាហាន, លន់នល់ អតីតប្រធានាធិបតី, ឡុង បូរ៉េត គឺជាអតីតនាយករដ្ឋមន្ត្រីទី១ និងអាមេរិកកាំង២នាក់ ព្រមទាំងទាហាន និងសុីវិលមួយចំនួនដែលខ្ញុំមិនបានស្គាល់ឈ្មោះ។ នៅពេលប្រជុំនោះលោក លន់ នល់ លើកឡើងពីបញ្ហាចំនួនពីរគឺ៖ ១) បញ្ហាទប់ទល់ជាមួយសកម្មភាពរបស់ខ្មែរក្រហម, ២) ការត្រៀមធ្វើរដ្ឋប្រហារ។ នៅក្នុងការពិភាក្សាលោក សូស្តែន មានយោបល់ថា ក្នុងបញ្ហាទប់ទល់ចំពោះសកម្មភាពរបស់ខ្មែរក្រហមគឺត្រូវតែបន្ថែមចំនួនទាហានឲ្យបានច្រើនទៀតនៅកន្លែងណាដែលមានទ័ពខ្មែរក្រហមខ្លាំង។ ចំណែកបញ្ហាធ្វើរដ្ឋប្រហារគឺត្រូវតែធ្វើ។ បន្ទាប់មកលោក ឡុង បូរ៉េត

បានឲ្យយោបល់ថា បញ្ហាទី១ លោកយល់ស្របជាមួយគំនិតរបស់លោក សូស្តែន ប៉ុន្តែបញ្ហាទី២គួរតែលើកឡើងទៅពិនិត្យឲ្យបានល្អិតល្អន់បន្តិចៗ ក្រោយពីការពិភាក្សាគ្នាយ៉ាងយូរ អង្គប្រជុំបានសម្រេច ១) ត្រូវបន្ថែមចំនួនទាហានដែលទ័ពខ្មែរក្រហមរស់នៅ, ២) បញ្ហាធ្វើរដ្ឋប្រហារត្រូវលើកទៅពិនិត្យថ្ងៃក្រោយៗ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំនិងក្រុមសេ-អ៊ី-អា នៅតាខ្មៅបានចុះតាមភូមិនៅជិតៗផ្សារតាខ្មៅ ដើម្បីធ្វើសកម្មភាពអប់រំអ្នកស្រុកឲ្យមានជំនឿហើយជួយគាំទ្ររបបថ្មីៗ

នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំជួបជាមួយឈ្មោះ អោម បូរី នៅចំណតរទេះភ្លើងស៊ីសូផុន នៅពេលដែលអង្គការជម្លៀសគាត់ចេញពីភ្នំពេញៗ ពេលខ្ញុំឃើញ អោម បូរី ខ្ញុំទៅរាយការណ៍ឲ្យ ម៉ែន ផុន ហៅ ហឹង្ស គឺជាលេខាតំបន់៥ភូមិភាគពាយ័ព្យៗ នៅពេល ហឹង្ស ដឹងព័ត៌មាននេះ គាត់បានឲ្យ អោម បូរី ទៅរស់នៅស្រុកព្រះនេត្រព្រះ ហើយចាប់តាំងពីពេលនោះមកខ្ញុំមិនដែលបានជួប ជាមួយឈ្មោះ អោម បូរី ទៀតទេៗ ចំណែក សេ-អ៊ី-អា ចាស់ដែលនៅតាខ្មៅ ខ្ញុំខិតខំស្រាវជ្រាវស្វែងរក ប៉ុន្តែខ្ញុំមិនដែលបានជួបសូម្បីតែម្នាក់ៗ ថ្ងៃមួយ សាវ៉ាត គឺជាប្រធានពាណិជ្ជកម្មតំបន់៤ ប្រាប់ខ្ញុំថា ហឹង្ស សម្រេចដកខ្ញុំឲ្យទៅធ្វើការនៅសហជីពកប្បាសជាមួយឈ្មោះ ឡេង មានតួនាទីប្រធានសហជីពកប្បាសតំបន់៥ៗ សាវ៉ាត បញ្ជាក់ថា ទៅធ្វើការនៅកន្លែងនោះស្រួល ហើយមិនចាំបាច់ទៅណាទៀតព្រោះមានសុទ្ធតែគ្នាយើងៗ

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំនិងសមាជិក សេ-អ៊ី-អា ចំនួន១០នាក់បានបំផុសប្រជាជនមិនឲ្យសប្បាយចិត្តចំពោះការធ្វើបដិវត្តន៍សង្គមនិយមដែលអង្គការលើកឡើងៗ យើងបំផុសឲ្យមានការរអាក់រអួលចំពោះការរៀបចំបាយរួមនៅតាមចម្ការកប្បាសៗ ថ្ងៃមួយ ខ្ញុំនិងសមាជិក១០នាក់ទៀតបាននាំគ្នាប្រជុំនៅផ្ទះ ឡេង ៗ យើងបានប្រជុំលើកអំពីផែនការដាំកប្បាស ១២០០ ហិកតា និងផែនការបំផ្លាញផលកប្បាសៗ យូរៗម្តងអង្គប្រជុំសម្រេចឲ្យរកគ្រាប់ពោតមកដាំលាយជាមួយកប្បាសដើម្បីឲ្យដើមកប្បាសខូចគុណភាព, ដាំគ្រាប់កប្បាសដាក់ឲ្យតិចដើម្បីឲ្យឃើញចំនួនដីដាំបានច្រើន ប៉ុន្តែទទួលបានទិន្នផលតិចៗ នៅពេលកប្បាសទទួលបានផល យើងបានបំផ្លាញកប្បាសទាំង ៤ចម្ការគឺ ចម្ការដីឡូ ២, ចម្ការភ្នំបាក់៣, ចម្ការកង៉ា ៤ និងចម្ការពង្រៃ ចាប់តាំងពីការដាំរហូតដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំៗ

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00៦១៣ ។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ទួត វ៉ែត ពិតប្រាកដយ៉ាងណានោះទេ?**



កងចល័តកំពុងភ្ជួរស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ២០ ឧសភា ២០២២ ប្រជាជនឃុំតាភេម
## ទទួលបានសំណង់និម្មិតរូប និងការអប់រំក្រៅផ្លូវការពីរបបខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី



អ្នកចូលរួមកម្មវិធីសម្ពោធចេតិយ៍ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ទទួលបានសំណង់ចេតីយ៍សមូហភាពមួយ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំមួយ សាងសង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមជំនួយទ្រទ្រង់ពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ សំណង់ទាំងពីរនេះ បានសាងសង់រួចរាល់នៅពាក់កណ្ដាលខែមេសា ឆ្នាំ២០២២ នៅលើទីតាំងដី «ព្រៃធាតុដើមឈើទាលកោង» ស្ថិតនៅភូមិកំពង់ស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ តាមការស្នើសុំរបស់មេឃុំតាភេមឈ្មោះ ស៊ុំ ផាសឹត កាលពីចុងឆ្នាំ២០២១ កន្លងមក។

«ព្រៃធាតុដើមឈើទាលកោង» គឺជាដីសាធារណៈមួយកន្លែងដែលប្រើប្រាស់ធ្វើជាកន្លែងកប់អដ្ឋិធាតុអ្នកភូមិតាំងពីមុនរបបសង្គមរាស្ត្រនិយមមកម្ល៉េះ។ ខណៈពេលដែលប្រទេសជាតិស្ថិតក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ និងរបបខ្មែរក្រហម បរិវេណដីព្រៃធាតុដើមឈើទាលកោង គឺជាដីព្រៃគ្មានមនុស្សរស់នៅ ហើយមានសាកសពមួយចំនួនដែលស្លាប់ដោយសារការប្រយុទ្ធគ្នារវាងកងទ័ពលន់ នល់ និងក្រុមខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៣ ក៏ត្រូវសែងយកមកកប់នៅទីនេះដែរ។ ក្រោយឆ្នាំ១៩៧៩ «ព្រៃទួលធាតុដើមឈើទាលកោង» លែងមានម្ចាស់គ្រប់គ្រងទៀតហើយ ហើយអ្នកភូមិបានកំណត់យកទីតាំងនេះធ្វើជាកន្លែងកប់អដ្ឋិធាតុអ្នកស្លាប់ នៅក្នុងឃុំតាភេម ទាំងមូលរហូតមកដល់បច្ចុប្បន្ន។

សព្វថ្ងៃនេះ «ទីតាំងព្រៃធាតុដើមឈើទាលកោង» មានទំហំដីជិតមួយហិកតា ខណៈពីមុនមក ទីតាំងនេះ



លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ឡើងថ្លែងនៅក្នុងកម្មវិធីសម្ពោធចេតិយ៍ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កញ្ញា វង្ស សុជាតា តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ឡើងថ្លែងនៅក្នុងកម្មវិធីសម្ពោធចេតិយ៍ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកមេឃុំតាភេម ឡើងថ្លែងនៅក្នុងកម្មវិធីសម្ពោធចេតិយ៍ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានត្រឹមតែជាង១០ម៉ែត្របួនជ្រុងប៉ុណ្ណោះ។ តាមប្រសាសន៍រៀបរាប់របស់ អាចារ្យ ឃួន គឹមម៉ន ដែលអះអាងថាគាត់បានបរិច្ចាកដីរបស់គាត់ចូលជាចំណែកដីព្រៃធាតុនេះបានប្រាប់ថា មូលហេតុដែលធ្វើឲ្យដីព្រៃធាតុដើមឈើទាលមានទំហំធំជាងមុន ព្រោះមានអ្នកបរិច្ចាកដីផ្ទាល់ខ្លួនចំនួនបីនាក់គឺ យាយ ហៀង, តាឈើវ និងខ្លួនគាត់ផ្ទាល់។

នៅវេលាព្រឹកថ្ងៃទី២០ ខែឧសភា ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ និងប្រគល់សំណង់ចេតិយ៍ ព្រមទាំងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យអាជ្ញាធរមូលដ្ឋាន និងប្រជាជនរស់នៅក្នុងឃុំតាភេម បានចាប់ផ្តើមឡើង ដោយមានការចូលរួមពីមេឃុំតាភេមលោក ស៊ុំ ផាសឺត មេភូមិគ្រប់ភូមិ អ្នករស់រានមានជីវិតចំនួន ៣០នាក់ សិស្សានុសិស្សថ្នាក់វិទ្យាល័យចំនួន១០នាក់ តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន ៦នាក់។ មេឃុំតាភេមបានសម្តែងក្តីសោមនស្សរីករាយចំពោះសមិទ្ធិផលថ្មីនេះ ព្រមទាំងអានសុន្ទរកថាស្តីអំពីបទពិសោធន៍របស់គាត់ និងប្រជាជនឯទៀតដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ លោកមេឃុំ ក៏បានផ្តាំផ្ញើដល់អ្នករស់រានមានជីវិតទាំងអស់ដែលមានវត្តមាននៅក្នុងពិធី ក៏ដូចជាប្រាប់ទៅមេភូមិទាំងអស់ឲ្យជូនដំណឹងដល់អ្នករស់រានមានជីវិតក្នុងភូមិរៀងខ្លួនឲ្យនាំយកអដ្ឋិធាតុសាច់ញាតិរបស់ខ្លួនដែលស្លាប់ក្នុងរបបខ្មែរក្រហម មកដាក់នៅក្នុងចេតិយនេះ ចាប់ពីថ្ងៃសម្ពោធនេះតទៅ។ ចុងបញ្ចប់នៃសុន្ទរកថារបស់គាត់ លោកមេឃុំបានស្នើសុំឲ្យមានការសាងសង់រោងមួយមានទំហំទទឹង៥ម៉ែត្រ និងបណ្តោយ១០ម៉ែត្រ ដើម្បីទុកធ្វើជាកន្លែងប្រារព្ធធ្វើពិធីសាសនាផ្សេងៗ និងកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ដែលរៀបចំដោយសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នាពេលអនាគត។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា, តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ និងសិស្សានុសិស្សថតរូបជុំគ្នានៅពីមុខផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ថ្លែងពីដំណើរការនៃការសាងសង់ចេតិយ និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំ ព្រមទាំងបានគូសបញ្ជាក់ពីសារសំខាន់នៃការសាងសង់សំណង់នេះ ពន្យល់ពីអត្ថន័យនៃផ្ទាំងពាក្យស្លោក ការបង្កើតសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការអប់រំក្រៅផ្លូវការស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលគ្រោងនឹងរៀបចំឡើងនៅលើទីតាំង «ព្រៃធាតុ ដើមឈើទាលកោង» ចាប់ពីពេលនេះតទៅ។ លោកក៏បានស្នើសុំឲ្យអាជ្ញាធរមូលដ្ឋាន និងអ្នករស់រានមានជីវិតទាំងអស់ សហការក្នុងការចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម ដល់ក្មេងៗជំនាន់ក្រោយដែលត្រូវជាកូន ចៅ និងចៅទួតរបស់ខ្លួន។ នៅក្នុងឱកាសនេះដែរ រ៉ាស៊ី ក៏បានពន្យល់ត្រួសៗពីមូលហេតុដែលនាំឲ្យមានការជ្រើសរើសយកថ្ងៃ២០ ខែឧសភា ធ្វើជាពិធីរំឭកការចងចាំ នៅក្នុងប្រទេសកម្ពុជា។ ការពន្យល់នេះ គឺសំដៅទៅកាន់ក្មេងៗជំនាន់ក្រោយឲ្យគិតគូរឡើងវិញពីការយកចិត្តទុកដាក់ចំពោះការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីការចងចាំ និងការផ្សះផ្សា។

បន្ទាប់មក កញ្ញា វង្ស សុជាតា តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ បានថ្លែងពីទំនាក់ទំនងល្អរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ក្នុងការផ្តល់ការគាំទ្រទាំងស្មារតី និងថវិកាក្នុងការអភិវឌ្ឍការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងមូលដ្ឋាន។ មុននឹងបញ្ចប់កម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់សំណង់ចេតិយ និងផ្ទាំងពាក្យស្លោកនេះ លោកមេភូមិកំពង់ស្វាយឈ្មោះ សួសរ៉ា បានឡើងមានយោបល់ទៅកាន់អ្នកចូលរួម និងគណៈប្រតិភូទាំងអស់ថា អ្នកភូមិរបស់គាត់មានសំណាងជាងគេក្នុងការទទួលបានសំណង់ទាំងពីរនេះ ព្រោះថានេះជាលើកដំបូងបង្អស់ហើយដែលឃុំតាភេមទទួលបានសមិទ្ធផលរួមសម្រាប់អ្នកភូមិទាំងអស់ក្នុងឃុំ។ លោកបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដែលបានសាងសង់សំណង់ទាំងពីរនេះឡើង ហើយលេចត្រដែតនៅក្នុងភូមិកំពង់ស្វាយ។ ចុងបញ្ចប់ លោកបានប្តេជ្ញាថា លោកនិងកៀងគរកម្លាំងប្រជាជនក្នុងភូមិឲ្យចូលរួមថែរក្សាសំណង់នេះឲ្យស្ថិតនៅគង់វង្សរហូតតទៅ។ កម្មវិធីសម្ពោធបានបញ្ចប់នៅត្រឹមម៉ោង១០កន្លះ ជាមួយនឹងការថតរូបជុំគ្នាជាអនុស្សាវរីយ៍ និងការហូបនំបញ្ចុកជុំគ្នាបន្ទាប់ពីកម្មវិធី។

# ការប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល

## ជូនជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ក្នុងទិវាជាតិនៃការចងចាំ ថ្ងៃទី២០ ខែឧសភា នៅចេតិយ៍សម្រាប់សហគមន៍នៅខេត្តកំពង់ចាម

*ស៊ាង ចិន្តា*



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចូលរួមប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលនៅចេតិយ៍រំឭកសម្រាប់សហគមន៍ នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ គាំទ្រដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅចេតិយ៍សម្រាប់សហគមន៍ និងដើម្បីរំឭកដល់ការចងចាំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម។ ចេតិយ៍សម្រាប់សហគមន៍ មានទីតាំងស្ថិតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ដែលមានចម្ងាយប្រមាណ ១៥គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម។

ចេតិយ៍សម្រាប់សហគមន៍ ត្រូវបានកសាងជានិមិត្តរូបដើម្បីរំឭកការចងចាំជាសមូហភាពដល់ជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងជាវេទិកាផ្ទាល់សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅកម្រិតមូលដ្ឋានដើម្បីចែករំលែកបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម



ចេតិយ៍រំឭកសម្រាប់សហគមន៍ ស្ថិតនៅកណ្តាលវាលស្រែ ក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចូលរួមប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលនៅចេតិយ៍រំឭកសម្រាប់សហគមន៍ នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដល់ក្មេងជំនាន់ក្រោយ ក្នុងការឈ្វេងយល់រឿងរ៉ាវដែលបានកើតឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ក្នុងភូមិសាស្ត្រឃុំគគរត្រូវបានខ្មែរក្រហមរៀបចំធ្វើជា ទីតាំងធ្វើទារុណកម្មសួរចម្លើយ និងទីតាំងសម្លាប់ប្រជាជនចំនួន ៣កន្លែងដែលធ្វើឲ្យជនរងគ្រោះរាប់រាយ នាក់ស្លាប់បាត់បង់ជីវិត ។ ទីតាំងសម្លាប់ទី១) ការដ្ឋានវាលស្រែក្នុងភូមិចំការសាមសិប (ដែលជា ទីតាំងចេតិយ៍ សម្រាប់សហគមន៍សព្វថ្ងៃ)។ ប្រជាជនមូលដ្ឋានដែលប្រព្រឹត្តខុស និងប្រជាជនបញ្ញើ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅវាលស្រែ។ ទីតាំងទី២) ឡដុតថ្នាំជក់ដែលខ្មែរក្រហមប្រើប្រាស់សម្រាប់សម្លាប់ជនជាតិភាគតិចចាមដែលរស់នៅភូមិចំការសាមសិប និងភូមិកំពង់ក្របី។ ជនជាតិភាគតិចចាមជាច្រើនគ្រួសារត្រូវបានខ្មែរក្រហមដឹកយកទៅសម្លាប់ និងកប់នៅក្នុងឡថ្នាំជក់ស្ថិតនៅឆ្ងាយពីផ្ទះអ្នកភូមិ។ ទីតាំងសម្លាប់ទី៣) មន្ទីរសន្តិសុខវត្តគគរ ដែលបានបង្កើតឡើងនៅឆ្នាំ១៩៧៥។ នៅពេលដែលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងភូមិសាស្ត្រឃុំគគរ រវាងពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨ ការកាប់សម្លាប់ប្រជាជនកើតមានកាន់តែច្រើនឡើង។ ប្រជាជនមូលដ្ឋាន និងជនជាតិភាគតិចចាមត្រូវបានយកទៅសម្លាប់ជាបន្តបន្ទាប់ ខណៈពេលដែលអតីតកម្មាភិបាលភូមិភាគបូព៌ាកម្រិតមូលដ្ឋានជាច្រើន និង





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានស្រោចទឹកកោដ្ឋតម្កល់ក្នុងចេតីយ៍រំឭកសម្រាប់សហគមន៍ ដើម្បីឧទ្ទិសកុសលជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ក្នុងទិវាជាតិនៃការចងចាំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកពាក់ព័ន្ធត្រូវបានចាប់ឃុំឃាំង សួរចម្លើយ និងសម្លាប់នៅមន្ទីរសន្តិសុខឃុំគគរ។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី បានឲ្យអ្នកទោសជីករណ្ដៅសាកសពរួមជាច្រើនមុនពេលសម្លាប់។

ជារៀងរាល់ឆ្នាំ នៅថ្ងៃទិវាជាតិនៃការចងចាំ អាជ្ញាធរមូលដ្ឋាន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សបានប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម នៅក្នុងបរិវេណវត្តគគរ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២នេះ សំណង់ចេតីយ៍សម្រាប់សហគមន៍បានលេចចេញរូបរាងឡើងជាលើកដំបូងនៅភូមិសាស្ត្រឃុំគគរ ដែលអាចឲ្យប្រជាជនមូលដ្ឋានរៀបចំប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនជនរងគ្រោះនៅចេតីយ៍សម្រាប់សហគមន៍នេះ នៅទិវាជាតិនៃការចងចាំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២នេះ។

នៅក្នុងពិធីសូត្រមន្តបង្សុកូលឧទ្ទិសដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម លោកយាយ ប៊ុន សេងហាន អាយុ៧៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បានរៀបរាប់ថា «ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តរាល់ពេលដែលខ្ញុំនឹកឃើញពីការស្លាប់របស់ប្ដី និងបងប្អូនប្រុសស្រីរបស់ខ្ញុំសរុបចំនួន៩ នាក់ក្នុងរបបខ្មែរក្រហម។ ជារៀងរាល់ឆ្នាំ ខ្ញុំនិមន្តព្រះសង្ឃសូត្រមន្តឧទ្ទិសកុសលជូនគ្រួសារដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅផ្ទះ។ ប៉ុន្តែនៅឆ្នាំនេះ ខ្ញុំអាចចូលរួមការប្រារព្ធទិវាជាតិនៃការចងចាំក្នុងមូលដ្ឋានរបស់ខ្ញុំ ដែលមានការកសាងចេតីយ៍សម្រាប់សហគមន៍នេះ។ ខ្ញុំរំភើបផង និងនឹកឃើញពេលវេលានៃការបាត់បង់គ្រួសារផង នៅពេលដែលព្រះសង្ឃសូត្រមន្ត។ ខ្ញុំសូមឧទ្ទិសកុសលជូនគ្រួសាររបស់ខ្ញុំ និងជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម»។

លោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ បានលើកឡើងថា «នៅថ្ងៃទី២០ ខែឧសភា គឺជាថ្ងៃមួយដែលប្រជាជនកម្ពុជាត្រូវតែចងចាំពីរងទុក្ខវេទនា និងការកាប់សម្លាប់ប្រជាជន។ យើងមិនអាចបំភ្លេចរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ទាំងនៅកម្រិតមូលដ្ឋាន និងទូទាំងប្រទេសទេ។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយកសាងចេតិយ៍សម្រាប់សហគមន៍នេះជានិមិត្តរូបសម្រាប់ឲ្យអ្នករស់រានមានជីវិតសិស្សានុសិស្ស និងប្រជាជនមូលដ្ឋានអាចមកចែករំលែកបទពិសោធន៍ជីវិត និងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនជនរងគ្រោះក្នុងរបបខ្មែរក្រហម»។

ជាចុងក្រោយ លោក តុង សុភា អ្នករស់រានមានជីវិត និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានឃុំគគរ បញ្ជាក់ថា «ចេតិយ៍សម្រាប់សហគមន៍នេះជានិមិត្តរូបសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋានឃុំគគរ និងនៅទូទាំងប្រទេសកម្ពុជា។ សម្រាប់ខ្ញុំ ការប្រារព្ធទិវាចងចាំនេះ គឺមានសារសំខាន់ខ្លាំងណាស់ ដែលអាចជួយឲ្យអ្នករស់រានមានជីវិតនិយាយប្រាប់ពីអ្វីដែលបានកើតឡើងនៅក្នុងមូលដ្ឋានទៅកាន់ក្មេងៗជំនាន់ក្រោយ ដើម្បីទប់ស្កាត់របបប្រល័យពូជសាសន៍ខ្មែរក្រហមកុំឲ្យកើតឡើងម្តងទៀត» ។




លោកយាយ ប៊ុន សេងហាន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានបាត់បង់សមាជិកគ្រួសារសរុបចំនួន៩ នាក់ ឧទ្ទិសកុសលជូនក្រុមគ្រួសារ និងជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ក្នុងទិវាជាតិនៃការចងចាំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណើរទស្សនកិច្ចសិក្សា

## របស់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មកកាន់មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

គាត ស្រីឡែន



និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថតរូបជុំគ្នាជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ក្រុមនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន១៩នាក់ និងលោកសាស្ត្រាចារ្យ បានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ។ លោក ឡុង ដានី គឺជានាយកនៅមជ្ឈមណ្ឌលឯកសារកោះថ្ម បានទទួលស្វាគមន៍ សាស្ត្រាចារ្យ និស្សិត ហើយក៏បានជម្រាបអំពីប្រវត្តិនៃការបង្កើត មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ។

មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានបង្កើតឡើងក្រោមការផ្តួចផ្តើមរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនាទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសក្រសួងការពារជាតិ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណង៖

១) បង្ហាញអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ ជាពិសេសដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត, សមមិត្ត ហ៊ុន



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ធ្វើបទបង្ហាញអំពីរូបថតដែលដាក់តាំងបង្ហាញ ទៅដល់ក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សែន និងយុទ្ធមិត្ត៤រូប កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

២) ពង្រឹងដល់ដំណើរការសន្តិភាព និងទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំដែល នឹងផ្តល់ឱកាសឲ្យយុវជនជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមជនបទ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការចែករំលែកអំពីរឿងរ៉ាវ បុព្វទុក្ខ... 

៥) លើកកម្ពស់សុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈការវាយតម្លៃ ស្ថានភាពសុខភាព និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពពួកគាត់។

៦) ពង្រឹងតួនាទីជាអ្នកដឹកនាំដល់អ្នកធ្វើការងារស្ម័គ្រចិត្តតាមរយៈការចូលរួមការបណ្តុះបណ្តាលផ្នែកប្រវត្តិសាស្ត្រ និងសុខភាព និងផ្តល់ឱកាសដល់អ្នកស្ម័គ្រចិត្តធ្វើការងារដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។








និសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទស្សនាពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកលោក ឡុង ដានី បានដឹកនាំនិសិ្សត និងសាស្ត្រាចារ្យដើរទស្សនាពិព័រណ៍រូបថតចំនួន ១៣៣ សន្លឹក រូបគំនូរចំនួន៣៦ផ្ទាំង និងផែនទីចំនួន ៦ផ្ទាំង។ រូបថត និងរូបគំនូរ ទាំងនោះបង្ហាញអំពី ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដោយសង្ក្រាមចាប់ផ្ដើមចេញពីតំបន់កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួល ខេត្តក្រចេះ,បណ្ដុំរូបថត នៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ភ័ស្តុតាងមួយចំនួនអំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា, ដំណើរសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្តទាំង ៤រូប ធ្វើដំណើរឆ្ពោះទៅផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧, ការបង្កើតអង្គភាព ១២៥ និងរូបថតនៃការផ្ដួចផ្ដើមបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ របស់ សម្ដេចតេជោ ហ៊ុន សែន នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅ

ក្នុងឆ្នាំ១៩៩៨។ រូបថតទាំងនោះថត ដោយ លោក ដេវីត ហក គឺជាអ្នកថតរូបជនជាតិអាមេរិក, លោក ឆាំង យុ គឺជាអ្នកថតរូបជនជាតិកម្ពុជា, លោកស្រី ស៊ីវ៉ាណា ហ៊ុរ គឺជាអ្នកថតរូបជនជាតិអាមេរិក, លោក ម៉ៃ ឡាំ គឺជាអ្នកថតរូបជនជាតិវៀតណាម, លោក ហ្គុនណា បើយស្ត្រម គឺ ជាអ្នកថតរូបជនជាតិស៊ុយអែត។ ចំណែករូបគំនូរគូរដោយវិចិត្រករ អ៊ុត វឿន។

នៅចុងបញ្ចប់ លោក ឡុង ដានី បានបន្ថែមថា មជ្ឈមណ្ឌលឯកសារកោះថ្ម គឺជាទីតាំងប្រវត្តិសាស្ត្រ យោធាមួយដែលសម្តេចតេជោ ហ៊ុន សែនបានយក អាយុជីវិតធ្វើជាដើមទុនដើម្បីស្វះស្វែងរកកិច្ច អន្តរាគមន៍ និងកសាងកម្លាំងប្រដាប់អាវុធវាយផ្តួល រំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុ ជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុត ពីសេចក្តីស្លាប់។ ចាប់ផ្តើមពីថ្ងៃ២០ ខែមិថុនា ឆ្នាំ ១៩៧៧ សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត ៤រូប


និសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារ កោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រួមមាន៖ នុត ថត, សន សាញ់, ញឹក ហួន និង វ៉ា ប៉ោអ៊ាន បានចាកចេញពីទីបញ្ជាការដ្ឋាន វរសេនាធំ តំបន់២១ ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុក


ពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌល ឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មេមត់ ខេត្តត្បូងឃ្មុំ ទាំងយប់ឆ្ពោះទៅកាន់ស្រុក ឡុកនិញ ខេត្តសុងបែ (បច្ចុប្បន្នស្រុក ឡុកនិញ ខេត្តប៊ិញហ្វឿក) ប្រទេសវៀតណាមប្រកបដោយគ្រោះថ្នាក់បំផុតៗ ទីកាសល្អនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ អង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធដំបូងដើម្បីតស៊ូប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ត្រូវបានប្រកាសឡើងនៅក្នុងប្រទេសវៀតណាម ដោយមាន សមមិត្ត ហ៊ុន សែន ជាប្រធានទទួលបន្ទុកនយោបាយ និងយោធា, សមមិត្ត នុត ថន គឺជាអនុប្រធានទទួលផ្នែកនយោបាយ, សមមិត្ត ហែម សាមិន គឺជាអនុប្រធានទទួលបន្ទុកភស្តុភារ និងហិរញ្ញវត្ថុ។ បន្ទាប់ពីការប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ អង្គភាព១២៥ បានកើនឡើងរហូតទៅដល់ ២២ វរសេនាតូចបុរស និងមួយកងវរសេនាតូចនារី ដែលមានសមមិត្តនារី មាន សំអាន គឺជាប្រធានកងវរសេនាតូច និងមានកម្លាំងសរុបរហូតដល់ជាង១ម៉ឺននាក់ៗ ចាប់ផ្តើមពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធអង្គភាព ១២៥ និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយសម្រុកជាទ្រង់ទ្រាយធំមកលើរបបខ្មែរក្រហម និងបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់មកអង្គភាព១២៥ បានក្លាយទៅជាកងទ័ពប្រជាជនបដិវត្តន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជាពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ១៩៩៣។ ថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទនាពេលបច្ចុប្បន្នភាគច្រើនបានប្រសូត្រចេញពីអង្គភាព១២៥នេះ។

និស្សិតមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម មានចំណាប់អារម្មណ៍ថា៖ គង់ តាយសេង ភេទប្រុស អាយុ២១ ឆ្នាំ គឺជានិស្សិតឆ្នាំទី៣ផ្នែកទំនាក់ទំនងអន្តរជាតិ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លើកឡើងថា«នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម គឺជាកន្លែងមួយដែលអាចឲ្យខ្ញុំស្រាវជ្រាវទាក់ទងនឹងឯកសារមួយចំនួនអំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តទាំង៤រូប ធ្វើដំណើរទៅប្រទេសវៀតណាមនៅក្នុងគោលបំណងសង្គ្រោះប្រទេសកម្ពុជាឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ចំពោះឯកសារមួយចំនួនទៀតដូចជា រូបថតអំពីរបបខ្មែរក្រហមថា ប្រជាជនកម្ពុជាពិតជាលំបាកវេទនាខ្លាំង។ ចំណែកដែនទីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ទៅវៀតណាមវិញ ខ្ញុំគិតថាបើសិនខ្ញុំចង់ស្រាវជ្រាវលើប្រធានបទនេះ ខ្ញុំអាចរកបាន នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ យើងជាយុវជនជំនាន់ក្រោយ ទាំងអស់ ត្រូវតែរៀនសូត្រអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមដើម្បីទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត»។

ត្រាំង គីមជូ ភេទស្រី អាយុ២០ឆ្នាំ ជានិស្សិតឆ្នាំទី៣ផ្នែកទំនាក់ទំនងអន្តរជាតិនៃសកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច« ខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងទាក់ទងនឹងរបបខ្មែរក្រហម ព្រោះលោកតា លោកយាយខ្ញុំតែងតែនិយាយរឿងរ៉ាវកាលពីសម័យខ្មែរក្រហមប្រាប់ខ្ញុំជាច្រើន គាត់និយាយថាកាលពីសម័យខ្មែរក្រហម អង្គការបង្ខំប្រជាជនឲ្យធ្វើការងារពលកម្មធ្ងន់ៗ ខ្មែរក្រហមបានបែងចែកឲ្យប្រជាជនឲ្យធ្វើពលកម្មទៅតាមកងនីមួយៗ ដូចជាមនុស្សចាស់ធ្វើពលកម្មនៅតាមកងដូចជាលើកដី, ធ្វើស្រែ។ ចំណែកកូនក្មេង ធ្វើពលកម្មនៅក្នុងកងកុមារ។ នៅពេលលោកតា លោកយាយខ្ញុំនិយាយ ខ្ញុំចាប់ផ្តើមចង់ដឹងពីម័យខ្មែរក្រហម ព្រោះរបបនេះបានធ្វើបាបប្រជាជនខ្មែររាប់លាននាក់ៗ ខ្ញុំគិតថាខ្លួនឯងមានសំណាង ដែលមិនបានឆ្លងកាត់របបខ្មែរក្រហម។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំងនោះ គឺនៅពេលបានមកទស្សនកិច្ចសិក្សានៅមជ្ឈ-មណ្ឌលឯកសារកោះថ្ម ដែលពោលពេញទៅដោយរូបភាពនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំគិតថាការសិក្សាប្រវត្តិសាស្ត្រ វាមានសារសំខាន់ណាស់ ព្រោះធ្វើឲ្យយុវជនជំនាន់ក្រោយ បានយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរ និងទប់ស្កាត់របបខ្មែរក្រហមកុំឲ្យកើតមានឡើងម្តងទៀត។

# គរុសិស្ស២៧នាក់មកពីមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគខេត្តកំពង់ចាម ធ្វើទស្សនកិច្ចសិក្សានៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម

**ទូច វណ្ណាត**



*គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ថតរូបជុំគ្នានៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ គរុសិស្សឆ្នាំទី១ចំនួន២៧ នាក់ (ស្រី២០នាក់ និងប្រុស៧ នាក់) នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម បានទស្សនា «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម» ខេត្តកំពង់ចាម ដែលស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានទទួលស្វាគមន៍ និងនាំគរុសិស្សចូលរួមទស្សនាពិព័រណ៍រូបថត និងការដាក់តាំងសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីបង្កើនការចង់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ក្នុងឱកាសទស្សនកិច្ចនេះ លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានបង្ហាញគរុសិស្សនូវកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបណ្ណសារខ្មែរក្រហម ដែលតម្កល់នៅ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម» ខេត្តកំពង់ចាមនេះ និងជំរុញ

ឲ្យគរុសិស្សទាំងអស់ ជាពិសេសគរុសិស្សដែលរៀនមុខវិជ្ជាប្រវត្តិវិទ្យាបន្តមកកាន់ទីតាំងនេះ ដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រើប្រាស់ការិយាល័យនេះសម្រាប់សិក្សាស្រាវជ្រាវ។ ការិយាល័យស្រាវជ្រាវនិងបណ្ណាល័យខ្មែរក្រហម ត្រូវបានបំពាក់គ្រឿងបរិក្ខាទំនើប និងសម្បូរបែបសម្រាប់ការសិក្សាស្រាវជ្រាវពីរបបខ្មែរក្រហម។

ជាកិច្ចបន្ត គរុសិស្សបានទស្សនាវីដេអូឯកសារដែលមានចំណងជើងថា «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ដែលរំឭកអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ គរុសិស្សទាំងអស់អង្គុយទស្សនាវីដេអូ «កុំស្មានបងភ្លេច» យ៉ាងស្ងៀមស្ងាត់ និងយកចិត្តទុកដាក់។

បន្ទាប់ពីបានទស្សនាវីដេអូឯកសារ គរុសិស្សបានសួរសំណួរ និងបានពិភាក្សាជុំវិញប្រធានបទប្រវត្តិ-សាស្ត្រកម្ពុជា។ នៅក្នុងឱកាសនោះគរុសិស្សទទួលបានទស្សនាវដ្តីស្វែងរកការពិតបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីអាន និងឈ្វេងយល់បន្ថែមអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាចុងក្រោយ គរុសិស្សចូលរួមបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

ហង្ស ស្រីទូច គរុសិស្សឆ្នាំទី១ ឯកទេសភាសាខ្មែរ និងពលរដ្ឋ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តក្រចេះ លើកឡើងថា «នាងខ្ញុំទទួលបានអ្វីដែលថ្មីទាក់ទងប្រវត្តិសាស្ត្រ និងតន្ត្រីខ្មែរ។ វីដេអូនេះ បានឆ្លុះបញ្ចាំងអំពីប្រវត្តិអតីតកាលដ៏កម្សត់របស់ប្រជាជនកម្ពុជា។ នាងខ្ញុំបានដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការសិក្សានៅថ្នាក់ទី១២ និងពីឪពុកម្តាយខ្ញុំ ប៉ុន្តែកម្មវិធីថ្ងៃនេះបានធ្វើឲ្យនាងខ្ញុំយល់ដឹងបន្ថែមទៀតពីប្រវត្តិសាស្ត្រនេះ។ នាងខ្ញុំនឹងយកចំណេះដឹងដែលទទួលបានថ្ងៃនេះទៅចែករំលែកជាមួយគរុសិស្សផ្សេងទៀត និងសួរបន្ថែមអំពីរឿងរ៉ាវដែលឪពុកម្តាយរបស់ខ្ញុំបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម»។



ព្រឿង កែវរ៉ានាថ គរុសិស្សឆ្នាំទី១ ឯកទេសភាសាខ្មែរ និងពលរដ្ឋ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តកំពង់ធំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រឿង កែវរ៉ានាថ គរុសិស្សឆ្នាំទី១ ឯកទេសភាសាខ្មែរ និងពលរដ្ឋ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តកំពង់ធំ ចែករំលែកចំណាប់អារម្មណ៍ថា «នៅពេលដែលមើលរូបថតសខ្មៅ ដាក់តាំងនៅបណ្ណាល័យខ្មែរក្រហមដំបូង នាងខ្ញុំមានអារម្មណ៍ភ័យ។ ខ្ញុំធ្លាប់ដឹងរឿងរ៉ាវកើតក្នុងរបបខ្មែរក្រហម តាមរយៈការនិយាយប្រាប់របស់លោកតាលោកយាយ ប៉ុន្តែខ្ញុំមិនយល់ដឹងបានទាំងអស់នោះឡើយ។ ឈាមក្រហមឆ្អៅនៅក្នុងវីដេអូ គឺជាឃ្លាដែលធ្វើឲ្យខ្ញុំកាន់តែភ័យតក់ស្លុតខ្លាំង។ ជាចុងក្រោយ នាងខ្ញុំយល់ថា កម្មវិធីចាក់បញ្ចាំងវីដេអូឯកសារខ្មែរក្រហម និងការជជែកសួរដេញដោលនេះគឺល្អណាស់ សម្រាប់ឲ្យក្មេងៗជំនាន់ក្រោយដូចជានាងខ្ញុំបានដឹងពីប្រវត្តិសាស្ត្រខ្មែរ»។



ហង្ស ស្រីទូច គរុសិស្សឆ្នាំទី១ ឯកទេសភាសាខ្មែរនិងពលរដ្ឋ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តក្រចេះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សែម មឿង គរុសិស្សឆ្នាំទី១ ឯកទេសគណិត និងរូបវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តឧត្តរមានជ័យ បានរៀបរាប់ថា «ខ្ញុំទទួលបានចំណេះដឹងបន្ថែម ទាក់ទងនឹងទុក្ខវេទនា និងការហូបចុកមិនគ្រប់គ្រាន់របស់ប្រជាជនកម្ពុជា តាមរយៈការទស្សនាពិព័រណ៍រូបថត និងសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ការមើលវីដេអូឯកសារ និងការពន្យល់បន្ថែមដោយលោកគ្រូបិន្ទា។ ខ្ញុំនឹងមកទីនេះម្តងទៀតដើម្បីស្រាវជ្រាវនិងទទួលបានការយល់ដឹងបន្ថែមទៀត ក្នុងអំឡុងពេលរៀនសូត្ររបស់ខ្ញុំនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមនេះ»។



សែម មឿង គរុសិស្សឆ្នាំទី១ ឯកទេសគណិត និងរូបវិទ្យា នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម មកពីខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាវីដេអូឯកសារដែលមានចំណងជើងថា «កុំស្អានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ដែលរំឭកអំពីតន្ត្រីវប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទស្សនកិច្ចរបស់និស្សិតសកលវិទ្យាល័យ

## ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មកកាន់ចេតិយ៍រំឭកសម្រាប់សហគមន៍ដើម្បីរំឭកការចងចាំពីអំពើប្រល័យពូជសាសន៍

ទូច វណ្ណាត



និសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថតរូបជុំគ្នាជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នារសៀលថ្ងៃសៅរ៍ ទី១៤ ខែឧសភា ឆ្នាំ២០២២ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានឃុំគគរ គាំទ្រដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សារបស់និស្សិតផ្នែកទំនាក់ទំនងអន្តរជាតិចំនួន១៩ នាក់ ដឹកនាំដោយសាស្ត្រាចារ្យបណ្ឌិត ជា ស៊ីវម៉ី នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មកកាន់ចេតិយ៍រំឭកសម្រាប់សហគមន៍ៗ ដើម្បីជំរុញការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម លោក ស៊ាង ចិន្តា និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញទៅកាន់និស្សិត និងសាស្ត្រាចារ្យចូលរួមទាំងអស់ អំពីកម្មវិធីអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម, ការប្រមូលចងក្រង និងតម្កល់ឯកសារខ្មែរក្រហម, ការដាក់តាំងពិព័រណ៍រូបថតអចិន្ត្រៃយ៍អំពីមេដឹកនាំខ្មែរក្រហម និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការចែកសៀវភៅ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២។



លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រៀបរាប់ប្រាប់ប្រតិភូនិស្សិតអំពីរឿងរ៉ាវដែលបានកើតឡើង នៅភូមិចំការសាមសិបក្នុងរបបខ្មែរក្រហម (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចបន្ទាប់ ប្រតិភូ និស្សិត និងសាស្ត្រាចារ្យបានបន្តដំណើរទៅកាន់ទីតាំងចេតិយ៍រំឭកសម្រាប់សហគមន៍ដើម្បីរំឭកការចងចាំពីអំពើប្រល័យពូជសាសន៍ ស្ថិតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ រៀបរាប់យ៉ាងលម្អិតទៅកាន់ប្រតិភូនិស្សិតអំពីវត្ថុបំណងនៃការសាងសង់ចេតិយ៍ និងរឿងរ៉ាវជនរងគ្រោះ រួមទាំងឪពុករបស់ខ្លួន ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។



ចេតិយ៍រំឭកសម្រាប់សហគមន៍ដើម្បីរំឭកការចងចាំពីអំពើប្រល័យពូជសាសន៍ ស្ថិតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គួររម្លឹកថា ចេតិយ៍រំឭកនេះ ផ្តល់ជាវេទិកាផ្ទាល់ និងនិមិត្តរូប សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអ្នកមានពិការភាព ដើម្បីផ្សាភ្ជាប់ប្រាស្រ័យទាក់ទង និងចែករំលែកបញ្ហាប្រឈមដែលតែងជួបប្រទះ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងជាទូទៅដើម្បីដោះស្រាយ។ គោលបំណងនៃសកម្មភាពនេះគឺផ្តល់ឱកាសបញ្ចេញមតិ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពី បទពិសោធន៍ បញ្ហាប្រឈម និងការស្វះស្វែងជម្នះរាល់ឧបសគ្គរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអ្នកមានពិការភាព តាមរយៈការផ្តល់ឱកាសផ្សាភ្ជាប់ ប្រាស្រ័យទាក់ទង និងចែករំលែកបទពិសោធន៍ បញ្ហា និងការជម្នះតស៊ូទូទៅ នាអតីតកាល និងបច្ចុប្បន្នកាល។

# កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា

## ជាមួយមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ និង អភិបាលស្រុកជាំក្សាន្ត លើគម្រោងសុខភាពនិងប្រវត្តិសាស្ត្រ

*សោម ប៊ុនថន*




*ឧត្តមសេនីយ៍ត្រី ចាន់ សុភត្ត្រា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ (រូបឈរនៅកណ្តាល) ថតរូបជុំគ្នាជាមួយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន អ្នកស្រី គីម សុវណ្ណដានី លោក សោម ប៊ុនថន និង លោក ផាត សិលា បានជួបជាមួយលោក ចាន់ សុភត្ត្រា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ និងលោក ផាន់ សាម៉ែន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងស្រុកជាំក្សាន្ត ដើម្បីពិភាក្សាលើការងារគម្រោងប្រវត្តិសាស្ត្រខ្មែរក្រហម និងសុខភាព។ នៅក្នុងឱកាសនោះដែរ ដោយមានការអនុញ្ញាតពីលោក ចាន់ សុភត្ត្រា និងលោក ផាន់ សាម៉ែន ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងភូមិតេជោបុស្សស្បូវ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ នៅក្នុងថ្ងៃដដែល ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានជួបជាមួយលោក វុធ តារ៉ា អភិបាលនៃគណៈអភិបាលស្រុកជាំក្សាន្ត និងលោក យុង ហួន ក្រុមប្រឹក្សាស្រុកជាំក្សាន្តដើម្បីជម្រាបជូនអំពីការងារគម្រោងប្រវត្តិសាស្ត្រខ្មែរក្រហម និងការងារសុខភាព និងសុំការអនុញ្ញាតដើម្បីធ្វើកិច្ចការនេះ។

គោលបំណងនៃគម្រោងប្រវត្តិសាស្ត្រ និងសុខភាព គឺ (១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅតាមគោលដៅ



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបពិភាក្សាការងារជាមួយលោក ផាន់ សាម៉ែន មេបញ្ជាការតំបន់ប្រតិបត្តិការសឹកស្រុកជាំក្សាន្ត និងកងទ័ពឈរជើងនៅច្រកជាំតែ ស្ថិតនៅក្នុងភូមិតេជោបុស្សស្បូវ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ដែលបានកំណត់ (២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង (៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាពិសេសនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មានក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជននិងសហគមន៍ទាំងនេះ។

ចាប់តាំងពីដើមខែសីហា ឆ្នាំ២០២១មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជាបួនជំនាន់រួចមកហើយ ដែលមានចំនួន ៩០០នាក់ បានចុះធ្វើការនៅតាមមូលដ្ឋានទូទាំង២៥ រាជធានីខេត្តក្រុងនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះមានអ្នកស្ម័គ្រចិត្តចំនួន ៥០នាក់ មកពីស្រុកគូលែន ត្បែងមានជ័យ ជ័យសែន ឆែប សង្គមថ្មី និងស្រុករវៀង ត្រូវបានជ្រើសរើសឲ្យធ្វើការងារនៅក្នុងគម្រោងសុខភាព និងប្រវត្តិសាស្ត្រនេះ។ ក្រុមអ្នកស្ម័គ្រចិត្តនៅក្នុងខេត្តព្រះវិហារ បានចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាឪពុកម្តាយ អ៊ំពូ មីង ក៏ដូចជាអ្នកស្រុកភូមិរបស់ខ្លួនសរុបចំនួនប្រមាណ ២០០០នាក់រួចមកហើយ។ នៅក្នុងខែឧសភា ឆ្នាំ២០២២ នេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តជំនាន់ទី៥ មកពីបណ្តាខេត្តនានា នៅទូទាំងប្រទេសកម្ពុជា។ ចំពោះខេត្តព្រះវិហារ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់យកស្រុកជាំក្សាន្ត ជាគោលដៅអទិភាពដើម្បីបន្តការងារ ព្រោះប្រជាជននៅក្នុងស្រុកនេះភាគច្រើនរស់នៅតំបន់ដាច់ស្រយាល មានជីវភាពក្រីក្រ និងត្រូវការចាំបាច់នូវការថែទាំសុខភាព។

សូមរំឭកថាកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២១ កន្លងមក ភូមិសាស្ត្រមួយចំនួនក្នុងស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ រួមមាន ឃុំជាំក្សាន្ត ឃុំទឹកក្រហម ឃុំព្រីងធំ ឃុំរំដោះស្រែ ឃុំយាង ឃុំកន្ទួត ឃុំស្រអែម និង



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថតរូបជុំគ្នាជាមួយកងទ័ពឈរជើងនៅច្រកជាំតែ ស្ថិតនៅក្នុងភូមិតេជោបុស្សស្បូវ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃុំមរកត ត្រូវបានបិទខ្ទប់ និង កំណត់ស្រុកជាំក្សាន្តជាតំបន់ក្រហម ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បំប្លែងថ្មី ដែលតា (Delta) ដោយសារតំបន់នេះមានព្រំប្រទល់ជាប់ជាមួយប្រទេសថៃ និង ឡាវ ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោក វុធ ដារ៉ា អភិបាលនៃគណៈអភិបាលស្រុកជាំក្សាន្ត និងលោក យុង ហួន ក្រុមប្រឹក្សាស្រុកជាំក្សាន្ត បានសម្តែងការស្វាគមន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជ្រើសរើសយកស្រុកជាំក្សាន្តជាគោលដៅដើម្បីចុះស្រាវជ្រាវទាក់ទងនឹងប្រវត្តិប្រវត្តិសាស្ត្រខ្មែរក្រហម និងជួយលើផ្នែកសុខភាព ព្រោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែមានវ័យចំណាស់ទៅហើយ។



រូបរាប់ពីស្តាំ៖ លោក សោម ប៊ុនថន ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក យ៉ុង ហួត ប្រធានក្រុមប្រឹក្សាស្រុកជាំក្សាន្ត, លោក វុធ តារ៉ា អភិបាលស្រុកជាំក្សាន្ត និងអ្នកស្រី គីម សុវណ្ណដានីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថតរូបជុំគ្នាជាមួយកងទ័ពឈរជើងនៅច្រកជាំតែ ស្ថិតនៅក្នុងភូមិតេជោបុស្សស្បូវ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កងទ័ពឈរជើងនៅច្រកជាំតែ កំពុងពិនិត្យមើលអណ្តូងទឹក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈឹម ឡុក៖ កងចល័តនៅក្នុងរបបខ្មែរក្រហម

រដេង ពន្សរ៉ាស៊ី



ឈឹម ឡុក អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈឹម ឡុកអាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិជ្រៃឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឈឹម ឡុក កើតនៅឆ្នាំ១៩៥០ ក្នុងគ្រួសារដែលមានជីវភាពក្រីក្រនៅភូមិត្រោក ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឈឹម ឡុក មិនបានរៀនសូត្រជ្រៅជ្រះទេ គឺគាត់បានឈប់រៀននៅឆ្នាំ១៩៦៧ ដើម្បីជួយឪពុកម្ដាយធ្វើស្រែ និងធ្វើការងារក្នុងផ្ទះរហូតដល់ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ក្រោយរដ្ឋប្រហារភ្លាម មានហេតុការណ៍ដាក់ពង្រាយ ទាហានធីវគីនៅលើទឹកដីភូមិត្រោក។ អ្នកភូមិទាំងអស់បានចាកចេញពីភូមិកំណើតរបស់ខ្លួន។ កាលនោះ ទីតាំង«ត្រពាំងទ័ព» ស្ថិតក្នុងភូមិត្រោក បានក្លាយជាសមរភូមិប្រយុទ្ធរវាងកងកម្លាំងវៀតកុង និងធីវគី ហើយក៏ជាទីកន្លែងមកដល់ដំបូងនៃកងទ័ពធីវគីរាប់រយនាក់ដែរ។ ឈឹម ឡុក បានឃើញហេតុការណ៍នេះផ្ទាល់ភ្នែក និងបានរំឭកឡើងវិញថា៖

ខ្ញុំរន្ធត់ខ្លាំងណាស់ នៅពេលដែលខ្ញុំកំពុងនៅលើចុងត្នោត ព្រោះបានឃើញផ្ទាល់ភ្នែកនូវកន្ទុំរុយ (ឧទ្ធម្ភាគចក្រ) ចំនួន ១០គ្រឿង ផ្ទុកទាហានធីវគីពេញៗ បន្ទាប់ខ្លួនចុះចតនៅលើដី ដើម្បីឲ្យទាហានទាំងនោះចេញពីឧទ្ធម្ភាគចក្រ។ ក្នុងមួយឧទ្ធម្ភាគចក្រមានទាហាន១២នាក់ ។ នៅពេលដែលទាហានទាំងនោះចុះអស់ ឧទ្ធម្ភាគចក្រទាំងនេះបានហោះត្រឡប់ទៅវិញ។ មួយសន្ទុះក្រោយមក ខ្ញុំបានឃើញឧទ្ធម្ភាគចក្រត្រឡប់មកវិញដោយដឹកទាហានធីវគីមកបន្ថែមទៀត។

ខ្ញុំមិនហ៊ានចុះពីលើចុងត្នោតឡើយ ព្រោះទាហានធីវគីនៅជុំគ្នាពេញទីវាលចតឧទ្ធម្ភាគចក្រ។ ខ្ញុំនៅលើចុងត្នោតរហូតទាល់តែឧទ្ធម្ភាគចក្រទាំងនោះត្រឡប់ទៅវិញ ហើយទាហានធីវគីទាំងអស់បានចាកចេញពីទីនោះ។ ខ្ញុំបានឃើញឧទ្ធម្ភាគចក្រ១០គ្រឿង ចុះចតចំនួន ៥លើកក្នុងថ្ងៃតែមួយ ដើម្បីដាក់ទាហានធីវគីចុះ។ ខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្លាចទាហានធីវគីឃើញខ្ញុំ ហើយបាញ់ខ្ញុំទម្លាក់ពីលើចុងត្នោត។

នៅឆ្នាំ១៩៧១ ខ្ញុំបានរៀបការជាមួយស្ត្រីដែលជាអ្នកភូមិជាមួយគ្នា ក្នុងពេលដែលស្ថានភាពរស់នៅរបស់ប្រជាជនទូទៅក្នុងឃុំជ្រៃកំពុងទទួលរងនូវការទម្លាក់គ្រាប់បែក និងការប្រយុទ្ធគ្នា។ នៅពេលនោះ ក្រុមពួករដ្ឋការ (អ្នកបម្រើការខាងរបបសាធារណរដ្ឋខ្មែរ) មួយកងមានគ្នាជាងដប់នាក់ បាននាំគ្នាចូលហូបអាហារដែលរៀបចំទុកសម្រាប់ទទួលភ្ញៀវក្នុងពិធីរៀបការរបស់អ្នកភូមិ ដោយមិនបានប្រាប់ដំណឹងមុនឡើយ។ ខ្ញុំ និងក្រុមគ្រួសារ ក៏ដូចជា អ្នកភូមិឯទៀតដែលបានចូលរួមនៅក្នុងពិធីមង្គលការ មានការភ័យស្លន់ស្លោចំពោះវត្តមានអ្នកទាំងនោះ ព្រោះទាហានម្នាក់ៗសុទ្ធតែមានស្ពាយកាំភ្លើង និងបង្ហាញអាកប្បកិរិយាប្រផេងប្រផាង និងបុកពារមិនសមរម្យ។ ក្រោយពេលរៀបការ ខ្ញុំនិងប្រពន្ធមិនដែលបានសម្រាកនៅក្នុងផ្ទះជាប់លាប់ទេ និងមិនបានប្រកបរបរធ្វើស្រែដូចរាល់ដងដែរ ព្រោះតែសង្គ្រាម និងការចូលលុកលុយរបស់ទាហានធីវគី និងក្រុមរដ្ឋការ។ សមរភូមិតូចធំបានកើតឡើងជាហូរហែនៅក្នុងភូមិត្រោក។ អ្នកភូមិទាំងអស់បានបោះបង់ចោលផ្ទះសម្បែងរបស់ខ្លួនរួចបាននាំគ្នាស្វែងរកទីជម្រកបណ្ដោះអាសន្ននៅក្បែរផ្លូវជាតិលេខ១១។

នៅឆ្នាំ១៩៧២ ខ្ញុំនិងប្រពន្ធ ព្រមទាំងអ្នកភូមិឯទៀត បានវិលត្រឡប់មកកាន់ភូមិកំណើតវិញ បន្ទាប់ពីបានដឹងថា កងកម្លាំងធីវគីនិងពួករដ្ឋការ បានដាក់មូលដ្ឋានទ័ពរបស់ខ្លួននៅក្នុងបរិវេណវត្តព្រៃពោន។ មកដល់ផ្ទះវិញ អ្នកភូមិភាគច្រើនបានចូលបម្រើក្នុងជួរបដិវត្តន៍តាមការអូសទាញគ្នាពីកន្លែងមួយទៅកន្លែងមួយ។ កងកម្លាំងវៀតកុង (វៀតណាមខាងជើង) គឺជាអ្នកជួយបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រដល់អ្នកភូមិដែលបានស្ម័គ្រចិត្តចូលបម្រើក្នុងកងកម្លាំងរំដោះ បុចលនារួបរួមជាតិកម្ពុជា។ មូលដ្ឋានមួយកន្លែងស្ថិតនៅក្បែរវត្តបេង ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមូលដ្ឋានយោធារបស់ លន់ នល់ នៅវត្តព្រៃពោន គឺជាកន្លែងប្រមូលផ្តុំ និងបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រដល់កងកម្លាំងខ្មែររំដោះ។ ខ្ញុំមិនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរបដិវត្តន៍ឡើយ។ ប្រធានភូមិ និងអ្នកស្គាល់គ្នាជាច្រើននាក់បានមកអូសទាញខ្ញុំឲ្យចូលបម្រើជាតិ ប៉ុន្តែខ្ញុំប្រកែកដោយលើកហេតុផលថា នៅមើលប្រពន្ធកូនខ្ញុំ និងរកស៊ីចិញ្ចឹមគ្រួសារ។

ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម នៅទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានរើសអើង និងចាត់ចូលជាប្រជាជនថ្មីដូចប្រជាជនជម្លៀសឯទៀតដែរ។ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋាន ចាត់តាំងឲ្យធ្វើការងាររែកដី លើកទំនប់ ជីកប្រឡាយ ភ្ជួរស្រែ និងដឹកជញ្ជូនស្រូវ។ ខ្ញុំបានហូបបាយនៅត្រឹមតែដើមឆ្នាំ១៩៧៦ប៉ុណ្ណោះ ក្រោយមកត្រូវប្តូរមកហូបបបររហូតដល់ថ្ងៃរំដោះ ទី៧ ខែមករា ឆ្នាំ១៩៧៩។ ខ្ញុំមិនមានបាត់បង់សមាជិកគ្រួសារណាម្នាក់ក្នុងរបបខ្មែរក្រហមឡើយ។ អ្វីដែលពិបាកបំផុតសម្រាប់ខ្ញុំនៅសម័យនោះ គឺការហូបចុកមិនគ្រប់គ្រាន់ ហើយហេតុការណ៍ដែលធ្វើឲ្យខ្ញុំរន្ធត់បំផុតនោះ គឺឃើញសាកសពមនុស្សនៅក្នុងរណ្តៅ និងស្លាកស្នាមនៃការធ្វើទារុណកម្មរបស់កម្មាភិបាលខ្មែរក្រហមខាងភូមិភាគនិរតីមកលើប្រជាជននិងអតីតកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ា។

ខ្ញុំនៅចាំថា «ថ្ងៃមួយវេលាម៉ោងប្រមាណ ១០ព្រឹកក្នុងឆ្នាំ១៩៧៨ ខ្ញុំបានបណ្តើរគោឲ្យស៊ីស្មៅរហូតដល់ប្រទះឃើញរណ្តៅធំៗចំនួនបី និងបង្គោលបុស្សីបញ្ឈរខ្ពស់ៗចំនួនពីរ ដែលនៅខាងចុងមានចងភ្ជាប់មេក្រូពីរសម្រាប់ចាក់បន្ទឺសំឡេងឡើងៗ។ រណ្តៅទាំងនោះមានទំហំប្រហែល៦ម៉ែត្រការ៉េ។ ខ្ញុំមិនដឹងពីជម្រៅរណ្តៅទេ ព្រោះសាកសពមនុស្សនៅពេញរណ្តៅទាំងបីនោះ។ ខ្ញុំរន្ធត់ខ្លាំងណាស់។ ខ្ញុំឃើញសាកសពដែល

ស្លាប់ទៅហើយ និងឃើញមនុស្ស កំពុងប្រកាច់ ព្រមទាំងឃើញមនុស្សដែលខំប្រឹងវារតោងសាកសពដទៃទៀតដើម្បីឡើងមកខាងលើមាត់រណ្ដៅ។ ខ្ញុំឃើញឈាមប្រឡាក់សាកសព អ្នករងរបួស និងឃើញឧបករណ៍ធ្វើទារុណកម្ម និងវាយសម្លាប់។ ខ្ញុំហូបបបរមិនចូល បន្ទាប់ពីឃើញហេតុការណ៍នោះ។ ក្រោយមក ខ្មែរក្រហមមកពីខាងភូមិភាគនិរតីបានបង្ខំខ្ញុំ និងប្រជាជនឯទៀតឲ្យចាកចេញទៅកាន់ស្រុកព្រះស្ដេច និងបន្តទៅអ្នកលឿង។ ខ្ញុំមិនបានទៅអ្នកលឿងទេ ព្រោះកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមកជួយសង្គ្រោះ។ ខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ និងបានរស់នៅជុំគ្រួសាររហូតមក។

សព្វថ្ងៃខ្ញុំមានមុខរបរជាចុងភៅ និងជាអ្នកបណ្ដុះសណ្ដែកលក់។ ប្រពន្ធរបស់ខ្ញុំបានជួយធ្វើកិច្ចការនេះ។ បន្ទាប់ពីជំងឺកូវីដ-១៩ បានថមថយ ខ្ញុំពុំសូវមានពេលទំនេរឡើយ ព្រោះខ្ញុំត្រូវទៅធ្វើចុងភៅនៅតាមពិធីបុណ្យ និងមង្គលការនៅក្នុងឃុំជ្រៃ និងឃុំផ្សេងៗទៀត។ ក្រៅពីកិច្ចការចុងភៅ ខ្ញុំមានតួនាទីមួយទៀតគឺ ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាប្រចាំឃុំជ្រៃ។ ខ្ញុំសូមផ្ដាំផ្ញើឲ្យក្មេងៗជំនាន់ក្រោយ ខិតខំរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្បាស់លាស់ ដើម្បីជាការចូលរួមទប់ស្កាត់ការវិលត្រឡប់នៃរបបប៉ុល ពត ជាលើកទីពីរ។



វាលស្រែនៅក្នុងភូមិជ្រៃ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញឹម លាម ៖ រឿងរ៉ាវជីវិតក្នុងសម័យខ្មែរក្រហម

*សូ ហាន់*



ញឹម លាម អាយុ៦៧ឆ្នាំ រស់នៅភូមិដក់ពរ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ញឹម លាម អាយុ៦៧ឆ្នាំ (កើតនៅឆ្នាំ១៩៥៥) ក្នុងត្រកូលកសិករក្រីក្រ នៅភូមិដក់ពរ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុករបស់ លាម ឈ្មោះ ញឹម ពុំ និងម្តាយឈ្មោះ អ៊ុំ ស៊ិន់។ លាម មិនបានរៀនសូត្រជ្រៅជ្រះទេ គឺរៀនត្រឹមថ្នាក់ទី១១ (ស្មើថ្នាក់ទី២) កាលពីសម័យសង្គមរាស្ត្រនិយម ហើយក៏បានឈប់រៀនមកជួយមើលថែប្អូនក្នុងគ្រួសារ។ លាមបានរៀបការនៅអាយុ១៨ឆ្នាំ (ក្នុងឆ្នាំ១៩៦៩) ជាមួយប្តីឈ្មោះ យូរ វង្ស។ ក្រោយពីរៀបការរួច លាម បានទៅរស់នៅជាមួយគ្រួសារខាងប្តី នៅក្នុងភូមិប្រធាតុ ឃុំប្រធាតុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ពេលដែល លាម ទៅរស់នៅភូមិប្រធាតុ ក៏កើតមានព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់។ នៅក្នុងឆ្នាំ១៩៧០ដដែល លាម បានឃើញមានវត្តមានកងទ័ពវៀតកុង នៅក្នុងឃុំប្រធាតុ។ បន្តិចក្រោយមកក៏មានការទម្លាក់គ្រាប់បែកធ្វើឲ្យប្រជាជនភិតភ័យ និងរត់ចូលលេណដ្ឋានដើម្បីលាក់ខ្លួនស្ទើររាល់ថ្ងៃ។ លាម បានបន្តទៀតថា មកដល់ឆ្នាំ១៩៧៣ ការទម្លាក់គ្រាប់បែកលែងកើតមានហើយ ហើយការធ្វើស្រែប្រវាស់ដៃក៏ចាប់ផ្តើមជាបណ្តើរៗ។

ក្រោយពីខ្មែរក្រហម ទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លាម ឃើញមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មករស់នៅតាមទីជនបទដាច់ស្រយាល។ ប្រជាជនជម្លៀសទាំងនោះត្រូវអង្គការចាត់ឲ្យរស់នៅដាច់ដោយឡែកពីគ្នា។ លាម និងគ្រួសារ ក៏ត្រូវបានអង្គការចាត់ឲ្យរស់នៅបែកពីគ្នាដែរ ដោយប្តីរបស់ លាម ត្រូវទៅធ្វើជាគ្រូបង្រៀនក្មេងៗនៅភូមិផ្សេងចំណែកលាមរស់នៅក្នុងភូមិប្រធាតុដែលជាស្រុកកំណើតរបស់ប្តីដដែល។ លាម បានលើកឡើងថា ក្នុងរបប ប៉ុល ពត អង្គការប្រើគាត់ឲ្យធ្វើការងារមិនដែលបានសម្រាកឡើយ។ ការងារទាំងនោះមានដូចជា ធ្វើដី លើកប្រព័ន្ធភ្លឺស្រែ លើកដីចាក់បំពេញភូមិដើម្បីសង់ផ្ទះថ្មីឲ្យប្រជាជនស្នាក់នៅ សែងផ្ទះ និងបុកស្រូវ។ រីឯការហូបចុកវិញ លាម មិនបាន

ហូបឆ្អែត និងគ្រប់គ្រាន់ឡើយ គឺភាគច្រើនហូបតែបបរលាយជាមួយសម្លដើមចេក ដែលជាហេតុធ្វើឲ្យ លាម និងប្រជាជនដទៃទៀតមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើការងារ។ លាម បានបន្ថែមទៀតថា សូម្បីតែដំណាំ និងសត្វរបស់គាត់ចិញ្ចឹម ក៏អង្គការមិនឲ្យហូបដែរ គឺឲ្យយកទៅដាក់នៅក្នុងរោងបាយរួម។ ប្រសិនបើប្រជាជនណាលួចហូប ហើយអង្គការស៊ើបដឹង នឹងចាប់បញ្ជូនទៅរៀនសូត្រមិនខាន។ នៅពេលដែលអង្គការបញ្ជូនអ្នកប្រព្រឹត្តកំហុសទៅរៀនសូត្រ គឺមិនដែលឃើញអ្នកទាំងនោះវិលត្រឡប់មកវិញទេ។ ក្រៅពីការបញ្ជូនទៅរៀនសូត្រ ក៏ឃើញមានការជម្លៀសប្រជាជនឲ្យទៅខេត្តពោធិ៍សាត់ និងបាត់ដំបងដែរ។

នៅឆ្នាំ១៩៧៨ ពេលខាងកម្មាភិបាល និងកងទ័ពមកពីភូមិភាគនិរតីចូលមកក្នុងមូលដ្ឋាន ការហូបចុកកាន់តែមានការខ្វះខាតទៅៗ។ កម្មាភិបាល និងកងទ័ពមកពីខាងនិរតីបានចោទប្រជាជននៅក្នុងភូមិភាគបូព៌ាថា«ខ្មែរក្បាលសក្បត់ជាមួយអង្គការ»។ នៅពេលនោះ លាម ឃើញមានប្រជាជនជាច្រើនបានរត់គេចខ្លួនចូលទៅក្នុងប្រទេសវៀតណាម។ អ្នកដែលរត់គេចខ្លួនទាំងនោះ នៅពេលដែលអង្គការចាប់ខ្លួនបាន ត្រូវបានអង្គការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ និងបាញ់សម្លាប់ចោលតែម្តង។ លាមបានលើកឡើងថា នៅចុងឆ្នាំ១៩៧៨ កម្មាភិបាល និងកងទ័ពមកពីនិរតីបានបញ្ជូឲ្យគាត់ និងប្រជាជនដទៃទៀតជីកស្រះដែលមានទំហំ៨ម៉ែត្រគុណនឹង៨ម៉ែត្រ ដោយគាត់ឮពាក្យចចាមអារ៉ាមថាកម្មាភិបាល និងកងទ័ពខ្មែរក្រហមទាំងនោះមានគម្រោងសម្លាប់ប្រជាជន និងកប់ក្នុងស្រះនោះ។ ប៉ុន្តែគម្រោងនៃការសម្លាប់នោះបានបរាជ័យ ដោយសារមានកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះទាន់ពេលវេលា។

ទោះបីយ៉ាងណានៅមុនពេលរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ លាម និងប្រជាជនដទៃទៀតត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិទាំងអស់។ លាម ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ភូមិកប់ប្រហុក ស្ថិតនៅខាងកើតអ្នកលឿង។ បន្ទាប់មកក៏មានអ្នកជិះសេះទៅប្រាប់គាត់ថាឲ្យវិលត្រឡប់មកក្រោយវិញ ព្រោះប្រទេសជាតិត្រូវបានរំដោះហើយ។ លាម បានវិលមកផ្ទះវិញ និងបានមករស់នៅជួបជុំគ្រួសារឡើងវិញ។ លាម និយាយថា អ្វីដែលគាត់នៅតែចងចាំមិនអាចបំភ្លេចបាននោះ គឺការបាត់បង់បងប្អូន២នាក់ និងការដែលអង្គការប្រើឲ្យគាត់ធ្វើការងារគ្មានពេលសម្រាក គឺឲ្យបុកស្រូវក្នុងមួយថ្ងៃឲ្យបានចំនួន៧តៅ ប្រសិនបើបុកស្រូវមិនហើយតាមផែនការ គឺអង្គការមិនឲ្យហូបបាយឡើយ។ ក្រោយពេលរំដោះភ្លាមៗ លាម និងគ្រួសារនៅតែមានការលំបាកក្នុងការហូបចុក។ មួយរយៈក្រោយមក នៅពេលដែល លាម និងគ្រួសារធ្វើស្រែ និងដាំដុះដំណាំបានរយៈពេលមួយឆ្នាំ ទើបការហូបចុករបស់គាត់បានប្រសើរឡើងវិញ។ សព្វថ្ងៃជីវភាពរបស់ លាម មិនធូរធាឡើយ ព្រោះត្រូវចំណាយថវិកាមួយចំនួនធំ ដើម្បីព្យាបាលជំងឺប្រចាំកាយរបស់ប្តីគាត់។



ញឹម លាម ផ្តល់បទសម្ភាសន៍ដល់ សូ ហាន់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពុធ សារឿន ៖ កងចល័តនៅក្នុងរបបខ្មែរក្រហម

*សូ ហាន់*



ពុធ សារឿន អាយុ៦២ឆ្នាំ រស់នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពុធ សារឿន អាយុ៦២ឆ្នាំ កើតនៅភូមិជ្រៃ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សារឿន រស់នៅក្នុងគ្រួសារកសិករដែលមានជីវភាពមធ្យម។ សារឿន ជាកូនទី២ក្នុងចំណោមបងប្អូន៩ នាក់។ សារឿន ចូលរៀនដំបូងនៅសាលាបឋមសិក្សាជ្រៃ។ ក្រោយកើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សារឿនបានឈប់រៀន។ សារឿន និងក្រុមគ្រួសារបានផ្លាស់ទៅរស់នៅម្តុំវត្តរមាសឈរ ស្ថិតនៅក្នុងឃុំគោខ្ទុក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយសារភ័យខ្លាចការទម្លាក់គ្រាប់បែក និងភ័យខ្លាចទាហានធីវគីចូលមកធ្វើបាបប្លន់យកទ្រព្យសម្បត្តិ និងសត្វពាហនៈ។

ក្រោយពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សារឿន ឃើញមានការជម្លៀសប្រជាជនចេញពីទីក្រុងមករស់នៅតាមទីជនបទ។ ប្រជាជនជម្លៀសពីទីក្រុងភ្នំពេញមករស់នៅតាមមូលដ្ឋានបានរយៈពេលចំនួន៣ថ្ងៃតែប៉ុណ្ណោះ ក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅទួលពោធិ៍ចាម (ឬទួលត្នោត) ដែលមានទីតាំងស្ថិតនៅខាងកើតវត្តព្រៃវៀរ។ សារឿន បាននិយាយថា ពេលនោះ គាត់បានឃើញឈ្លបខ្មែរក្រហមបណ្តើរមនុស្សទាំងហ្វូងៗ យកទៅសម្លាប់ចោល។ ជារៀងរាល់ពេលកម្មាភិបាលខ្មែរក្រហមយកមនុស្សទៅសម្លាប់ គឺតែងតែចាក់មេក្រូដើម្បីកុំឲ្យសំឡេងស្រែករបស់ជនរងគ្រោះឮចេញមកខាងក្រៅ។ ឈ្លបខ្មែរក្រហមបានរឹះយកប្រមាត់របស់ជនរងគ្រោះមកដាក់ហាលទុក និងដើម្បីរាប់ចំនួនរាយការណ៍ជូនថ្នាក់លើ។ ចំណែកប្រជាជន ត្រូវបែងចែកជាពីរប្រភេទ គឺ ទី១) ប្រជាជនដែលរស់នៅក្នុងមូលដ្ឋានរំដោះ ចាត់ចូលជាប្រជាជនត្រៀម និង ទី២) ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញ ចាត់ចូលជាប្រជាជនថ្មី។ បន្ទាប់មកខ្មែរក្រហមបានបែងចែកការរស់នៅរបស់ប្រជាជន គឺកុមាររស់នៅដោយក្រុមកុមារ, យុវជនរស់នៅដោយក្រុមយុវជន និងមនុស្សចាស់រស់ដោយមនុស្សចាស់។ ចំណែកការហូបចុក មុនដំបូងខ្មែរក្រហមឲ្យប្រជាជនហូបបាយ តែក្រោយមកឲ្យហូបតែបបរលាយជាមួយ

សម្ដើមចេកប៉ុណ្ណោះ។ កាលនោះ នៅក្នុងភូមិជ្រៃ មានរោងបាយរួមទាំងអស់ចំនួន៤កន្លែង។

សាវឿន និងគ្រួសារខ្លួនរស់នៅលំបាកខ្លាំងណាស់ ដោយសារតែឪពុករបស់គាត់មានជាប់សន្តិសម្ព័ន្ធ (ជាប់និន្នាការនយោបាយពីសង្គមចាស់)។ ខ្មែរក្រហមចាត់តាំងឲ្យ សាវឿន ធ្វើដីដាក់ស្រែ បន្ទាប់មក ក៏បញ្ជូនគាត់ឲ្យទៅលើកប្រព័ន្ធប្រឡាយនៅឃុំឈើកាច់ ក្នុងស្រុកបាភ្នំ។ នៅទីនោះ ប្រធានកងបានបែងចែកជាក្រុមៗ ដោយមួយក្រុមមានសមាជិកចំនួន៣នាក់ និងត្រូវលើកប្រឡាយប្រវែង១២ម៉ែត្រឲ្យហើយក្នុងមួយថ្ងៃ។ សាវឿន បាននិយាយថា គាត់មានសំណាងដោយសារសមាជិកក្នុងក្រុមរបស់គាត់ឆ្លាត និងអាចលួចបន្ថំចំនួនម៉ែត្របាន។ ក្រៅពីលើកប្រព័ន្ធប្រឡាយ ខ្មែរក្រហមប្រើ សាវឿន ឲ្យលើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយ។ សាវឿន បន្តថា នៅពេលគាត់ឈឺ គាត់មិនដែលហ៊ានប្រាប់ប្រធានក្រុមទេ ព្រោះគាត់ឃើញខ្មែរក្រហមបញ្ជូនអ្នកដែលសុំច្បាប់ឈឺទៅរៀនសូត្រ។ នៅពេលខ្មែរក្រហមបញ្ជូនអ្នកទាំងនោះទៅរៀនសូត្រហើយ គឺមិនដែលបានវិលត្រឡប់មកកងវិញទេ។

ក្រោយមក ខ្មែរក្រហមបានបញ្ជូន សាវឿន មកដកស្ទូង និងធ្វើស្រែនៅឃុំពាមមន្ទារ ស្រុកកំពង់ត្របែកវិញ។ សាវឿន ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅជីកស្រះទំហំ៤ម៉ែត្រគុណ៤ម៉ែត្រ នៅភូមិជីពាយ និងទៅធ្វើការនៅភូមិក្រសាំងទងទៀត។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយចូលមករំដោះប្រជាជន។ ពេលនោះ សាវឿន ឃើញអ្នកជិះសេះប្រកាសប្រាប់ប្រជាជនឲ្យវិលទៅភូមិកំណើតរបស់ខ្លួនវិញ ព្រោះកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដណ្ដើមបានជ័យជម្នះពីកម្លាំងរបស់ ប៉ុល ពត ហើយ។ សាវឿន ក៏ដូចប្រជាជនដទៃទៀតបានវិលត្រឡប់មកផ្ទះនៅក្នុងភូមិជ្រៃ និងជួបជុំគ្រួសារវិញ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សាវឿន បានរៀបការជាមួយប្ដីឈ្មោះ ហ៊ីវ សារុន និងមានកូនចំនួន៨នាក់ ក្នុងនោះមានកូនស្រី៣នាក់។ គ្រួសាររបស់ សាវឿន រស់នៅមិនលំបាកដូចសម័យខ្មែរក្រហមទេ ព្រោះប្ដីរបស់គាត់មានប្រាក់បៀវត្សរ៍ ហើយគាត់អាចរកចំណូលបន្ថែមពីការចិញ្ចឹមសត្វ និងដាំបន្លែលក់យកប្រាក់មកផ្គត់ផ្គង់ជីវភាពរស់នៅក្នុងគ្រួសារ។



ពុធ សាវឿន ផ្ដល់បទសម្ភាសន៍ដល់ សូ ហាន់ ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាប្រវត្តិសាស្ត្រគ្រួសារ

## នៅឃុំមហាលាភ ស្រុកកោះសូទិន និង ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម

***ទូច វណ្ណាត និង អេង វណ្ណីកា***

ពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាប្រវត្តិសាស្ត្រគ្រួសារនៅស្រុកកំពង់សៀម និងស្រុកកោះសូទិន ខេត្តកំពង់ចាម។ ក្រុមការងារបានចំណាយរយៈពេលចំនួន២ថ្ងៃធ្វើការសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ បន្ទាប់មកក្រុមការងារបានបន្តចុះសម្ភាសន៍អ្នករស់មានជីវិតពីរបបខ្មែរក្រហមនៅភូមិមហាលាភជើង ឃុំមហាលាភ ស្រុកកោះសូទិន។ ខាងក្រោមគឺជារឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

### ១) ឈុន ញាណ កងចល័តនារីក្នុងរបបខ្មែរក្រហម




*ឈុន ញាណ អាយុ៧៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិមហាលាភជើង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម*

ឈុន ញាណ ភេទស្រី អាយុ៧៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិមហាលាភជើង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម បានរៀបរាប់រឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមថា ខ្ញុំឈ្មោះ ឈុន ញាណ កើតនៅឆ្នាំ១៩៤៩ ក្នុងភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានប្ដីឈ្មោះ ជីម ជឿន និងមានកូនចំនួន៧នាក់ គឺស្រី៤នាក់ និងប្រុស៣នាក់។ សព្វថ្ងៃនេះ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ ឈុន ជា និងម្ដាយឈ្មោះ សៀង ផាប។ ខ្ញុំមានបងប្អូនប្រុសស្រីសរុបចំនួន៥នាក់។

កាលនៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាមហាលាភ រហូតថ្នាក់ទី៧ចាស់។ ដោយសារតែជីវភាពគ្រួសារលំបាកពេក ខ្ញុំសុំឪពុកម្ដាយឈប់រៀនដើម្បីមកជួយធ្វើការងារផ្ទះ និងស្រែចម្ការវិញ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានរៀបការ និងផ្លាស់ទៅរស់នៅជាមួយឪពុកម្ដាយក្មេក។ ខ្ញុំ និងប្ដីប្រកបរបរធ្វើស្រែចម្ការ។ រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏មានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ និងមានបាតុកម្មនៅតាមផ្លូវដើម្បីប្រឆាំងនឹង លន់ នល់។ នៅពេលនោះ ប្ដីរបស់ខ្ញុំបានចូលរួមបាតុកម្មជាមួយអ្នកភូមិផ្សេងទៀត និងបានដង្ហែរក្បួនទៅដល់ទីរួមខេត្តកំពង់ចាម។ នៅពេលល្ងាច ប្ដីរបស់ខ្ញុំបានវិលត្រឡប់មកផ្ទះវិញ និងបានប្រាប់ខ្ញុំថា ទាហាន លន់ នល់ បានបាញ់បង្ក្រាបបាតុករ។ ចំណែកប្អូនប្រុសរបស់លោក លន់ នល់ គឺឈ្មោះ លន់ និល និងប្រពន្ធដែលធ្វើការនៅចម្ការកៅស៊ូ ខាងជប់ ត្រូវបានបាតុករសម្លាប់ដោយអារក និងវះពោះនៅមុំផ្លូវលំទទឹង។

នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហម បានចូលមកដល់ក្នុងភូមិមហាលាភ និងបានស្នាក់នៅក្រោមផ្ទះប្រជាជនៗ កងទ័ពរំដោះខ្មែរក្រហមស្លៀកខោខ្មៅអាវខ្មៅ និងចេញចូលភូមិជាប្រចាំ។ ខ្ញុំដឹងថា កងទ័ពរំដោះខ្មែរក្រហម ត្រូវបានបញ្ជូនទៅត្រៀមឈរជើងនៅម្តុំកោះចិន និងកំពង់រាប ដើម្បីស្ទាក់បាញ់ម៉ារីនរបស់ទាហាន លន់ នល់ ដែលដឹកស្បៀង និងអាវុធយុទ្ធភ័ណ្ឌពីទីក្រុងភ្នំពេញទៅ ទីរួមខេត្តកំពង់ចាម។ ចន្លោះពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៣ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បានផ្ទុះឡើងកាន់តែខ្លាំង។ នៅពេលនោះមានការទម្លាក់គ្រាប់បែកជាច្រើននៅលើភូមិសាស្ត្រឃុំមហាលាភ។ ខ្ញុំនៅចាំថា នៅមុនពេលទម្លាក់គ្រាប់បែកម្តងៗ មានយន្តហោះ (ប្រជាជនទូទៅហៅថា អាចានស្រាក់) ហោះមកឆ្វែលចុះឆ្វែលឡើងដើម្បីស៊ើបយកការណ៍អំពីទីតាំងរបស់ខ្មែរក្រហម។ បន្តិចក្រោយមក យន្តហោះស្ទាបកាត់បានហោះមកទម្លាក់គ្រាប់បែក ដែលបណ្តាលឲ្យប្រជាជនក្នុងភូមិស្លាប់ និងរងរបួសជាច្រើន ចំណែកផ្ទះសម្បែងត្រូវខ្ទេចខ្ទី។

នៅឆ្នាំ១៩៧៤ ខ្ញុំកើតបានកូនប្រុសម្នាក់។ បន្ទាប់ពីកើតកូនរួច ខ្ញុំបានស្នាក់នៅផ្ទះរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៥ ទើបខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅរែកដីនៅតាមការដ្ឋានក្នុងភូមិ។ អ្នកភូមិខ្លះដកស្ទូង អ្នកខ្លះរែកដី និងខ្លះទៀតជីកប្រឡាយ ប៉ុន្តែខ្មែរក្រហមមិនទាន់ចាត់តាំងឲ្យប្រជាជនទៅធ្វើការនៅកងចល័តឆ្ងាយពីភូមិឡើយ។ នៅចុងឆ្នាំ១៩៧៦ ខ្ញុំឃើញមានអ្នកភូមិជាច្រើនគ្រួសារត្រូវបានចល័តទៅធ្វើការងារនៅតាមការដ្ឋានក្នុងខេត្តកំពង់ធំ។ នៅឆ្នាំ១៩៧៧ កម្មាភិបាល និងយោធាខ្មែរក្រហមនៅភូមិភាគនិរតីបានចូលមកភូមិមហាលាភ។ នៅពេលនោះ គ្រួសារអ្នកភូមិជាច្រើន រួមទាំងគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ធំ។ គ្រួសារខ្ញុំបានដើរពីភូមិមហាលាភទៅដេកនៅទន្លេបិទមួយយប់។ នៅពេលព្រឹក គ្រួសារខ្ញុំឆ្លងស្រឡាងទៅជ្រោយថ្មី និងជិះគោយន្តបន្តទៅវត្តតាំងក្រសាំង។ នៅថ្ងៃបន្ទាប់ ខ្ញុំនិងគ្រួសារបានបន្តដំណើរដោយថ្មើរជើងទៅភូមិសំបូរ ក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ និងបានធ្វើការនៅការដ្ឋាននោះរយៈពេល ២៧ថ្ងៃ។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានរំសាយប្រជាជនពីការដ្ឋានការងារ និងបានរត់ភៀសខ្លួនចូលព្រៃ ព្រោះកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមក។ ខ្ញុំ និងគ្រួសារមិនបានរត់ទៅតាមខ្មែរក្រហមឡើយ។ ខ្ញុំសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំនិងគ្រួសារបានរួចផុតពីសេចក្តីស្លាប់ ចំណែកគ្រួសារជាច្រើនទៀតនៅក្នុងភូមិបានបាត់សមាជិកគ្រួសាររហូតមកដល់សព្វថ្ងៃនេះ។

## ២) នួន រឿន អតីតយុទ្ធជនខ្មែរក្រហម



នួន រឿន អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

នួន រឿន ភេទប្រុស អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានរំឭកអំពីមូលហេតុចូលរួមជាមួយកងទ័ព និងជីវិតរស់នៅក្នុងកងចល័តក្នុងរបបខ្មែរក្រហមថា ខ្ញុំឈ្មោះ នួន រឿន កើតនៅឆ្នាំ១៩៤៧ នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

ខ្ញុំរៀបការជាមួយប្រពន្ធឈ្មោះ ម៉េង ហ៊ាង និងមានកូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំប្រកបរបរជាកសិករ។ ឪពុករបស់ខ្ញុំឈ្មោះ សួង នួន និងម្តាយឈ្មោះ អ៊ុង ឈឹម។ ខ្ញុំគឺជាកូនទី៣ ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន ១០នាក់។ នៅពេលដែលខ្ញុំមានអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅសាលាបឋមសិក្សានាងអង។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ចាស់។ ក្រោយមកទៀត ខ្ញុំបានបួសរៀននៅវត្តព្រះគ្រូ អ៊ុក បាន ៤ព្រះវស្សា។ ខ្ញុំលាចាកសិក្ខាបទនៅអាយុ១៦ឆ្នាំ។ ខ្ញុំទៅរៀនធ្វើជាងមាសនៅភ្នំពេញ ដោយបានស្នាក់នៅម្តុំផ្សារអូ ឡាំពិក រហូតដល់ឆ្នាំ១៩៦៨។

នៅឆ្នាំ១៩៦៩ ខ្ញុំបានវិលត្រឡប់មកស្រុកវិញ និងបើកមុខរបរធ្វើជាជាងមាសនៅផ្ទះតែម្តង។ ខ្ញុំធ្វើមាសយកទៅលក់នៅទីរួមខេត្តកំពង់ចាម ដើម្បីសម្រួលដល់ជីវភាពគ្រួសារ។ នៅឆ្នាំ១៩៧០ ខ្ញុំឃើញអ្នកភូមិជាច្រើនបានចូលរួមធ្វើបាតុកម្មដង្ហែរតាមដងផ្លូវមកពីទិសខាងលិច។ នៅពេលនោះ ខ្ញុំក៏បានចូលរួមដង្ហែរក្បួនជាមួយបាតុករទៅដល់សាលាដំបូងខេត្តកំពង់ចាមដែរ។ នៅពេលទៅដល់ទីកន្លែងប្រមូលផ្តុំ ខ្ញុំមិនបានឡើងជិះឡានដង្ហែរបន្តទៅភ្នំពេញទេ។ ខ្ញុំសម្រេចចិត្តវិលត្រឡប់មកផ្ទះវិញ។

នៅឆ្នាំ១៩៧០ ដដែល រដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ បានកែនយុវជនឲ្យចូលបម្រើកងទ័ព។ ដោយសារខ្ញុំមិនចង់ចូលកងទ័ព ទើបខ្ញុំរត់ចេញពីភូមិទៅនៅស្រុកកោះសូទិន។ ខ្ញុំស្នាក់នៅពកស្នែងជាមួយបងប្អូនរបស់ខ្ញុំ។ មិនទាន់បានប៉ុន្មានផង ខ្ញុំឃើញកងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិ។ ខ្ញុំត្រូវបានបញ្ចុះបញ្ចូលឲ្យស្ម័គ្រចិត្តធ្វើជាកងទ័ពរំដោះខ្មែរក្រហម។ ដោយមិនមានជម្រើស និងមិនអាចរត់មកភូមិកំណើត ដែលមានវត្តមានទាហាន លន់ នល់ ខ្ញុំក៏បានសម្រេចចិត្តចូលបម្រើកងទ័ពរំដោះខ្មែរក្រហមនៅទីនោះ។ នៅពេលនោះ មានយុវជនប្រហែល១០០នាក់រួមទាំងរូបខ្ញុំផ្ទាល់ ត្រូវបានបញ្ជូនទៅខាងជីហែ ដែលជាតំបន់រំដោះខ្មែរក្រហម។ បន្ទាប់មក យុវជនទាំងនេះត្រូវបានប្រគល់ឲ្យកងកម្លាំងវៀតកុងដើម្បីបង្ហាត់បង្រៀនពីក្បួនទ័ព នៅខេត្តព្រៃវែង។

នៅឆ្នាំ១៩៧២ ខ្ញុំត្រូវបានបញ្ជូនទៅហ្វឹកហ្វឺនក្បួនទ័ពនៅភូមិផ្អែកកូន ឃុំជាខ្លាង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ ខ្ញុំរៀនពីវិធីប្រយុទ្ធ, ទប់ទល់, ប្រដេញ និងប្រើប្រាស់កាំភ្លើងគ្រប់ប្រភេទ។ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានបញ្ជូនទៅប្រយុទ្ធនៅសមរភូមិកំពង់ត្របែក និងនៅសមរភូមិផ្សេងៗទៀត។

នៅឆ្នាំ១៩៧៥ ខ្ញុំបានសុំឈប់ធ្វើជាកងទ័ពដើម្បីមកមើលថែម្តាយនៅភូមិវិញ។ បន្ទាប់ពីមកដល់ភូមិវិញ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅការដ្ឋានភូមិកៀនជ្រៃ ឃុំកៀនជ្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧៦ ខ្ញុំរៀបការប្រពន្ធ និងធ្វើការនៅកងចល័តក្នុងសហករណ៍គគរ។ ខ្ញុំគឺជាប្រធានកង និងមិត្តនារី សៅ គឺជាអនុប្រធានកង។

នៅឆ្នាំ១៩៧៧ កម្មាភិបាលនិងយោធាខ្មែរក្រហមភូមិភាគនិរតីបានចូលមកគ្រប់គ្រង ឃុំគគរ។ ពេលនោះ ខ្ញុំស្នើសុំឲ្យមិត្តនារី សៅ ឡើងធ្វើជាប្រធានជំនួសខ្ញុំ ព្រោះខ្ញុំត្រូវទៅធ្វើជាប្រធានកងចល័តវ័យកណ្តាល ដោយមើលលើការងាររក្សូវរាស់, ដាំពោត និងដំណាំផ្សេងៗដើម្បីផ្គត់ផ្គង់មូលដ្ឋាន។ បើទោះបីជាទទួលផលបានច្រើនយ៉ាងណាក៏ដោយ ក៏ប្រជាជនរួមទាំងខ្ញុំមិនមានអាហារហូបចុកគ្រប់គ្រាន់ដែរ។ នៅពេលនោះ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី បានចាប់អ្នកភូមិ ជនជាតិភាគតិចចាម និងកម្មាភិបាលខ្មែរក្រហមនៅក្នុងមូលដ្ឋានយកទៅសម្លាប់អស់ជាច្រើននាក់។

នៅឆ្នាំ១៩៧៨ ប្រពន្ធរបស់ខ្ញុំបង្កើតបានកូនម្នាក់។ ខ្ញុំព្យាយាមលួចដីកដំឡូងយកមកស្ងោរឲ្យប្រពន្ធហូប។ ប៉ុន្តែថ្ងៃមួយ កងឈ្លបបានឃើញ និងចាប់ខ្ញុំយកទៅសួរចម្លើយ។ ខ្ញុំឆ្លើយកុហកថា ខ្ញុំជីកដំឡូងព្រៃមិនមែនដំឡូងដែលប្រជាជនដាំទេ។ បន្ទាប់មកខ្ញុំត្រូវបានដោះលែងវិញ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងប្រពន្ធកូនបានរួចផុត

ពីសេចក្តីអត់ឃ្លាន និងស្លាប់ ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមក។ ខ្ញុំនិងគ្រួសារបានជួបជុំគ្នាវិញ និងបានប្រកបរបរជាកសិកររហូតមកដល់សព្វថ្ងៃនេះ។

## ៣) សេង អួន អតីតពេទ្យខ្មែរក្រហម



សេង អួន កើតនៅឆ្នាំ១៩៥០ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅក្នុងភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

សេង អួន ភេទស្រី កើតនៅឆ្នាំ១៩៥០ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅក្នុងភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម បានរៀបរាប់ថា កាលនៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាកណ្តាលកោះ។ ខ្ញុំរៀនត្រឹមថ្នាក់ទី៧ចាស់ ក៏ឈប់រៀនព្រោះតែប្រឡងធ្លាក់។

ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏មានបាតុកម្មកើតឡើង ដើម្បីទាមទារយកសម្តេចមកកាន់អំណាចវិញ។ នៅឆ្នាំ១៩៧១ ខ្ញុំនៅជួយធ្វើការឪពុកម្តាយនៅផ្ទះ ហើយពេលនោះ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ក៏បានផ្ទុះឡើងជាបណ្តើរៗដែរ។ នៅឆ្នាំ១៩៧២ ខ្ញុំស្ម័គ្រចិត្តចូលធ្វើពេទ្យកងទ័ព។ ខ្ញុំទៅរៀនពេទ្យនៅស្រុកល្វាឯម ខេត្តកណ្តាល បានរយៈពេល៤ខែ។ បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅតាមកងទ័ពរំដោះខ្មែរក្រហមដែលឡើងទៅវាយនៅលើសមរភូមិ។ ពេលខ្លះ ខ្ញុំប្រមូលបានសម្ភារយោធារបស់អាមេរិកាំងដែលបន្សល់ទុកនៅបន្ទាយរបស់ លន់ នល់។ ខ្ញុំធ្លាប់រើសបានកាតាបទាហានអាមេរិកកាំង និងយកមកដាក់ថ្នាំពេទ្យ។

នៅឆ្នាំ១៩៧៥ ខ្ញុំលែងទៅតាមកងទ័ពខ្មែរក្រហមដែលឡើងទៅវាយនៅលើសមរភូមិ ទៀតហើយ។ ខ្ញុំព្យាបាលអ្នកជំងឺ ដែលដកស្ទូង, រែកដី, ជីកប្រឡាយ នៅតាមការដ្ឋាន។ នៅឆ្នាំ១៩៧៦ ខ្ញុំទៅព្យាបាលកងចល័តនៅស្រុកពារាំង ខេត្តព្រៃវែង ហើយទំនេរពីការងារខ្ញុំជួយធ្វើពាងទឹក។ នៅចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ មានការចាប់កម្មាភិបាល និងប្រជាជនយកទៅសម្លាប់ជាច្រើន។ នៅក្នុងហេតុការណ៍នោះ ប្រធានពេទ្យរបស់ខ្ញុំក៏ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងយកទៅសម្លាប់ដែរ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានរៀបការប្តីឈ្មោះ ដៃ គឺជាយោធាតំបន់។ នៅដើមឆ្នាំ១៩៧៩ ពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំនិងប្តីបានវិលត្រឡប់មកភូមិកំណើតវិញ។ បច្ចុប្បន្ន ខ្ញុំមានកូនប្រុសស្រីចំនួន៤នាក់។

## ៤) សាត់ សំអឿន អតីតកងចល័តនារី



សាត់ សំអឿន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិមហាលាភជើង ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

សាត់ សំអឿន ភេទស្រី គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិមហាលាភជើង ឃុំកោះសូទិន បានរំឭកអំពីរឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមថា ខ្ញុំឈ្មោះ សាត់ សំអឿន កើតនៅឆ្នាំ១៩៦២ នៅភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ សៀង សំនាង និងមានកូនប្រុស៣នាក់ និងស្រី២នាក់។ ឪពុករបស់ខ្ញុំឈ្មោះ សាត់ ភួង និងម្តាយឈ្មោះ ជឹម ឈន់។ ខ្ញុំមានបងប្អូនសរុបចំនួន២នាក់។

កាលនៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាមហាលាភ ដល់ថ្នាក់ទី៩ចាស់។ នៅឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀន ហើយមកជួយធ្វើការងារឪពុកម្តាយ ហើយនៅពេលនោះក៏មានបាតុកម្មកើតឡើងដែរ។ នៅឆ្នាំ១៩៧១ ខ្ញុំឃើញមានវត្តមានកងទ័ពរំដោះខ្មែរក្រហមចូលមក ក្នុងភូមិ និងសុំអ្នកភូមិស្នាក់នៅក្រោមផ្ទះ។ កងទ័ពរំដោះខ្មែរក្រហមទាំងនោះត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅតាមបណ្តោយទន្លេមេគង្គដើម្បីត្រៀមវាយប្រហារទៅលើទាហានលន់នល់។ នៅឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកខ្លាំងណាស់លើភូមិមហាលាភ ពីសំណាក់កងទ័ពលន់ នល់ ដែលបានបណ្តាលឲ្យឪពុករបស់ខ្ញុំស្លាប់បាត់បង់ជីវិត។ ខ្ញុំចាំបានថា ក្នុងពេលទម្លាក់គ្រាប់បែកនោះ ឪពុករបស់ខ្ញុំបានយកកង់ទៅប៉ះនៅផ្សារមហាលាភ។ នៅមុនពេលទម្លាក់គ្រាប់បែកគឺមានយន្តហោះ ហោះអ្នែលចុះឡើងដើម្បីស៊ើបយកការណ៍ ហើយបន្តិចក្រោយមកក៏មានយន្តហោះផ្សេងទៀតមកទម្លាក់គ្រាប់បែកតែម្តង។

ឪពុករបស់ខ្ញុំរត់ចូលក្នុងរណ្តៅត្រង់សេជាមួយគ្រួសារមួយ ដែលមានកូនស្រីប្រុស។ ឪពុករបស់ខ្ញុំឃើញយន្តហោះទម្លាក់គ្រាប់សំដៅមកចំមាត់រណ្តៅ។ គាត់ភ័យខ្លាំងពេក ក៏បានលោតចេញពីរណ្តៅ ហើយត្រូវអំបែងគ្រាប់បែក។ ឪពុករបស់ខ្ញុំបានប៉ើងធ្លាក់ចូលទៅក្នុងទឹកក្បែរនោះ។ រយៈពេលពីរថ្ងៃក្រោយមកទើបសាកសពឪពុករបស់ខ្ញុំអណ្តែតឡើង។ ម្តាយរបស់ខ្ញុំ និងបងប្អូនរបស់ខ្ញុំ បានយកសាកសពឪពុករបស់ខ្ញុំមកធ្វើបុណ្យតាមប្រពៃណីសាសនា។ ចាប់ពីពេលនោះមក រាល់ពេលមានការទម្លាក់គ្រាប់បែកម្តងៗ ខ្ញុំនាំប្អូនៗរត់ចូលត្រង់សេលាក់ខ្លួន។

នៅឆ្នាំ១៩៧៥ ខ្ញុំបែកចេញពីគ្រួសារទៅចូលក្នុងកងយុវនារីដែលមានសមាជិក១៥នាក់។ មិត្តនារី សុភាព គឺជាប្រធានកង និងមិត្ត ហុត គឺជាអនុប្រធាន។ កងយុវនារីត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានស្វាយទាប ក្នុងខេត្តព្រៃវែង។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានប្រធានកងបញ្ជូនឲ្យមកធ្វើការនៅកងចល័តនារីក្នុងភូមិវិញ។ ខ្ញុំធ្វើការងារដកស្ទូង ដោយចាប់ផ្តើមពីម៉ោង៧ព្រឹក ដល់ម៉ោង១១ថ្ងៃត្រង់ និងពីម៉ោង១ ដល់ម៉ោង៥រសៀល។ នៅពេលយប់ ខ្ញុំចូលរួមប្រជុំអំពីផែនការទៀត។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យទៅជីកប្រឡាយនៅត្រពាំងទា។ នៅឆ្នាំ១៩៧៨ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ធំ។ នៅពេលដែលកងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរំលំរបបខ្មែរក្រហម ខ្ញុំនិងគ្រួសារបានវិលត្រឡប់មកភូមិកំណើតវិញ។



បុរសកំពុងវាយមងនៅទន្លេមេគង្គ ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាប្រវត្តិសាស្ត្រគ្រួសារ

## កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

***មេក ទិន, ហ៊ាន ពិសី, សួត វិចិត្រ***

ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាប្រវត្តិសាស្ត្រគ្រួសារនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ក្រុមការងារបានចំណាយរយៈពេលចំនួន៣ថ្ងៃធ្វើការសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំផ្អាវ ហើយខាងក្រោមគឺជារឿងរ៉ាវសង្ខេបរបស់គាត់៖

### ***១) យុន វី៖ អតីតនីរសារ***



យុន វី អាយុ៦១ឆ្នាំ រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុន វី ភេទប្រុស អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិសុជល់ ឃុំដាន់ញើម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។ បច្ចុប្បន្ន យុន វី រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ យុន វី បានចែករំលែកបទពិសោធន៍របស់ខ្លួនថា នៅអាយុប្រហែល១៥ឆ្នាំ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាកងចល័ត។ ឈ្មោះ ចូន និង គាំ ដែលមកពីភូមិភាគបូព៌ាគឺជាប្រធានកងរបស់យើង។ យើងត្រូវដាក់ឲ្យរស់នៅជាក្រុម និងហូបបាយរួមគ្នាក្នុងរោងបាយតែមួយ។ ខ្មែរក្រហមឲ្យយើងទប់ទំនប់នៅបារាយណ៍ប្រាសាទធំ, ទំនប់ជិតប្រាសាទសោភី និងទំនប់ជាច្រើនទៀតនៅក្នុងខេត្តកំពង់ធំ។ ជាទូទៅយើងត្រូវចំណាយពេលធ្វើការមួយវស្សាប្លើសនេះទៅតាមទំនប់តូចនិងធំ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៨ ខ្មែរក្រហមផ្លាស់ខ្ញុំឲ្យទៅធ្វើជានីរសារឲ្យ ចូន និង គាំ វិញ។ កាលណោះយើងប្រើសេះសម្រាប់ជិះរត់សំបុត្រ ហើយអ្វីដែលជាឧបសគ្គក្នុងពេលរត់សំបុត្រ គឺជួបសត្វខ្លា ដូច្នេះធ្វើឲ្យសេះមិនហ៊ានបោលទៅមុខ។ ភាគច្រើនខ្ញុំមិនដែលបានដឹងអំពីខ្លឹមសារនៅក្នុងសំបុត្រនោះទេ ខ្ញុំដឹងតែអង្គការប្រើឲ្យទៅគឺខ្ញុំទៅតែម្ដង។

លុះដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមកយើងបែកខ្ញែកគ្នា។ ខ្ញុំរត់ត្រឡប់មកភូមិជួបឪពុកម្ដាយខ្ញុំវិញ។ ក្រោយមកខ្ញុំត្រូវបានជ្រើសរើសឲ្យចូលធ្វើជាកងជីវពលនៅកងវរៈ ២។ មិនបានប៉ុន្មានខ្ញុំក៏សុំឈប់ ហើយមករស់នៅជាប្រជាពលរដ្ឋធម្មតាវិញ។ នៅក្នុងភូមិរបស់ខ្ញុំអំឡុងពេលនោះគឺមានភាពអសន្តិសុខ។ ក្រោយមក ខ្ញុំចូលធ្វើជាយោធាខាងខ្មែរក្រហមក្នុងកងពល៩១៦ ដែលមានទីតាំងនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ បន្ទាប់មកខ្មែរក្រហមបានឲ្យខ្ញុំទៅសមរភូមិមុខប្រយុទ្ធជាមួយ

កងទ័ពវៀតណាម នៅខេត្តកំពង់ធំៗ គោលការណ៍របស់ខ្មែរក្រហមនៅពេលនោះ ប្រសិនបើយើងវាយប៉ះចំខ្មែរដូចគ្នា យើងនឹងនិយាយបញ្ចុះបញ្ចូលធ្វើយ៉ាងណាឲ្យចូលមករួមតស៊ូជាមួយយើង ប៉ុន្តែប្រសិនបើមិនចង់ចូលរួមជាមួយយើងទេ យើងក៏មិនបង្ខំដែរ គឺយើងដោះលែងឲ្យត្រឡប់ទៅវិញ។ យើងគិតថា ដោយសារយើងជាខ្មែរតែមួយ។ ប្រសិនបើវាយប៉ះកងទ័ពវៀតណាម គឺខាងខ្មែរក្រហមមិនទុកឲ្យរស់ឡើយ គឺសម្លាប់ចោលតែម្តង។ នៅឆ្នាំ១៩៨៩ ខ្ញុំបានរៀបការប្រពន្ធ។ បន្ទាប់ពីរៀបការរួច ខ្ញុំត្រូវបានបញ្ជូនឲ្យទៅសមរភូមិមុខរយៈពេល៦ខែ ទើបត្រឡប់មកលេងប្រពន្ធកូនវិញ។ ខ្ញុំនៅតស៊ូជាមួយខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៨។ នៅពេលដែលប្រទេសមានសុខសន្តិភាព ខ្ញុំបានជួបជុំគ្រួសារវិញ និងបានសម្រេចចិត្តរស់នៅក្នុងឃុំផ្អាវនេះរហូតមកដល់ពេលបច្ចុប្បន្ន។

## ២) លេន ផុន ៖ យុទ្ធនារីខ្មែរក្រហម



លេន ផុន អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លេន ផុន ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិចំបក់ ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ បច្ចុប្បន្ន លេន ផុន រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

លេន ផុន បានរៀបរាប់ថា នៅអាយុ១៣ឆ្នាំ ខ្ញុំត្រូវបង្ខំឲ្យចូលសម្តែងសិល្បៈ ចំណែកម្តាយ និងឪពុកខ្ញុំមិនហ៊ានប្រកែកឡើយ។ ក្រោយពីហ្វឹកហាត់សិល្បៈ ខ្ញុំត្រូវបញ្ជូនឲ្យទៅដឹកប្រឡាយនៅស្ទឹងជីនិត។ នៅទីនោះមានមនុស្សរាប់ពាន់នាក់ធ្វើការងារដឹកប្រឡាយ។ ខ្ញុំធ្វើកិច្ចការងារនេះបានរយៈពេលចំនួន២ខែ។ ក្រោយមក ប្រធានកងផ្លាស់ខ្ញុំឲ្យធ្វើជាកងទ័ពដើម្បីចូលរួមក្នុងយុទ្ធនាការវាយភ្នំស្រី និងភ្នំប្រុស។ ខ្មែរក្រហមឲ្យយើងឆ្លាស់គ្នាទៅនៅតាមខ្សែត្រៀមម្នាក់រយៈពេលបីយប់បីថ្ងៃ បើរួចផុតបីថ្ងៃប្រធានកងនឹងប្តូរអ្នកថ្មីឲ្យទៅម្តង។ ខ្មែរក្រហមបញ្ជូនឲ្យខ្ញុំទៅសមរភូមិមុខទាំងខ្ញុំមិនធ្លាប់បានហ្វឹកហាត់អ្វីសោះពីមុនមក។ ខ្ញុំពិតជាភ័យខ្លាចណាស់។ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីលាក់ខ្លួនក្នុងលេណដ្ឋាន ធ្វើយ៉ាងណាឲ្យតែរួចជីវិតប៉ុណ្ណោះ។ ក្រោយវាយយកបានភ្នំស្រី ភ្នំប្រុស ទើបខ្មែរក្រហមឲ្យខ្ញុំទៅហាត់រៀនបាញ់កាំភ្លើង។

លុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលយោធាខ្មែរក្រហមវាយយកបានភ្នំពេញភ្លាម ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅភ្នំពេញដោយមានយាយ ថាន គឺជាអ្នកដឹកនាំ។ ខ្ញុំមកបោសសម្អាតនៅទួលគោកបានរយៈពេលបីថ្ងៃប៉ុណ្ណោះ ទើបខ្មែរក្រហមផ្លាស់ឲ្យខ្ញុំនិងក្រុមទ័ពស្រួចទៅឈរជើងនៅស្រុកជើងព្រៃរយៈពេល៤ថ្ងៃទៀត។ ដោយសារពេលនោះស្ងប់ស្ងាត់សង្គ្រាមហើយ ទើបខ្មែរក្រហមបញ្ជូនយើងឲ្យទៅមណ្ឌលគិរី។ នៅទីនោះយើងលែងកាន់កាំភ្លើងត្រៀមអ្វីទៀតហើយ គឺយើងចាប់ផ្តើមធ្វើស្រែចម្ការសម្រាប់ផ្គត់ផ្គង់នៅក្នុងអង្គភាព។ ទីនោះ យើងទទួលបានការហូបចុកគ្រប់គ្រាន់ គឺហូបបាយបីពេល រួមទាំងបន្ថែមទៀត។ ខ្មែរក្រហមចែកខោអាវឲ្យយើងមួយឆ្នាំពីរសម្រាប់គឺខោខ្មៅ និងអាវខ្មៅ។ ជារឿយៗនៅពេលយប់ យើងតែងតែប្រជុំគ្នា អំពីការងារ និងការគោរពវិន័យ ទាំង១២ប្រការ។ វិន័យ១២ប្រការនោះ គឺអប់រំឲ្យយើងចេះសាមគ្គីភាព មិនប្រកាន់វណ្ណៈ រស់នៅចេះយោគយល់គ្នា មិនមានទំនាស់ទាស់ទែងឬគុំកួនគ្នា និងអប់រំយើងឲ្យមានឥរិយាបថល្អ។



ដំ ឡឿន អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានរត់គេចខ្លួនទៅភូមិភាគឧត្តរ។ ពេលនោះ ខ្ញុំរស់នៅដោយខ្លួនត្រូវទីពឹងខ្លួនឯង។ ប្រសិនបើខ្ញុំមានកម្លាំងបន្តដំណើរទៅមុខគឺរស់ ប៉ុន្តែបើខ្ញុំគ្មានកម្លាំងដើរទេ គឺស្លាប់នៅក្នុងព្រៃ។ ខ្ញុំពុំមានស្បៀងអាហារហូបគ្រប់គ្រាន់ទេ ដូច្នេះខ្ញុំត្រូវជីកមើមដំឡូង ឬមើមក្ដួចយកមកហូបជំនួសបាយ។ ខ្ញុំនិងប្រជាជនផ្សេងទៀតបានចំណាយពេលមួយឆ្នាំពេញទើបដើរដល់ភ្នំ១០០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តា០៦។

នៅឆ្នាំ១៩៩២ យើងត្រូវបានជម្លៀសចេញពីភ្នំ១០០១ទៅកាន់ភ្នំ១០០៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក វិញ។ នៅទីនោះខ្ញុំមិនធ្វើកិច្ចការផ្សាររអ៊ីទេ ដោយសារពេលនោះខ្ញុំមានកូន។ ខ្ញុំនៅតែមើលថែកូនតូចៗនៅផ្ទះ។ ខ្ញុំរស់នៅភ្នំ១០០៣បានរយៈពេល២ឆ្នាំ។ ក្រោយមក នៅឆ្នាំ១៩៩៣ ទើបខ្ញុំនិងប្រជាជនដែលមកពីភ្នំ ១០០១ ទាំងអស់បានចុះមករស់នៅស្ពានអូរជីក ក្រោមការមើលការខុសត្រូវរបស់តា០៦ដដែល។ មកដល់ស្ពានអូរជីកដំបូង ប្រជាជនជាច្រើនបានស្លាប់ដោយសារចាញ់ទឹកចាញ់ដី និងមូសខាំ។ យើងមិនមានថ្នាំពេទ្យសម្រាប់ព្យាបាលឡើយ។ នៅឆ្នាំ១៩៩៧ តា០៦ លែងគ្រប់គ្រងយើងដូចមុនទៀតហើយ ដូច្នេះប្រជាជនបានជួបប្រទះនូវការខ្វះខាតគ្រប់សព្វបែបយ៉ាង។

## ៣) ដំ ឡឿន ៖ យោធាខ្មែរក្រហម

ដំ ឡឿន ភេទប្រុស អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ដំ ឡឿន រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ឡឿន បានចែករំលែកពីបទពិសោធន៍កាលនៅជាកងទ័ពថា៖

«នៅឆ្នាំ១៩៧២ ខ្ញុំចាកចេញពីផ្ទះចូលមកធ្វើជាកងរំដោះ និងតស៊ូជាមួយខ្មែរក្រហមរហូតមក ដោយសារកាលនោះមានការឃោសនាឲ្យចូលរួមតស៊ូដើម្បីទាមទារអំណាចជូនសម្ដេចឪវិញ។ មុនដំបូងខ្មែរក្រហមបានរៀបចំជាអង្គភាពទ័ពដោយពេលនោះខ្ញុំនៅក្នុងកងវរ ១៦ គ្រប់គ្រងដោយ កែ ពក ។ ជំនាន់នោះមិនមានការការហ្វឹកហ្វឺនទ័ពទេ គឺខ្ញុំអនុវត្តផ្ទាល់តែម្ដង គឺឲ្យតែមានកម្លាំងច្រើន គឺខ្មែរក្រហមបញ្ជូនទៅវាយជាមួយ លន់ នល់ តែម្ដង។ ប្រសិនបើនរណាដែលឆ្លាត ហើយរហ័សគឺនៅមានជីវិតរស់។ នៅក្នុងសម័យសង្គ្រាម ខ្ញុំជួបការលំបាកខ្លាំង ព្រោះខោអាវមានតែមួយសម្រាប់នៅជាប់នឹងខ្លួន ក្រៅពីនោះមានតែក្រមាម្នាក់មួយប៉ុណ្ណោះ។ ខ្ញុំទទួលបានកាំភ្លើងសេកាសេ ឬ កាប៊ីន មួយដើមពីអង្គភាពទ័ព នៅភូមិភាគឧត្តរ។ ដោយឡែក ភូមិភាគនិរតីទើបមានកាំភ្លើងអាកា (AK) ដែលនាំចូលមកពីចិនថ្មីៗសម្រាប់ប្រើប្រាស់។ ថ្វីត្បិតតែខាងភូមិភាគឧត្តរមិនមានអាវុធទំនើបប្រើយ៉ាងណាក្តី ប៉ុន្តែខាងឧត្តរគឺមានភាពសាមគ្គីគ្នានៅពេលធ្វើសង្គ្រាមម្ដងៗ។

អង្គភាពទ័ពនៅភូមិភាគឧត្តរបានឡើងទៅវាយប្រយុទ្ធនៅជ្រោយចង្វារ ចំណែកកងកម្លាំងភូមិភាគនិរតីមិនបានចូលរួមប្រយុទ្ធទេ និងសូម្បីតែស្បៀងអាហារក៏មិនផ្តល់ឲ្យទ័ពនៅភូមិភាគឧត្តរដែរ ព្រោះចង់ដឹងកងកម្លាំងរបស់ភូមិភាគឧត្តរអាចវាយឈ្នះកងទ័ព លន់ នល់ ដែរឬទេ។ ដោយសារតែពេលនោះ

ស្ថានការណ៍បន្ទាន់ ដូច្នេះយើងមិនបានត្រៀមស្បៀងអាហារសម្រាប់ផ្គត់ផ្គង់កងទ័ពឡើយ ក្រៅពីហូបគ្រាប់ឈូកៗ យើងតស៊ូវាយប្រយុទ្ធរហូតទទួលបានជ័យជម្នះ ទើបមេដឹកនាំភូមិភាគនិរតីជឿជាក់ថាកងកម្លាំងខាងភូមិភាគឧត្តរមានសមត្ថភាព។

នៅឆ្នាំ១៩៧៣ អង្គភាពទ័ពរបស់ខ្ញុំឡើងទៅវាយនៅ ខេត្តកំពង់ចាមម្តង។ យុទ្ធសាស្ត្រនៃការធ្វើសង្គ្រាមរបស់កងកម្លាំងភូមិភាគឧត្តរតែងតែរៀបចំទុកជាមុន។ ប្រសិនបើខ្មែរក្រហមដាក់គោលដៅវាយបន្ទាយបន្ទាយ ទាហាន លន់ នល់ គឺកងកម្លាំងទ័ពខ្មែរក្រហមត្រូវស៊ើបការណ៍រយៈពេលមួយខែមុនចូលវាយ។ បន្ទាប់មកខាងខ្មែរក្រហមបានលួចដោះមីនដែលទាហាន លន់ នល់ បានដាក់ការពារបន្ទាយ។ ទម្រាំតែ ទាហាន លន់ នល់ ដឹងខ្លួនគឺខ្មែរក្រហមបានរៀបចំព័ទ្ធជុំវិញហើយ។ ចំពោះការដឹកលេណដ្ឋានគឺខ្មែរក្រហមដឹកដោយសម្ងាត់បំផុត ហើយយន្តហោះរបស់ លន់ នល់ មិនងាយសង្កេតឃើញឡើយ។ ទាំងនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងការធ្វើសង្គ្រាមរបស់ខ្មែរក្រហមនៅក្នុងការយកឈ្នះ ទាហាន លន់ នល់។ នៅឆ្នាំ១៩៧៣ វៀតណាមលែងមាននៅក្នុងប្រទេសកម្ពុជាហើយ។ ចាប់ពីឆ្នាំ១៩៧៤ ខ្មែរក្រហមវាយសម្រុកចូលទីក្រុងភ្នំពេញ ហើយខ្មែរក្រហមបានដឹងរួចជាស្រេចថានឹងទទួលបានជ័យជម្នះលើ លន់ នល់។

បន្ទាប់ពីទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមរៀបចំការដឹកនាំថ្មី និងបែងចែកកម្លាំងទៅប្រចាំការនៅតាមភូមិភាគនិងតំបន់។ ខ្ញុំនៅក្នុងកងពល៩២០ មកឈរជើងនៅទួលគោក ក្បែរអង់តែនទូរទស្សន៍។ បន្ទាប់មកខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយបានប្រកាសថា នរណាដែលធ្លាប់មានមុខតំណែងអ្វីក្នុងរាជការពីមុនមកគឺរក្សាបន្តតំណែងឲ្យនៅដដែល។ ខ្មែរក្រហមធ្វើដូច្នេះដើម្បីស្វែងរកអ្នកចេះដឹង មន្ត្រីរាជការដែលខ្មែរក្រហមបានចាត់ទុកជាសត្រូវ និងយកទៅសម្លាប់ចោល។

រយៈពេលមួយខែក្រោយមក ខ្ញុំត្រូវបានបញ្ជូនទៅមណ្ឌលគិរី។ ខ្ញុំបានបន្តវាយជាមួយកងទ័ពវៀតណាមដោយសារខ្មែរក្រហមចោទថាវៀតណាមមានបំណងចង់លេបត្របាក់យកទឹកដីខ្មែរ។ នៅពេលនោះក៏មានកងកម្លាំង ហ៊្វុលរ៉ូ (រណសិរ្សរួមជនជាតិភាគតិចរបស់ជនជាតិ៣ គឺ ជនជាតិចាម, ម៉ុងតាញ៉ា និងខ្មែរក្រោម) ចូលរួមតស៊ូជាមួយខ្មែរក្រហមដើម្បីទាមទារទឹកដីពីវៀតណាមមកវិញដែរ។

## ៤) ពេជ្រ អៀន ៖ អតីតយោធា



ពេជ្រ អៀន អាយុ៨៦ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេជ្រ អៀន ភេទប្រុស អាយុ៨៦ឆ្នាំ មានទីកន្លែងកំណើតនៅភូមិព្រៃដូង ឃុំព្រៃដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ពេជ្រ អៀន រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ពេជ្រ អៀន បានរៀបរាប់ដូចខាងក្រោមថា ៖

ខ្ញុំមានបងប្អូនចំនួន៥នាក់។ ឪពុកម្តាយរបស់ខ្ញុំគឺជាកសិករ ធ្វើស្រែនិងចម្ការ។ ខ្ញុំមិនបានរៀនសូត្រច្រើនទេ។ បន្ទាប់ពីលន់នល់ធ្វើរដ្ឋប្រហារ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ក៏មានសង្គ្រាមនិងមានការទម្លាក់គ្រាប់បែក ធ្វើឲ្យគ្រួសាររបស់ខ្ញុំនិងប្រជាជន នាំគ្នាលាក់ខ្លួន។ ក្រោយមក ក៏មានការប្រកាសឲ្យប្រជាជនចូលព្រៃម៉ាគីតស៊ូដើម្បីទាមទារ

អំណាចថ្វាយសម្តេចព្រះ នរោត្តម សីហនុ វិញ ។ ខ្ញុំស្ម័គ្រចូលរួមតស៊ូនៅក្នុងព្រៃជាមួយ នឹងកងទ័ពខ្មែរក្រហម ដោយសារតែស្រឡាញ់សម្តេចព្រះ នរោត្តម សីហនុ។ ពេលនោះលំបាកណាស់សម្រាប់ខ្ញុំព្រោះមិនមានអាហារហូបគ្រប់គ្រាន់។ ខ្ញុំត្រូវហូបមើមក្តួចបន្ថែម។ ខ្ញុំបានដឹកនាំកម្លាំង៣០នាក់ វាយប្រយុទ្ធនៅភាគខាងជើងស្រុកកំពង់ស្វាយ។ ក្រោយមក ខ្ញុំដឹកនាំកម្លាំងវាយបន្តផ្លោះទៅភ្នំពេញ។ អង្គភាពរបស់ខ្ញុំទទួលបានជ័យជម្នះជារឿយៗ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមកឈរជើងនៅម្តុំជ្រោយចង្វារ។ ចំណែកប្រជាជនត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ។ ខ្មែរក្រហមបានចាត់ឲ្យខ្ញុំនាំផ្លូវប្រជាជនជម្លៀសទៅខេត្តមណ្ឌលគិរី។ ប្រជាជនត្រូវធ្វើដំណើរកាត់តាមព្រែកក្តាម ដូច្នេះខ្ញុំនិងសមាជិកត្រូវកាប់ឬស្សីយកមកធ្វើជាក្បូនដើម្បីឲ្យប្រជាជនឆ្លងទន្លេ។ ទំរាំប្រជាជនឆ្លងទន្លេអស់គឺប្រើរយៈពេលបីយប់បីថ្ងៃ។ ដោយសារតែមនុស្សច្រើន យើងមិនអាចជួយចម្លងមកដល់ត្រើយដោយសុវត្ថិភាពទាំងអស់ទេ គឺមានប្រជាជនជាច្រើនបានលង់ទឹកស្លាប់។ នៅតាមផ្លូវធ្វើដំណើរពិបាករកទឹកដឹកខ្លាំងណាស់ ហើយប្រជាជនបានស្លាប់ជាបន្តបន្ទាប់ទៀត ដោយសារហេវហត់ និងអស់កម្លាំង។ លុះពេលទៅដល់មណ្ឌលគិរី ប្រជាជនត្រូវបែងចែកទៅធ្វើការងាររៀងៗខ្លួន។ ចំណែកខ្ញុំផ្លាស់មកឈរជើងការពារព្រំដែននៅស្រុកស្នួល ខេត្តក្រចេះវិញ។ ដោយសារតែសភាពការណ៍ស្ងប់ ខ្មែរក្រហមចាត់តាំងខ្ញុំនិងកងកម្លាំងនៅក្នុងអង្គភាពទ័ពធ្វើស្រែចម្ការ។ ខ្ញុំរស់នៅទីនោះរហូតដល់កងទ័ពវៀតណាមចូលមកនៅដើមឆ្នាំ១៩៧៩ ទើបខ្ញុំភៀសខ្លួនមកភ្នំដងរែក។ នៅពេលកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨ ខ្ញុំនិងគ្រួសារសម្រេចចិត្តមករស់នៅភូមិអូរជីករហូតមកដល់ពេលបច្ចុប្បន្ន។

## ៥) គឹម ប៉ាវ ៖ អតីតយោធា



គឹម ប៉ាវ អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គឹម ប៉ាវ ភេទប្រុស អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បច្ចុប្បន្ន គឹម ប៉ា រស់នៅ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ គឹម ប៉ាវ បានរៀបរាប់រឿងរ៉ាវរបស់គាត់នៅក្នុងសម័យខ្មែរក្រហមថា ៖

ឪពុកម្តាយរបស់ខ្ញុំគឺជាកសិករ។ ខ្ញុំរៀនសូត្រត្រឹមកម្រិតកុមារដ្ឋាន កាលពីជំនាន់សង្គមរាស្ត្រនិយម។ ក្រោយមកខ្ញុំក៏ឈប់រៀនដោយសារជីវភាពគ្រួសារខ្វះខាត ហើយត្រូវជួយឃ្វាលគោក្របីឪពុកម្តាយវិញ។ នៅពេលមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានរត់ចូលព្រៃដើម្បីតស៊ូជាមួយខ្មែរក្រហមដើម្បីទាមទារអំណាចថ្វាយព្រះអង្គវិញ។ ខ្ញុំបានចូលជាយោធាស្រុកក្រោមការគ្រប់គ្រងរបស់ តាជិន បន្ទាប់មកត្រូវបានផ្ទាក់លើបញ្ជូនទៅនៅ ភ្នំប្រុស-ភ្នំស្រី ខេត្តកំពង់ចាម។ នៅ ទីនោះ ខ្ញុំត្រូវហ្វឹកហាត់អំពីយុទ្ធសាស្ត្រកងទ័ព និងស្មារតីតស៊ូ។ ខ្មែរក្រហមបណ្តុះគំនិតខ្ញុំឲ្យផ្តួលរំលំរបបសក្តិភូមិ និងអ្នកជិះជាន់កេងប្រវ័ញ្ចលើអ្នកក្រ ហើយធ្វើយ៉ាងណាឲ្យប្រជាជនមានកំហឹងឈឺចាប់ និងចូលរួមចលនាខ្មែរក្រហមកាន់តែច្រើនថែមទៀត។

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ផ្តើមរៀបចំអង្គភាពចល័ត និងមានការបង្កើនចំនួនទ័ពប្រមាណជាង ៤០០ នាក់នៅក្នុងមួយកងវរសេនាតូចៗ យើងដើរធ្វើការចល័តរវាងខេត្តបាត់ដំបង និងកំពង់ឆ្នាំង។ អង្គភាពរបស់ខ្ញុំបានកំណត់គោលដៅប្រយុទ្ធជាមួយទាហាន លន់ នល់ នៅតាមមុខសញ្ញាឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសអំពីជ័យជម្នះទៅលើទាហាន លន់ នល់។ នៅពេលនោះ ខ្ញុំមានការត្រេកអរខ្លាំងណាស់ដោយយល់ថា យើងឈប់ច្បាំងគ្នា លែងមានរបួស ឬបាត់បង់ជីវិតប្រជាជនទៀតហើយ។ ខ្ញុំបានឈរជើងនៅម្តុំទួលគោក ហើយភ្លាមៗនោះ ស្រាប់តែខ្ញុំឃើញប្រជាជនត្រូវបានកងទ័ពជម្លៀសចេញពីទីក្រុងភ្នំពេញ។ ដំបូងខ្ញុំយល់ថា ការជម្លៀសប្រជាជនរបស់ខ្មែរក្រហមកាលជំនាន់នោះ គឺដើម្បីការពារអាយុជីវិតប្រជាជនពីការទម្លាក់គ្រាប់បែកតែប៉ុណ្ណោះ។ មេអង្គភាពរបស់ខ្ញុំ បានហាមដាច់ខាត មិនឲ្យខ្ញុំនិងសមាជិកនៅក្នុងអង្គភាពយកទ្រព្យសម្បត្តិ ឬគំរាមកំហែងទៅលើប្រជាជនឡើយ ព្រោះខុសនឹងវិន័យរបស់កងទ័ពខ្មែរក្រហម។ បន្ទាប់មក ខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅឈរជើងនៅគល់ស្ពានជ្រោយចង្វារវិញ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាប៉ូល។ កងកម្លាំងនៅក្នុងអង្គភាពរបស់ខ្ញុំចាប់ផ្តើមមានការអន់ចិត្ត ព្រោះខ្មែរក្រហមដាក់ផែនការឲ្យលើកទំនប់ និងជីកប្រឡាយ ប៉ុន្តែយើងមិនដែលហ៊ានប្រកែកតវ៉ា ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនអង្គភាពរបស់ខ្ញុំទៅកាន់ភ្នំដិន ក្នុងខេត្តតាកែវ ដើម្បីការពារព្រំដែន។ រយៈពេល១ឆ្នាំក្រោយមក យើងក៏ត្រូវបានផ្ទាក់លើបញ្ជូនទៅឈរជើងត្រើយខាងកើតទន្លេមេគង្គ ក្នុងខេត្តកំពង់ចាមវិញ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយដណ្តើមបានទីក្រុងភ្នំពេញ ចំណែកខ្ញុំនិងកងកម្លាំងមួយចំនួនដែលសេសសល់នៅក្នុងអង្គភាពបានធ្វើដំណើរទៅភ្នំដងរែក ដើម្បីប្រមូលផ្តុំកម្លាំងឡើងវិញ។ យើងបានចូលទៅក្នុងភូមិរបស់អ្នកស្រុកដើម្បីស្វែងរកស្បៀងអាហារ។ ខ្ញុំគឺជាកងទ័ព ដូច្នេះខ្ញុំមិនបានដឹងរឿងរ៉ាវរបស់ប្រជាជននៅសមរភូមិក្រោយជួបគ្រោះអត់ឃ្លានទេ។ ប៉ុន្តែទោះបីជាយ៉ាង ប្រជាជនមិនធ្វើបាបយើងដែរ។

រហូតដល់ឆ្នាំ១៩៨០ ខ្ញុំធ្វើដំណើរមកដល់ភ្នំដងរែក។ ខ្ញុំរស់នៅភូមិដូនអាវ ខាងលិចតំបន់មុំបី។ ខ្ញុំទទួលបានអាហារបំប៉នកម្លាំង និងស្បៀងសម្រាប់ហូប។ ក្រោយមក ខ្ញុំធ្វើបានដំណើរចូលទៅសមរភូមិខាងក្នុងប្រទេសជាញឹកញាប់ ដើម្បីបន្តទំនាក់ទំនងប្រជាជនឡើងវិញ និងវាយដណ្តើមតំបន់ដែលធ្លាប់គ្រប់គ្រងមកវិញ។ ប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់ផ្តើមទាក់ទង និងចូលរួមជាមួយចលនារបស់ខ្មែរក្រហមជាបន្តបន្ទាប់ ដែលមានទីតាំងនៅភាគខាងជើងជាប់ជួរភ្នំដងរែក។

## ៦) កែប រ៉េត ៖ ប្រជាជន



កែប រ៉េត អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កែប រ៉េត ភេទស្រី អាយុ៦២ឆ្នាំ មានស្រុកកំណើតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ។ សព្វថ្ងៃ កែប រ៉េត រស់នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ កែប រ៉េត បាននិយាយរៀបរាប់អំពីរឿងរ៉ាវតស៊ូរបស់គាត់នៅសម័យខ្មែរក្រហមថា ៖

កាលពីនៅតូច ពេលខ្ញុំកំពុងរៀនថ្នាក់ទី៣ពីសង្គមចាស់ ស្រាប់តែកើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំបានឈប់រៀនចាប់តាំងពីពេលនោះមក។ សមាជិកគ្រួសាររបស់ខ្ញុំសុទ្ធតែរៀនសូត្របានខ្ពស់ ដោយឪពុករបស់ខ្ញុំគឺជាគ្រូពេទ្យនៅសម័យសង្គមរាស្ត្រនិយម។ នៅដើមឆ្នាំ១៩៧៣ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ចោលដោយចោទប្រកាន់គាត់ថា ជាប់និន្នាការនយោបាយ។ ចំណែកខ្ញុំនិងម្ដាយត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិកំណើតឲ្យទៅរស់នៅសហករណ៍ក្នុងស្រុកសំបូរ។ កាលនោះខ្ញុំមានអាយុ១១ឆ្នាំ។ ខ្ញុំនិងម្ដាយត្រូវបានខ្មែរក្រហមជម្លៀសពីកន្លែងមួយទៅកន្លែងមួយទៀត។ រហូតដល់ដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានប្រកាសឲ្យប្រជាជនទៅរស់នៅក្នុងស្រុកកំណើតវិញ។ ខ្ញុំមិនបានត្រឡប់ទៅស្រុកជាមួយម្ដាយរបស់ខ្ញុំទេ ដោយសារតែខ្ញុំនៅវ័យក្មេង ចាញ់ការបោកបញ្ឆោតរបស់បងៗដែលរួមដំណើរជាមួយគ្នាប្រាប់ថា «ប្រសិនបើខ្ញុំត្រឡប់ទៅស្រុកកំណើតវិញ គឺខ្ញុំមិនបានទៅលេងនៅភ្នំឪរ៉ាល់ទេ»។ ខ្ញុំលុតជង្គង់ សុំម្ដាយខ្ញុំទៅតាមបងៗចូលព្រៃ ដោយសារតែខ្ញុំចង់ទៅលេងភ្នំឪរ៉ាល់។ ខ្ញុំជួបការលំបាកវេទនាខ្លាំងណាស់នៅក្នុងព្រៃ ហើយខ្ញុំមានការសោកស្ដាយជាខ្លាំងដែលបានសម្រេចចិត្តមកចោលម្ដាយ។ ប្រជាជនខ្លះដេកស្លាប់នៅលើដី ខ្លះទៀតអង្គុយស្លាប់ពេលឈប់សម្រាក ដោយសារតែគ្មានអាហារហូបចុក និង ទឹកផឹក។

បន្ទាប់ពីឃើញប្រជាជនស្លាប់ច្រើន កងទ័ពខ្មែរក្រហមដែលបានរួមដំណើរ សម្រេចចិត្តនាំប្រជាជនធ្វើដំណើរឆ្ពោះទៅភ្នំ១០០១ ក្នុងខេត្តព្រះវិហារ។ យើងធ្វើដំណើរអស់រយៈពេល១ខែទើបទៅដល់ភ្នំ១០០១។ ខ្ញុំរស់នៅភ្នំ១០០១រហូតដល់ឆ្នាំ១៩៨១ ទើបខ្ញុំរៀបការ។ បន្ទាប់ពីមានគ្រួសារហើយ ខ្ញុំត្រូវបានបញ្ជូនទៅជំរំភូណយ។ ខ្ញុំរស់នៅក្នុងជំរំភូណយ រហូតដល់ឆ្នាំ១៩៩៣ ទើបតាម៉ុកឲ្យខ្ញុំចុះពីលើភ្នំមករស់នៅខាងក្រោមវិញ។ ក្រោយមក ប្ដីរបស់ខ្ញុំត្រូវបានគេលួចបាញ់សម្លាប់នៅតាមផ្លូវធ្វើដំណើរ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានក្លាយជាស្ត្រីមេម៉ាយរហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃនេះ ខ្ញុំមានជីវភាពធូរធារជាងមុន និងជាមេភូមិផ្អាវ។

## ៧) សុន សំ ៖ អតីតឈ្លបនៅក្នុងរបបខ្មែរក្រហម



សុន សំ អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិអូរជីក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សុនសំ ភេទប្រុស អាយុ៦៧ឆ្នាំ មានស្រុកកំណើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ សព្វថ្ងៃ សុន សំ រស់នៅក្នុងភូមិអូរជីក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សុន សំ និយាយរៀបរាប់អំពីប្រវត្តិតស៊ូរបស់គាត់ដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមថា ៖

កាលពីកុមារ ខ្ញុំមិនរៀនសូត្រទេ ដោយសារគ្រួសារមានជីវភាពខ្វះខាត។ ឪពុកម្ដាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ។ នៅឆ្នាំ១៩៧២ ខ្ញុំចូលធ្វើជាឈ្លបនៅក្នុងភូមិកំណើតខ្ញុំ។ ក្រោយមក ខ្ញុំឡើងទៅជាឈ្លបឃុំ និងឈ្លបស្រុក។ កាលណោះការងារឈ្លបគឺទៅសែងអ្នករបួសពីសមរភូមិមុខ។ មួយកងឈ្លបរបស់ខ្ញុំមានសមាជិកចំនួន១០នាក់។ ខ្ញុំស្ម័គ្រចិត្តធ្វើជាឈ្លបរហូតដល់ឆ្នាំ១៩៧៣ ទើបខ្ញុំចូលធ្វើជាកងទ័ពវិញ។ ខ្ញុំត្រូវបញ្ជូនឲ្យទៅវាយនៅភូមិភាគ

ឧត្តរ។ កាលណោះខ្ញុំនៅក្រោមការគ្រប់គ្រងរបស់តាឡុត គឺជាមេវរសេនាតូចលេខ១៦៧។ ខ្ញុំរួមទាំងកម្លាំងកងទ័ពទាំងអស់ ប្រយុទ្ធនៅលើសមរភូមិក្នុងគោលដៅឆ្ពោះទៅទីក្រុងភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំរួមទាំងកងទ័ពខ្មែរក្រហមជាច្រើននាក់ទៀតវាយចូលដល់ក្រុងភ្នំពេញ។ បន្ទាប់ពីវាយចូលភ្នំពេញបានរយៈពេល ២ថ្ងៃ កម្លាំងនៅក្នុងអង្គភាពរបស់ខ្ញុំទៅឈរជើងនៅទួលគោក ដោយស្នាក់នៅផ្ទះរបស់ប្រជាជនបណ្ដោះអាសន្ន។ នៅពេលខ្ញុំចូលទៅដល់ទួលគោកដំបូង ខ្ញុំមិនឃើញមានប្រជាជនរស់នៅទេ គឺស្ងាត់ជ្រងំ។ បន្ទាប់មក កងទ័ពទាំងអស់ចាប់ផ្ដើមរៀបចំសាជាថ្មី ហើយអង្គភាពរបស់ខ្ញុំត្រូវបញ្ជូនឲ្យនៅការពារតាមព្រំដែនក្នុងខេត្តមណ្ឌលគិរី។ កាលណោះ អង្គភាពខ្ញុំរៀបចំឈរជើងនៅអូរដាក់ដាំ និងម្ដងទៀតកងទ័ពវៀតណាម។ ការងារដែលខ្ញុំធ្វើគឺដោតចម្រូង និងដើរយាមល្បាតតាមព្រំដែន។ ពេលដែលកងទ័ពខ្មែរក្រហមទៅឈរជើងដំបូងៗ កងទ័ពវៀតណាមតែងតែមកនិយាយសួរនាំ ប៉ុជដែកគ្នាលេង។

នៅឆ្នាំ១៩៧៧ កងទ័ពវៀតណាមចាប់ផ្ដើមវាយចូលមកទឹកដីខ្មែរ ដូច្នេះកងទ័ពខ្មែរក្រហមក៏វាយបកទៅវិញរហូតដល់វាយបែកបន្ទាយរបស់កងទ័ពវៀតណាម។ បន្ទាប់មកកងទ័ពដែលឈរជើងនៅអូរដាក់ដាំក៏ផ្លាស់មកនៅកោះរំយោល ដើម្បីងាយស្រួលក្នុងការទទួលស្បៀងអាហារ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់កោះរំយោល ធ្វើឲ្យកងទ័ពខ្មែរក្រហមរួមទាំងប្រជាជនដែលរស់នៅកោះរំយោលរត់បែកខ្ញែកគ្នាអស់។ ខ្ញុំ និងប្រជាជនបានរត់គេចខ្លួន ហើយនៅឆ្នាំ១៩៨៣ ទើបធ្វើដំណើរទៅដល់ភ្នំដងរែក។ ខ្ញុំរស់នៅភ្នំ១០០១និងមានប្រពន្ធ។ ខ្ញុំនៅកងពលវរសេនាធំ ៩៧ ដែលគ្រប់គ្រងដោយ តាអ៊ា។ បន្ទាប់មក ខ្ញុំនាំប្រពន្ធទៅរស់នៅក្នុងជំរំអូរត្រាវវិញ។ នៅឆ្នាំ១៩៩១ ខ្ញុំ និងប្រពន្ធរួមទាំងប្រជាជនបានមករស់នៅក្នុងភូមិអូរជីក ក្នុងស្រុកត្រពាំងប្រាសាទវិញ។ ខ្ញុំនៅក្នុងកងពល៩២០ គ្រប់គ្រងដោយ តាសាន។ ក្រោយមក តាសាន និងតាសារឿន ត្រូវបានតាម៉ុកចោទថាក្បត់ និងចាប់យកទៅសម្លាប់ចោល។ ប្រជាជនដែលរស់នៅក្នុងស្រុកត្រពាំងប្រាសាទក្រោមការគ្រប់របស់តាសាន និង តាសារឿន បានកោះប្រជុំសម្រេចចិត្តផ្ដាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ១៩៩៧។ កងកម្លាំងខ្មែរក្រហមនៅស្រុកត្រពាំងប្រាសាទចាប់ផ្ដើមទាក់ទងទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីសុំជំនួយជម្លៀសប្រជាជនចេញពីស្រុកត្រពាំងប្រាសាទ។ កងម្លាំងរបស់រដ្ឋាភិបាលបានមកដឹកប្រជាជនទាំងអស់ទៅនៅខាងប៉ៃតាប់ រហូតដល់កងទ័ពខ្មែរក្រហមព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ទើបខ្ញុំត្រឡប់មករស់នៅក្នុងភូមិអូរជីកនេះរហូតដល់បច្ចុប្បន្ន។



ផ្លូវទៅវត្តប្រោក ស្ថិតនៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមទឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទិសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

*សូមអរគុណ!*















# វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅខេត្តព្រៃវែង

*ផេង ពង្សរ៉ាស៊ី*



*សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀន ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

## សេចក្តីផ្តើម

មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែង បានអនុវត្តវេទិកាថ្នាក់រៀនលើកទី៧៧របស់ខ្លួន នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ជាមួយសិស្សានុសិស្សចំនួន៤៥នាក់(ស្រី៣៥នាក់ ស្មើនឹង៧៨%) មកពីវិទ្យាល័យច័ន្ទក្រឹស្នា ស្ថិតនៅឃុំប្រេស ស្រុកមេសាង ខេត្តព្រៃវែង តាមការស្នើសុំរបស់គណៈគ្រប់គ្រងវិទ្យាល័យនេះកាលពីខែមីនា ឆ្នាំ២០២២ កន្លងមក។ សិស្សានុសិស្សទាំងអស់ និងគ្រូដឹកនាំចំនួនបីនាក់ បានធ្វើដំណើរមកដល់ទីតាំងមជ្ឈមណ្ឌល ឯកសារកម្ពុជាខេត្តព្រៃវែង នៅវេលាម៉ោង៩ព្រឹក ហើយដំណើរការកម្មវិធីវេទិកាថ្នាក់រៀនបានចាប់ផ្តើមភ្លាមៗដែរ។ កម្មវិធីដែលបានរៀបចំទុកមុនរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែង ត្រូវបានអនុវត្ត ជាបន្តបន្ទាប់រហូតដល់ម៉ោង១៥:០០នាទីរសៀលថ្ងៃដដែល។


សិស្សានុសិស្សកំពុងបំពេញកម្រងសំណួរស្ទាបស្ទង់មតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


សៀវភៅកត់ត្រារបស់សិស្សដែលចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ប្រវត្តិសង្ខេបវិទ្យាល័យ ច័ន្ទក្រីស្នា

ប្រវត្តិវិទ្យាល័យ ច័ន្ទក្រីស្នា មិនត្រូវបានចងក្រងលម្អិតឡើយ។ តាមសំណេរដោយដៃចំនួន៣ទំព័រដែលត្រូវបានផ្តល់ឲ្យដោយគណៈគ្រប់គ្រងវិទ្យាល័យនេះ គឺបានរៀបរាប់ត្រួសៗពីទិសដៅទៅកាន់ទីតាំងវិទ្យាល័យ ការកកើតវិទ្យាល័យ ស្ថានភាពរបស់វិទ្យាល័យនាពេលថ្មីៗនេះ តម្រូវការរបស់វិទ្យាល័យ និងការចុះឈ្មោះចូលរៀនរបស់សិស្សសម្រាប់ឆ្នាំថ្មីៗកន្លងមកនេះ។ ក្រុមការងារបានសង្ខេបតែចំណុចទាក់ទងនឹងប្រវត្តិរបស់វិទ្យាល័យមកបញ្ជាក់ដូចតទៅ៖ នៅឆ្នាំ១៩៦៤ នាសម័យសង្គមរាស្ត្រនិយម វិទ្យាល័យនេះត្រូវបានសាងសង់ឡើង ដើម្បីផ្តល់នូវសេចក្តីត្រូវការរបស់អ្នកភូមិក្នុងការបញ្ជូនកូនៗរបស់ខ្លួនឲ្យចូលរៀន។ កាលនោះគឺជាសាលាបឋមសិក្សាច័ន្ទក្រីស្នា។ ប្រាំមួយឆ្នាំក្រោយមកគឺនៅឆ្នាំ១៩៧០ សាលានេះត្រូវបិទទ្វារដោយសារតែសង្គ្រាម។ ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ បរិវេណសាលាទាំងមូលត្រូវខ្មែរក្រហមប្រើប្រាស់ជាកន្លែងផលិតជីធម្មជាតិដាក់ស្រែ និងមន្ទីរពេទ្យប្រចាំឃុំច្រេស។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ សាលារៀននេះត្រូវបានបើកឲ្យដំណើរការឡើងវិញ ដោយមានឈ្មោះជាសាលាបឋមសិក្សាច័ន្ទក្រីស្នាដដែល។ នៅឆ្នាំ១៩៨៤ ក្រសួងអប់រំបានតម្លើងកម្រិតសិក្សាពីសាលាបឋមសិក្សា ទៅជាអនុវិទ្យាល័យ ហើយចាប់ពីឆ្នាំ២០០៥មក ទៅជាវិទ្យាល័យ ច័ន្ទក្រីស្នា។

## កាលវិភាគវេទិកាថ្នាក់រៀន

### ពេលព្រឹក

១) ណែនាំសិស្សានុសិស្សពីមូលហេតុនៃការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង និងតួនាទីរបស់មជ្ឈមណ្ឌលនេះ។

២) វាស់ស្ទង់ចំណេះដឹងសិស្សមុនពេលអនុវត្តវេទិកាថ្នាក់រៀនចាប់ផ្តើម។

៣) ណែនាំ និងពន្យល់សិស្សានុសិស្សពីពិព័រណ៍រូបថតដែលតាំងបង្ហាញនៅផ្នែកខាងក្នុង និងខាងក្រៅ ការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង។

៤) ណែនាំសិស្សានុសិស្សឲ្យស្វែងយល់ស៊ីជម្រៅពីបរិបទប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩។

## ពេលរសៀល

៥) តម្រង់ទិសសិស្សានុសិស្សឲ្យគិតគូរស៊ីជម្រៅពីវិធីសាស្ត្រទប់ស្កាត់អំពើឃោរឃៅក្នុងប្រទេសកម្ពុជា នាពេលអនាគត ដោយណែនាំអ្នកទាំងនោះឲ្យស្វែងយល់ពីៈ (ក) និយមន័យឧក្រិដ្ឋកម្មឃោរឃៅ។ (ខ) កត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានអំពើឃោរឃៅក្នុងពិភពលោក។ (គ) វិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ជាលក្ខណៈបុគ្គល គ្រួសារ សហគមន៍ និងជាតិ ដើម្បីជាគំនិតក្នុងការត្រិះរិះពិចារណាពីវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការ ទប់ស្កាត់អំពើប្រល័យពូជសាសន៍។

៦) សំណួរ និងចម្លើយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

៧) វាស់ស្ទង់ចំណេះដឹងសិស្សក្រោយពេលវេទិកាចប់។

៨) ចែកចាយសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

៩) ថតរូបអនុស្សាវរីយ៍ និងបិទកម្មវិធីវេទិកាថ្នាក់រៀន។

## សកម្មភាពវេទិកាថ្នាក់រៀន

ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង បានណែនាំសិស្សានុសិស្សទាំងអស់ពីការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តព្រៃវែង ព្រមទាំងបានបង្ហាញពីគោលបំណង តួនាទី និងការកិច្ចរបស់មជ្ឈមណ្ឌលនេះ ក្នុងការផ្សព្វផ្សាយពីឯកសារខ្មែរក្រហមទាំងអស់ដែលមានតម្កល់នៅក្នុងការិយាល័យនេះ និងប្រមូលចងក្រងឯកសារទាំងឡាយណាដែលទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ដូចជាការចងក្រងបទសម្ភាសរបស់អ្នករស់រានមានជីវិតពីរបបនេះ ដើម្បីការចងចាំ ការបង្រៀន និងការប្រើប្រាស់ជាមេរៀនបន្ថែមស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

បន្ទាប់មក សិស្សានុសិស្សទាំងអស់ ត្រូវបានស្នើសុំឲ្យបំពេញតារាងស្ទាបស្ទង់មតិមុនពេលអនុវត្តវេទិកាថ្នាក់រៀន ដើម្បីវាស់ស្ទង់ចំណេះដឹងពីមុនរបស់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ តារាងស្ទាបស្ទង់មតិមុនពេលធ្វើវេទិកាចំនួន៤៥ច្បាប់ ត្រូវបានចែកទៅកាន់សិស្សានុសិស្សទាំងអស់ដើម្បីបំពេញ។ តារាងស្ទាបស្ទង់មតិនេះ មាន១២សំណួរដែលត្រូវបានបែងចែកជាបីផ្នែកធំៗគឺៈ ផ្នែកចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ផ្នែកចំណេះដឹងអំពីនិយមន័យ និងកត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានអំពើឃោរឃៅក្នុងពិភពលោក និងផ្នែកចំណេះដឹងអំពីវិធីសាស្ត្រក្នុងការចូលរួមទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ សិស្សានុសិស្សទាំងអស់ មានពេលត្រឹមតែ១៥នាទីប៉ុណ្ណោះក្នុងការបំពេញសំណួរទាំង១២សំណួរនេះ។

សកម្មភាពបន្ទាប់ទៀត គឺជាការបង្ហាញពីពិព័រណ៍រូបថតខ្មែរក្រហម ដែលមាននៅខាងក្នុង និងខាងក្រៅបន្ទប់ការិយាល័យ។ សិស្សានុសិស្សត្រូវបានបង្ហាញពីរូបថតម្តងមួយផ្ទាំងៗ អមជាមួយនឹងការពន្យល់ពីផ្ទាំងរូបថតទាំងនោះផង។ ក្នុងពេលជាមួយគ្នានេះដែរ សិស្សានុសិស្សត្រូវបានលើកទឹកចិត្តឲ្យកត់ត្រានូវសំណួរផ្សេងៗដែលខ្លួនមាន នៅក្នុងសៀវភៅកំណត់ហេតុ ដើម្បីសួរក្នុងពេលវេលាដែលបានកំណត់នៅក្នុងកាលវិភាគ។ សិស្សអាចកត់ត្រានូវសំណួរដែលខ្លួនឆ្ងល់ជាយូរយារណាស់មកហើយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអាចជាឱកាសនៃការសួរសំណួរពិបាកៗដែលគ្រូរបស់ខ្លួនមិនទាន់រកចម្លើយឲ្យខ្លួនបាន។

កាលវិភាគបន្តបន្ទាប់ទៀត គឺការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហម។ គ្រូឧទ្ទេសបានចំណាយពេលវេលាប្រហែលពីម៉ោង សម្រាប់ការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ការធ្វើបទបង្ហាញ បានចាប់ផ្តើមពីការ

កកើតខ្មែរក្រហម និងបញ្ចប់ដោយការបង្ហាញពីផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើប្រជាជនទូទៅ និងប្រទេសជាតិ ជាពិសេសជំងឺបាក់ស្បាតដែលនៅតែបន្តកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនាពេលបច្ចុប្បន្ននេះ និងជីវិតតែលតោលរបស់ក្មេងកំព្រារាប់សែននាក់បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩។

នៅពេលរសៀលថ្ងៃដដែល គ្រូឧទ្ទេសបានពិភាក្សាពីសំណួរមួយចំនួនដែលសិស្សានុសិស្សបានសួរ។ បន្ទាប់មក គ្រូឧទ្ទេសបានចាប់ផ្ដើមការធ្វើបទបង្ហាញរបស់ខ្លួនបន្តទៀត ដោយផ្ដោតលើផ្នែកសំខាន់ពីរគឺ៖ ១) និយមន័យនៃអំពើឧក្រិដ្ឋឃោរឃៅ (រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) និងឧទាហរណ៍ជាក់លាក់មួយចំនួនដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មឃោរឃៅទាំងឡាយ។ ២) ការបង្ហាញពីវិធីសាស្ត្រជាក់លាក់ចំនួនពីរក្នុងការចូលរួមទប់ស្កាត់អំពើឃោរឃៅឬអំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារឬសហគមន៍ និងកម្រិតប្រទេសជាតិ។

សិស្សានុសិស្សទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យបំពេញតារាងស្ទាបស្ទង់មតិ (ក្រោយពេលធ្វើវេទិកា) ម្ដងទៀត ដើម្បីស្វែងយល់ពីចំណេះដឹងកើនឡើងក្រោយពេលដែលខ្លួនបានចូលរួមក្នុងសកម្មភាពវេទិកាថ្នាក់រៀនរយៈពេលបីម៉ោងរួចមក។ លើកនេះ សិស្សានុសិស្សបានចំណាយពេលវេលាច្រើនជាងកន្លះម៉ោងក្នុងការបំពេញតារាងស្ទាបស្ទង់មតិនេះ ព្រោះថា មានសំណួរមួយចំនួនទាមទារឲ្យសិស្សានុសិស្សសរសេររៀបរាប់ពីចំណេះដឹងដែលខ្លួនបានសិក្សាថ្មីៗពីក្នុងកម្មវិធីវេទិកាថ្នាក់រៀន ពីគំនិតយល់ឃើញនានារបស់ខ្លួនអំពីវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការចូលរួមទប់ស្កាត់អំពើហិង្សា និងពីគំនិតឆ្លុះបញ្ចាំងពីដំណោះស្រាយចំពោះការកើតឡើងនូវអំពើហិង្សានៅក្នុងសហគមន៍ ដែលខ្លួនគួរមាននិងដោះស្រាយក្នុងករណីដែលមានអំពើហិង្សាកើតឡើងមែន។

ចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀន សិស្សានុសិស្សទាំងអស់ទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ម្នាក់មួយច្បាប់ ដើម្បីទុកជាឯកសារស្រាវជ្រាវ និងរៀនសូត្របន្ថែមមុនពេលដែលខ្លួននឹងត្រូវចូលរួមប្រឡងប្រជែងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនាពេលប៉ុន្មានខែខាងមុខនេះ។

មុននឹងត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួនវិញ សិស្សានុសិស្សទាំងអស់បានឈរថតរូបជុំគ្នាជាមួយនឹងគ្រូឧទ្ទេស គ្រូដឹកនាំ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅពីមុខផ្ទាំងពិព័រណ៌ធំមួយស្ថិតនៅខាងក្នុងបរិវេណការិយាល័យមជ្ឈមណ្ឌលមណ្ឌលឯកសារខេត្តព្រៃវែង។

## លទ្ធផល

លទ្ធផលដែលទទួលបានពីការធ្វើវេទិកាថ្នាក់រៀន គឺត្រូវបានធ្វើឡើងតាមរយៈការបំពេញតារាងស្ទាបស្ទង់មតិ (ក្រោយពេលធ្វើវេទិកា) របស់សិស្សានុសិស្ស។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏លទ្ធផលនេះត្រូវបានវាស់ស្ទង់តាមរយៈចំណេះដឹងពីមុនរបស់សិស្សលើផ្នែកសំខាន់ៗចំនួនបីគឺ៖ មាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និយមន័យនិងកត្តាគ្រោះថ្នាក់ជាក់លាក់ដែលជាមូលហេតុបង្កបង្កើតឲ្យមានឧក្រិដ្ឋកម្មឃោរឃៅនានា និងវិធីសាស្ត្រសំខាន់ៗមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារឬសហគមន៍ និងប្រទេសជាតិ។ សំណួរដដែលទាំងនេះ ត្រូវបានសួរទៅកាន់សិស្សានុសិស្សម្ដងទៀតនៅក្រោយការបញ្ចប់វេទិកាថ្នាក់រៀន ដើម្បីវាស់ស្ទង់ថា តើកម្រិតនៃការយល់ដឹងរបស់សិស្សលើផ្នែកសំខាន់ៗទាំងបីខាងលើបានកើនឡើងកម្រិតណា។

តារាងខាងក្រោមនេះ គឺជាលទ្ធផលស្រង់ចេញពីតារាងស្ទាបស្ទង់មតិទាំងពីរ ដែលសិស្សបានបំពេញទាំងមុន និងក្រោយការធ្វើវេទិកាថ្នាក់រៀន។ រាល់ចម្លើយដែលជាប្រភេទចម្លើយជ្រើសរើសសម្រាប់ផ្នែក «និយមន័យ និងកត្តាគ្រោះថ្នាក់ជាក់លាក់នៃឧក្រិដ្ឋកម្មឃោរឃៅ» និង«វិធីសាស្ត្រសំខាន់ៗក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ហើយត្រូវ



សិស្សានុសិស្ស គ្រូដឹកនាំ និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានយកមកដាក់នៅក្នុងតារាងនេះ គឺជាចម្លើយជ្រើសរើសដែលត្រឹមត្រូវបំផុត។

## បញ្ហាប្រឈម

ដោយសារតម្រូវការរបស់គ្រូដឹកនាំសិស្សមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាថាឲ្យគ្រូខុទ្ទេសធ្វើបទបង្ហាញលើចំណុចច្រើន និងលម្អិតពីបរិបទប្រវត្តិសាស្ត្រខ្មែរក្រហម យើងបានចំណាយពេលវេលាយ៉ាងច្រើននៅវេលាព្រឹកនៃការធ្វើវេទិកាថ្នាក់រៀន។ សកម្មភាពនេះ បានធ្វើឲ្យសិស្សានុសិស្សមានអារម្មណ៍ថា ខ្វះហាក់ដូចជា ទទួលនូវចំណេះដឹងច្រើនពេក ដែលជាហេតុធ្វើឲ្យអ្នកទាំងនោះបាត់បង់ថាមពលនៅពេលរសៀលក្នុងការក្រេបជញ្ជក់ចំណេះដឹងអំពី និយមន័យ និងកត្តាគ្រោះថ្នាក់ជាក់លាក់នៃឧក្រិដ្ឋកម្មឃោរឃៅ។ សិស្សានុសិស្សមួយចំនួនបានបង្ហាញឲ្យឃើញពីភាពអស់កម្លាំងក្នុងពេលត្រងត្រាប់ស្តាប់គ្រូខុទ្ទេស។ ជាបទពិសោធន៍កម្មវិធីវេទិកាថ្នាក់រៀនដែលនឹងប្រារព្ធធ្វើនាពេលក្រោយៗទៀត គឺត្រូវកំណត់ត្រឹមតែរយៈពេលក្រោមពីរម៉ោងសម្រាប់ការធ្វើបទបង្ហាញទាំងអស់។



សិស្សផ្តល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង បន្ទាប់ពីវេទិកាថ្នាក់រៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សទទួលសៀវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ពីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង បន្ទាប់ពីវេទិកាថ្នាក់រៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ចូលរួមដោយសិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន បឹងកុក រៀបចំដោយ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម» ខេត្តកំពង់ចាម

*អេង ខណ្ឌីកា*



សិស្សានុសិស្សថ្នាក់ទី១២នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន បឹងកុក ទស្សនាពិព័រណ៍រូបថត នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ សិស្សានុសិស្សថ្នាក់ទី១២នៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន បឹងកុក ចំនួន២១នាក់ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលរៀបចំដោយ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម» ខេត្តកំពង់ចាម ដែលស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនជាលើកទី៣នេះ ដែលចាប់ផ្តើមនៅវេលាម៉ោង៩:០០នាទី និងបញ្ចប់នៅវេលាម៉ោង១១:០០ព្រឹក ដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ

កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សដែលកំពុងសិក្សានៅកម្រិតថ្នាក់វិទ្យាល័យ តាមរយៈ ការដាក់តាំងបង្ហាញពិព័រណ៍រូបថតអំពីរឿងរ៉ាវ និងសម្ភាររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការធ្វើបទបង្ហាញអំពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យដោយលោកគ្រូ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងកិច្ចពិភាក្សាទៅលើប្រវត្តិសាស្ត្រខ្មែរក្រហមរវាងសិស្សានុសិស្សចូលរួម និងវាគ្មិនៗ ក្នុងវេទិកាថ្នាក់រៀនដែលមានរយៈពេល ២ម៉ោងនេះ សិស្សានុសិស្សចូលរួមបានដើរទស្សនាពិព័រណ៍យ៉ាងយកចិត្តទុកដាក់ ស្តាប់ការធ្វើបទបង្ហាញរបស់វាគ្មិនយ៉ាងស្ងៀមស្ងាត់ និងជជែកសួរដេញដោលៗ

បន្ទាប់មកសិស្សានុសិស្សដែលបានចូលក្នុងវេទិកាថ្នាក់រៀននេះបានចែករំលែកចំណេះដឹងដែលទទួលបាន និងទស្សនៈយល់ឃើញដូចខាងក្រោម ៖



រុំ អាម៉ី រៀនថ្នាក់ទី១១-B មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុកៗ
(ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

«ខ្ញុំឈ្មោះរុំអាម៉ីរៀនថ្នាក់ទី១១-Bមុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុកៗ នៅពេលដែលលោកគ្រូធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំនឹកដល់ជីដូនឈ្មោះ យេង ស៊្រុន អាយុប្រហែល៧០ឆ្នាំ ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហមៗ នៅក្នុងរបបខ្មែរក្រហមជីដូនរបស់ខ្ញុំរស់នៅភូមិទ្រាន ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ ជីដូនរបស់ខ្ញុំត្រូវបានដាក់ឲ្យធ្វើការគ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់ៗ គាត់ស្នាក់នៅកន្លែងធ្វើស្រែ និងការដ្ឋានលើកទំនប់ៗ ជីដូនរបស់ខ្ញុំតែងតែនិយាយប្រាប់ខ្ញុំអំពីទុក្ខលំបាកនៅពេលនោះៗ ខ្ញុំក៏អាណិតអាសូរប្រជាជនកម្ពុជាដែលបានរស់នៅក្នុងរបបខ្មែរក្រហម និងមិនចង់ឲ្យរបបនេះវិលត្រឡប់មកវិញទេៗ រឿងរ៉ាវទុក្ខលំបាករបស់ជនរងគ្រោះដែលបានស្លាប់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺស្ថិតនៅក្នុងការចងចាំរបស់ខ្ញុំ»ៗ



វ៉ា ស្រីកា រៀនថ្នាក់ទី១១-D មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុកៗ
(ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

«ខ្ញុំឈ្មោះ វ៉ា ស្រីកា រៀនថ្នាក់ទី១១-D មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុកៗ ខ្ញុំទទួលបានចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យៗ ខ្ញុំក៏មានជីដូនឈ្មោះ អ៊ុក ផល អាយុ៧០ឆ្នាំ ដែលជាអតីតពេទ្យខ្មែរក្រហម និងរស់រានមានជីវិតពីរបបខ្មែរក្រហមៗ ជីដូនរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំអំពីជីវិតជាពេទ្យខ្មែរក្រហម ដែលមានការងារមិនសូវលំបាក និងហូបចុកគ្រប់គ្រាន់ ខណៈពេលដែលប្រជាជនផ្សេងទៀតរងទុក្ខវេទនា និងស្លាប់ដោយការអត់ឃ្លានៗ បន្ទាប់ពីបានស្តាប់ការពន្យល់របស់លោកគ្រូអំពីទុក្ខវេទនា និងការស្លាប់របស់ប្រជាជន ព្រមទាំងការនិយាយប្រាប់រឿងរ៉ាវរបស់ជីដូន ខ្ញុំកាន់តែយល់អំពីការលំបាក និងការរស់នៅរបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម»ៗ

«ខ្ញុំឈ្មោះ ម៉ុង ស្រីនាង រៀនថ្នាក់ទី១១-D មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុក។ ខ្ញុំបានដឹងរឿងរ៉ាវជាច្រើនអំពីការជម្លៀសដោយបង្ខំ ទីតាំងសម្លាប់រង្គាល និងប្រវត្តិមេដឹកនាំខ្មែរក្រហម។ ខ្ញុំមានជីដូន និងជីតាដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំដឹងអំពីរឿងនេះតាមរយៈឪពុករបស់ខ្ញុំដែលជាក្មេងកំព្រា ចាប់តាំងពីពេលដែលខ្មែរក្រហមបានចាប់យកជីដូនជីតារបស់ខ្ញុំទៅសម្លាប់ចោល។ នៅក្នុងរបបខ្មែរក្រហម ឪពុករបស់ខ្ញុំរស់នៅភូមិក្រូចសើច ឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងបានរួចផុតពីសេចក្តីស្លាប់។ ការយល់ដឹងកាន់តែច្រើន និងការចងចាំអំពីជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិត ដូចជាឪពុករបស់ខ្ញុំដែលបានឆ្លងកាត់របបនេះ គឺពិតជាសំខាន់ដើម្បីកុំរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញទៀត»។



ម៉ុង ស្រីនាង រៀនថ្នាក់ទី១១-D មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យតេជោ ហ៊ុន សែន បឹងកុក។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សថ្នាក់ទី១២នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន បឹងកុក ចូលរួមវេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វាលពិឃាត (ត)
# សម្រែកមច្ចុរាជមេកងអង្គការលងអន្ទង

## ជីវិតផ្សេងក្នុងសុបិនចុងក្រោយ

ម្ដាយនិយាយមើលមុខឪពុកខ្ញុំ "យើងអស់សង្ឃឹមហើយ" ទាំងអួលដើមករំជួលអារម្មណ៍មានកែវភ្នែកក្រហមរងាល។

បន្ទាប់មកគាត់ក៏ឡើងទៅលើផ្ទះនិងនិយាយទៅកាន់តាយាយ ខ្ញុំថា "ពុកម៉ែ ថ្ងៃស្អែកកូននឹងលាពុកម៉ែទៅនៅទួលស្វាំងហើយ ខ្ញុំនឹងលាក់ទុកចិន្តាកូនស្រី និងអាវ៉ា ឲ្យនៅជាមួយពុកម៉ែ ហើយខ្ញុំនឹងយកអាវង្ស និងអាភ្លោះពីរនាក់ទៅជាមួយ សូមពុកម៉ែជួយមើលកូនខ្ញុំផង។"

ពាក្យសម្ដីលាយឡំទឹកភ្នែកយ៉ាងក្ដុកក្ដួល ស្រណោះសោកាបានប្រហារបំបែកដួងចិត្តគ្រួសារឲ្យប្រេះស្រាំ។ ជីវិតប្រៀបដូចនឹងថ្ងៃជិតលិច ហើយក្តិចទងប្រមាត់ឲ្យអួលណែនទ្រូងក្នុងឆាកជីវិតពោរពេញដោយសោកនាដកម្ម។

យប់នោះខ្ញុំសង្កេតឃើញលោកឪពុកអ្នកម្ដាយសម្រាន្តលើភក់ជ្រាំទឹកភ្នែកទុក្ខព្រួយមើលមកកូនៗកំពុងគេងលង់លក់រហង់ ចង់បញ្ចេញបណ្ដូលចិត្តភក្ដីភាពមនោសញ្ចេតនារវាងកូននិងពុកម៉ែ ចំណែកតាយាយក៏ដូច្នោះដែរ ភ្នែកទាំងគូសម្លឹងរបុះរបេះឡើងមើលទៅកូនគាត់ និងចៅៗនៅតូចៗមិនដឹងថាវាសនាចុងក្រោយទៅជាយ៉ាងណា?។

ដោយអស់សង្ឃឹមជីវិតកាន់តែរួមតូចទៅៗ ម្ដាយខ្ញុំបានបញ្ចេញសម្ដីមកកាន់កូនស្រីទាំងយំខ្សឹកខ្សួលខ្សាវៗ ជាមួយដៃអង្អែលក្បាលកូនស្រីថា "កូនស្រីមាសម្ដាយ! ស្អែកម៉ែ និងពុកលាកូនទៅហើយ ម៉ែ និងពុកឯងមិនដឹងថារស់ឬស្លាប់ទេ ដូច្នេះកូនគេងលើកដៃផ្សងក្នុងសុបិនយប់នេះ លួអាក្រក់។"

ពេលចប់បងស្រីដើរទៅក្បែរជញ្ជាំងផ្ទះ អង្គុយបត់ជើងយកដៃសំពះទួលលើក្បាលតាមមាត់បន្ដួចនិយាយខ្សឹបៗថា "សូមវត្ថុស័ក្តិសិទ្ធទាំងឡាយក្នុងលោកជួយបង្ហាញខ្ញុំក្នុងផ្លូវសុបិនផង បើឪពុកម្ដាយខ្ញុំគ្មានគ្រោះថ្នាក់អ្វីទេ?" ពេលរួចគាត់ក៏ចូលទៅសម្រាន្តទាំងអស់គ្នាក្នុងស្បែរាត្រីខ្មៅងងឹតដែលមិនទាន់យល់ពីអ្វីទាំងអស់។

នេះជាការគិតចុងក្រោយនៃចុងបញ្ចប់ជីវិត ពឹងទៅលើអាគមផ្សំអាយុ ព្រោះវាអាចជាការបង្ហាញផ្លូវជីវិតណាមួយ ធ្វើឲ្យរំសាយអារម្មណ៍តែប៉ុណ្ណោះ។

ពួថៅខ្មៅមច្ចុរាជសង្គម បានពុះច្រៀកជាចម្រៀកៗនៃផ្លូវជីវិតគ្រួសារឲ្យបែកខ្ញែកជាកង់ៗ ដែលមិនអាចផ្សំផ្គុំបានក្នុងឋានមនុស្សលោកយើងនេះដែលមិនធ្លាប់មាន។

---

## ពូឆាយ ទឹកចិត្តអ្នកជិតខាង

មួយសន្ទុះ ឪពុកគាត់បានចុះមកក្រោមផ្ទះរកកន្ត្រកផាងត្នោតដែលព្យួរនៅក្បែរជង្រុកស្រូវដើម្បីវេចខោអាវយកទៅទួលស្វាំងក្នុងទឹកមុខខ្សោះរីងរៃ។

មិនយូរប៉ុន្មាន ខ្ញុំឃើញស្រមោលមនុស្សស្គុងៗស្មៀកក្រមាអត់អាវស្បែកជើង... រុលរបងចូលមកក្នុងផ្ទះខ្ញុំ ក្នុងទឹកមុខភ័យខ្លាចមើលឆ្វេងស្ដាំ ហើយយកដៃខ្ទប់នឹងត្រចៀកពុកខ្ញុំថា "សូមបងកុំទៅទួលស្វាំងតាមគេបញ្ឆោអី គេនឹងសម្លាប់គ្រួសារបងនៅទីនោះជាមិនខាន សូមបងបង្ហួសទៅភូមិយោគទៅ។" ឪពុកខ្ញុំតប "អ្នកឆាយអើយ កូនខ្ញុំតូចៗច្រើន ពិបាកគេចណាស់ តាមតែយថាកម្មចុះ។" បន្ទាប់មកពូឆាយស្ទុះឱបពុកខ្ញុំ ហើយនិយាយទាំងអួលដើមក "សូមគ្រួសារបងសុខសប្បាយណា!" រួចគាត់ក៏ស្ទុះរុលរបងទៅវិញយ៉ាងលឿន។ ឪពុកខ្ញុំជូតទឹកភ្នែកលើកដៃរាពីក្រោយជាសម្ដីថា "អរគុណអ្នកឆាយហើយ"។

## កង់ប្រវត្តិសាស្ត្រអាក្រក់នៃអគ្គារបដិវត្តន៍

យប់មុនថ្ងៃគាត់ចេញទៅទួលស្លែង។ យប់នោះគាត់សម្រាន្តលើគំនរទុក្ខព្រួយ ត្រាំទឹកភ្នែកមិនរសាយ និងរសាប់រសល់មិនលក់។

ព្រលឹមអរុណ ព្រះអាទិត្យរះអើតលើមៗ ម្ដាយខ្ញុំងើបមើលកូនដេករដូករណែល ទឹកភ្នែកហូរស្ទើរខ្សោះខ្លួនចេញស្រោចពេញដៃនផ្កាល់ ទាំងព្រលឹមគ្មានភាពស្រស់ស្រាយ នឹកអាណិតកូនៗ ហើយបានស្ទុះដើរទៅរោងបាយកណ្ដាលភូមិ។ ដើរបណ្ដើរយកដាយក្រមាជូតទឹកភ្នែកទឹកសម្បោរបណ្ដើរ ស្ទើរផ្ដាច់វង្វេងនៃជីវិតសល់មិនបានមួយដង្ហើមមួសជង។

មួយស្របក់ក្រោយមកម្ដាយខ្ញុំចេញពីរោងបាយវិញបានជួបមីងហៀប នៅកណ្ដាលផ្លូវ។ មីងសួរទៅម្ដាយខ្ញុំថា "អ្នកបងបានជួបមេកងសយទេ?" ម្ដាយខ្ញុំតប "មិនបានជួបទេ ទៅពីរដងហើយ" ឥឡូវអង្គការបង្ខំឲ្យគ្រួសារបងទៅទួលស្លែងនៅពេលព្រឹកនេះជាដាច់ខាត។

---

## ចិញ្ចៀនគ្រាប់ល្មុត

ម្ដាយខ្ញុំផាកមើលឆ្វេងស្ដាំយកដៃកាន់ស្មាមីងហៀប ទាំងទឹកភ្នែកកំពុងហូរសស្រាក់ ជាមួយវាចាដាច់ៗថា៖

"អូន! ជួយមើលម្ដាយ និងកូនៗបងផង អម្បាញ់មិញបងមកជួបសមមិត្តលី ប្រធានគណៈមុខព្រួយរោងបាយកណ្ដាល ផ្ដាំផ្ញើគាត់ បើឃើញកូនខ្ញុំមករោងបាយ ជួយឲ្យបាយបបរវា ហូបផង ព្រោះខ្ញុំនឹងសុំអ្នកគ្រប់គ្រងទួលស្លែងទុកកូនឲ្យនៅជាមួយតាយាយនៅពេលខ្ញុំទៅដល់ទួលស្លែង។ ប៉ុន្តែ បើមិនឃើញខ្ញុំត្រឡប់មកវិញទេ ប្រាកដជាគេអនុញ្ញាតឲ្យកូនៗខ្ញុំរស់នៅក្នុងសហករណ៍ហើយ។ តែបើគេមិនព្រមទេ ខ្ញុំនឹងត្រឡប់មកយកកូនវិញជាមិនខាន។ បងបានទុកចិញ្ចៀនត្បូងគ្រាប់ល្មុតមួយវង់ឲ្យគាត់ជាសគុណ" (ពាក្យសម្ដីដែលម្ដាយខ្ញុំបានប្រាប់ទៅប្រធានគណៈមុខព្រួញរោងបាយជាគំនិតមួយដើម្បីកុំឲ្យគេធ្វើបាបកូនៗ ព្រោះគាត់ដឹងថាគេនឹងសម្លាប់គាត់នៅលើទួលស្លែងជាមិនខាន)។ បន្ទាប់មកម្ដាយខ្ញុំរលាស់ដៃចេញពីមីហៀប ដើរមកផ្ទះវិញពោរពេញដោយបណ្ដាំរាប់រយលានទុក្ខសោកក្រៀមក្រំក្នុងបេះដូង។

ពេលនោះមីងហៀប បានរត់មកប្រាប់ទាំងក្ដុកក្ដួលថា "អ៊ីចឹងហើយ អ្នកបងកុំយកកូនៗទៅជាមួយអីទុកព្រលែងវាដូចកូនមាន់កូនទាទៅ គេមិនចាំថាអ្នកណាជានរណាទេ ហើយដើរបង្អួសទៅភូមិយោតទៅ។" ឮការនិយាយរបស់មីងហៀប ម្ដាយខ្ញុំគ្មានមាត់កអ៊ីឡើយ គ្រាន់តែយកក្រមាជូតទឹកភ្នែក លេបទឹកមាត់ និងនិយាយតិចៗថា "អរគុណប្អូនច្រើនហើយ"។

មកដល់ផ្ទះកូនៗមិនទាន់ភ្ញាក់ពីដំណេក ម្ដាយនិងឪពុកចាប់ផ្ដើមរៀបចំអីវ៉ាន់ទៅទួលស្លែងក្នុងភាពអស់សង្ឃឹម ស្ងួតក្រៀមក្រំរីងរៃ។ ទាំងអស់គ្នាមានអារម្មណ៍ស្ទើរបែកធ្លាយដើមទ្រូង ហាយំលែងចេញ គ្មានព្រលឹងព្រលះក្នុងខ្លួន។

បងស្រីងើបមកអង្គុយបត់ជើងសំពះម្ដាយ។ ម្ដាយឃើញដូច្នោះសួរទៅកូនស្រីបណ្ដើររៀបចំអីវ៉ាន់បណ្ដើរជាមួយ ទឹកភ្នែកហូរសស្រាក់អណ្ដឹតអណ្ដក៖

"តើកូនយល់សប្ដឃើញអ្វីខ្លះ?" បងស្រីតបថា៖

"ម៉ែ! កូនយល់សប្ដឃើញថាព្រលឹងរបស់កូនបានដើរចូលទៅក្នុងទួលស្លែងឃើញផ្ទះគំរូអង្គការបដិវត្តន៍ប្រក់ក្បឿង ហើយព្រះសង្ឃមួយអង្គគង់នៅក្រោមផ្ទះ។"

ឮដូច្នោះម្ដាយខ្ញុំមានទឹកមុខស្មើ ហើយស្ទុះមកលុតជង្គង់ឱបកូន ដោយអង្អែលក្បាលនិយាយថា "តើកូនឃើញអ្វីទៀតទេ?"

បងស្រីបន្ត៖ "បន្ទាប់មកខ្ញុំឃើញស្ត្រីម្នាក់ស្លៀកសារុងលេចគូទកណ្ដាលវាលនៅឈរពីលើផ្ទះចំព្រះសង្ឃ"។

ឮដូច្នោះម្ដាយខ្ញុំហូរទឹកភ្នែកប្រោកស្ទើរបោកប្រាណ ហើយទាញក្រមាមក

ដូតៗ ដៃគាត់នៅតែអង្អែលក្បាលកូនស្រីហើយពោលថា៖

"ម៉ែពុកនិងប្អូនៗឯងពិតជាត្រូវអស់អាយុជីវិតនៅលើលោកនេះ ហើយ។ មានអ្នកមានបុណ្យមកជួយដែរតែជួយមិនបាន"។

ម្តាយខ្ញុំយំឱបបងស្រី ទន់ខ្លួនដូចត្រូវគេសន្ធប់ដោយអស់រលីង អ៊ីៗមិនមានទៀតទេ។ បងស្រីយំឱបម្តាយហើយនិយាយ ទាំងដង្ហក់ថា ពេលម៉ែទៅដល់ទួលស្លាំង សូមម៉ែសុំគេមកវិញមកៗ ម្តាយខ្ញុំពេបមើលមុខកូនស្រីស្ទើរសន្ធប់ទាំងទឹកភ្នែក ហូរស្រណោះខ្លោចចិត្ត និងងក់ក្បាលជាសញ្ញា ក្នុងក្តីអាណិតកូនឥតឧបមាជាសម្រែក ហើយបានស្រែកឲ្យរបើកដួងចិត្តដែលបានកប់ងងឹត ឡូវដូច ភ្នំភ្លើងកំពុងផ្ទុះ។

ឱ! ព្រះជាម្ចាស់អើយ! តើខ្ញុំមានបាបកម្មអ្វី? បង្កើតរូបខ្ញុំមកហើយម្តេចឡើយឲ្យជួបតែរឿងឈឺចាប់ខ្លោចផ្សារកាប់សម្លាប់ព្រាត់ប្រាសនិរាសគ្រួសារដូច្នេះទៅវិញ។ ខ្ញុំអាណិតកូនៗខ្ញុំខ្លាំងណាស់ បើអត់ពីខ្ញុំទៅតើពួកគេរស់នៅរបៀបណា ដែលគ្នានៅតូចមិនទាន់ដឹងអ្វីៗទាំងអស់ សូមព្រះលោកជួយខ្ញុំផង។

ការទួញសោកស្រក់ទឹកភ្នែករាប់លានតំណក់ស្ទើរសន្ធប់នៃសម្រែកការឈឺចាប់នេះ គ្មានអ្នកណាអាចវាស់ស្ទង់ដឹងពីជម្រៅចិត្តម្តាយចំពោះកូនៗឡើយ។ ឱ! កម្មាភិបាលខ្មែរក្រហមអើយតើអ្នកបានពិចារណាល្អិតល្អន់ ហើយឬនៅ មុននឹងអូសក្បាលឪពុកម្តាយយកទៅសម្លាប់ចោល ទុកឲ្យកូនតូចៗនៅកំព្រាគ្មានស្តាយស្រណោះ។ ឱ! កូនតូចៗមាសម្តាយ ទាំងអស់គ្នា សូមកូនរស់នៅឲ្យបានសុខណា។

ភ្លើងមច្ចុរាជកំពុងតែដុតកម្លោចដួងចិត្តគាត់ដែលសល់បន្តិចបន្តួចឲ្យអស់រលីង ហើយសល់តែទឹកភ្នែកឈាមដិតជាមស្រពាំងក្នុងកែវភ្នែកមើលកូនៗទាំងអស់នៅជុំវិញខ្លួនយ៉ាងរហង់ **នៃរសជាតិខ្សែជីវិតចុងក្រោយដែលល្ងឹងជូរចត់ងងឹតសូន្យសុងក្នុងគ្រួសារ ហើយចង់ស្រែកឲ្យបែកផែនដី។ ទោះជាខំប្រឹងរើបម្រះប៉ុនណាក៏មិនអាចឆ្លងផុតពីរង្វង់កង់ប្រវត្តិសាស្ត្រអាក្រក់របស់អង្គការបដិវត្តន៍ដ៏កាចសាហាវមួយនេះបានឡើយ។**

ទីបំផុតគាត់ក៏សម្រេចចិត្តទៅតាមយថាកម្មនៃការបញ្ជាដាច់ខាតរបស់កម្មាភិបាលមេកងសយ ដែលអនុគណៈមុខព្រួញរោងបាយឈ្មោះ ហាត និងវ៉ាន់មកបណ្តើរពីផ្ទះយកទៅ។ សង្ឃឹមថាគ្រួសារយើងគេមិនសម្លាប់ចុះ! ។ នេះជាសម្តីឪពុក ប្រាប់ដល់ម្តាយខ្ញុំ។ ទោះជាខ្ញុំបានឃើញគេដឹករណ្តៅទុកជាសម្លាប់គ្រួសារស្រេចហើយរៀបរាប់ប្រាប់និងទាញដៃគាត់មិនឲ្យទៅយ៉ាងណាក៏ដោយ។

ខ្ញុំត្រូវតែបន្ទោសដល់ព្រហ្មលិខិតដ៏កាចហាវពិសពុលនៃសង្គមកខ្វក់អប្រិយ អន្តរាយដែលបានគួចយកព្រលឹងឪពុកម្តាយ និងប្អូនភ្លោះហើយបានរុញច្រានគ្រួសារខ្ញុំឲ្យខ្ចាត់ខ្ចាយដួលរលំរលត់រស្មីជីវិត។ រស់ជាតិមួយលានល្វីងជូរចត់ក្លាយជាបទចម្រៀងអវសានជីវិតគ្រួសារច្រៀងទួញបំពេជាសអារម្មណ៍កូនៗ លុះលង់ជីវិតបង់លើលោកកិយនេះ ៕

# ៦. អាពាហ៍ពិពាហ៍ក្រោមដំបូលមេបាបដិវត្តន៍

## ចំណងដៃទឹកភ្នែកចំពោះកូនស្រី

### សំឡេងយំបងភ្លេងបាយខុនចងដៃ

ធម្មជាតិបានបង្កើតឲ្យមានយប់មានថ្ងៃ មានរដូវវស្សា ប្រាំង និងរំហើយ ហើយក៏មានខ្មៅតនិងរនោចដែរ។ សម្រាប់គ្រប់ជីវិតដែលរស់នៅក្នុងរបបអាវខ្មៅខ្មែរក្រហមនេះវិញគឺគ្មានប្រាំង គ្មានវស្សា គ្មានខ្មៅតអីទេ គឺមានតែរនោចខែវស្សាភ្លៀងផ្គរងងឹតស្លុបទាំងយប់ថ្ងៃ។ មានន័យថាគឺគ្មានសេរីភាព គ្មានសិទ្ធិអ្វីទាំងអស់និងរង់ចាំតែគេបោះទម្រកាន់ហើយយកទៅសម្លាប់ចោលតែប៉ុណ្ណោះ។

សម្រាប់ជីវិតកូនកំព្រាទាំងបីនាក់ក្រោយពីលោកឪពុកអ្នកម្តាយនិងប្អូនៗត្រូវបានអង្គការយកទៅសម្លាប់ចោលបានតស៊ូរស់នៅទាំងលំបាកវេទនាត្រដាបត្រដួសជាមួយយាយតា ទាំងបិទមាត់ជិតដែលសម័យនោះគេច្រើននិយាយថាដាំដើមគ គឺមិនហ៊ាននិយាយមាត់ក

អ្វីទេ។ ដូចពាក្យស្លោកគេប្រើប្អូនវិចារណញ្ញាណ គឺ មិនឃើញ មិនដឹង មិនឮ មិននិយាយ។

ការងារនៅតែដដែលៗ ក្រៅពីខ្ញុំនិងប្អូនប្រុសរ៉ាទៅចាំគោ បងស្រីដាទៅធ្វើស្រែតាមបញ្ជាកម្មាភិបាលថ្នាក់លើតែប៉ុណ្ណោះ។

ថ្ងៃមួយពេលខ្ញុំទៅចាំគោនៅក្បែរទួលតាបញ្ញាពីរនាក់ប្អូនប្រុសរ៉ា មានកុមារមូលដ្ឋានបីបួនអ្នកដើរតាមភ្លឺស្រែក្បែរនោះ។ គេឃើញខ្ញុំ និងប្អូនប្រុស ស្រែកចំអកមកថា "នែសមមិត្តកុមារវង្ស និងរ៉ា អាអ្នក១៧មេសាហ្អែងអត់ទៅមើលបងស្រីចិន្តាឯងរៀបការនៅរោងបាយ ខាងកើតភូមិទេអី?"

ខ្ញុំស្រឡាំងកាំងងាកមើលមុខប្អូនប្រុសទៅវិញទៅមកហើយក៏នឹកឃើញពាក្យសម្តីម្តាយខ្ញុំនិយាយ លា និងផ្តាំផ្ញើជាមួយអ៊ំតែម ដែលជាជន្ទងគាត់មុនពេលគេយកម្តាយខ្ញុំទៅសម្លាប់។ គាត់ពោលទាំងទឹកភ្នែកថា អ្នកបងតែមគ្រួសារប្អូនត្រូវមេកងសយឲ្យទៅរស់នៅទួលស្វាំង តែបើសិនជាមិនឃើញខ្ញុំត្រលប់មកវិញទេនោះប្រាកដជាខ្ញុំត្រូវគេសម្លាប់នៅ ទីនោះហើយ ដូច្នេះសូមអ្នកបងរៀបចំផ្សំផ្គុំកូនប្រុសណាត និងកូនស្រីចិន្តាយើងចុះនៅពេលអង្គការបដិវត្តន៍ប្រមូលផ្តុំឲ្យរៀបការជាក្រុមនៅក្នុងភូមិហើយជួយមើលកូនៗ និងឪពុកម្តាយខ្ញុំផងខ្ញុំលាអ្នកបងតែមសិនហើយ។

និយាយរួចគាត់ស្ទុះឱបជន្ទងគាត់ដែលខ្ញុំហៅគាត់ថាអ៊ំៗ ម្តាយខ្ញុំក៏លាដៃចេញពីគាត់ជាមួយទឹកភ្នែកហូររហាមទាំងពីរនាក់។ អ៊ំតែមគាត់បន្លឺសំឡេងតាមក្រោយថា "សូមប្អូនឆេង និងប្អូនឡុងទៅឲ្យបានសេចក្តីសុខណា។ ប្អូនឆេង! កូនបងមីតុប កូនប្រសាមុយ និងចៅម្នាក់ត្រូវមេកងសយឲ្យទៅនៅទួលស្វាំងដែរ ដូច្នេះ ប្អូនជួយមើលវាផងៗ" ជាបណ្តាំឆ្លើយឆ្លងទុក្ខសោក។

ម្តាយខ្ញុំងាកមើលក្រោយសម្លឹងមើលទៅអ៊ំតែម ដោយយកក្រមាជូតទឹកភ្នែកយំអណ្តើតអណ្តក ទួញសោកអាឡោះអាល័យជាបទភ្លេងបាយខុនចងដៃជូនពរកូនមា សម្តាយក្នុងជំរំបដិវត្តន៍ នៃអាពាហ៍ពិពាហ៍គ្មានភ្លេងសម្រាប់កូនស្រីដំបូងក្នុងជីវិតរបស់គាត់។

ពិតជាព្រហ្មលិខិតកាចសាហាវជះមកលើខ្សែជីវិតគ្រួសារមួយនេះ ដែលផុសចេញពីទឹកចិត្តនូវពាក្យបណ្តាំរយពាន់ តែងតែផ្តាំផ្ញើដល់អ្នកស្គាល់ជិតដិតគ្នាជានិច្ច ឲ្យជួយមើលកូនៗ គាត់ពិតជាវង្វេងវង្វាន់ស្មារតីរកគិតអ្វីពុំយល់។

មេឃគង់មានភ្លៀង ថ្ងៃក៏គង់រះ តែរស្មីពន្លឺនៃជីវិតគ្រួសារខ្ញុំមិនដែលភ្លឺស្រឡះសោះឡើយ។



ទិដ្ឋភាពៈ រយពាន់បណ្តាំម្តាយខ្ញុំដែលផ្តាំជន្ទងគាត់ឲ្យរៀបការកូនចិន្តា និងកូនណាតនៅពេលអង្គការប្រមូលផ្តុំរៀបការជាក្រុម។

# អាថ៌កំបាំងក្រោយវាំងននជីវិត

## ជីវិតតោកយាក

ពេលនោះគ្មានអ្នកណាអាចវាស់ស្ទង់នូវទំហំទុក្ខរបស់អ្នកម្តាយខ្ញុំបានទេ ថាគាត់កំពុងតែឈឺចាប់ប៉ុនណា? សេចក្តីស្លាប់កំពុងតែឈានមកជិតគាត់បន្តិចម្តងៗ។ មិនខុសពីលោកពុកដែរ គាត់កំពុងតែឈឺចាប់ក្នុងចិត្តតែមិនអាចនិយាយចេញមកបាននូវការទូលភ្នំទុក្ខ គឺបានតែត្រឹមលួចយំក្នុងទ្រូងប៉ុណ្ណោះ។

រាប់លានទុក្ខសោកនៃភ្លើងកម្មឆាបឆួល បានអន្ទ្រើនបោកបក់មកលើអារម្មណ៍ផ្លូវចិត្តឪពុកម្តាយខ្ញុំ គ្មានពេលល្ហែ សូម្បីនាងបងជាចាខ្វែងឆក់កូន និងបាត់បង់កូនលង់ទឹក ទួញសោកបោកប្រាណទ្រហោយំ ចុះទម្រាំឪពុកម្តាយខ្ញុំត្រូវឃាតកឆក់យកជីវិតខ្លួន ប្តី កូន ព្រាត់ប្រាសនិរាសគ្រួសារ តើមានទំហំធំធេងប៉ុនណាទៅ?

ឆាកជីវិតចាក់ស្រែះដោយសោកនាដកម្មដែលត្រូវគិត និងដោះស្រាយស្មើរខ្សោះខ្យល់ គិតពីឪពុកម្តាយចាស់ជរា កូនៗនៅផ្ទះ ឯកូនវ៉ុឡបងប្រុសបង្អស់នៅកងចល័តសមរភូមិមុខរូបខ្លួន និងកូនក្មោះពៅដែលកំពុងឈរមាត់រណ្តៅ មរណៈមិនសល់ពេលមិនយូរប៉ុន្មាននោះ។ មិនខុសពីសត្វអកដែលហើរមកដល់សម្បុកបាត់កូនអស់ យំសោកសង្រេងបោកប្រាណ ហើយខំប្រឹងស្រែករកកូនព្ទុនូវសំឡេងអកៗគ្មានទីបញ្ចប់ មិនដឹងថា សត្វពស់ចង្រៃបានលេបកូនទាំងរស់អស់ហើយ។

ទីបំផុតសត្វអកអស់សង្ឃឹមបានសម្រេចចិត្តហើរទៅលើយ៉ាងខ្ពស់រួចទម្លាក់ខ្លួនមកដីវិញ ធ្វើអត្តឃាតបញ្ចប់ជីវិតដោយខ្លួនឯងដើម្បីបំបាត់ទុក្ខកង្វល់ទាំងឡាយពិតជាវេទនាណាស់ប្រៀបដូចសត្វអណ្តើកត្រូវភ្លើងព្រៃពិឃាដៗ តែទោះជាយ៉ាងណាក៏មិនអាចគេចផុតពីកណ្តាប់ដៃភ្លើងមច្ចុរាជឡើយ គឺជាជីវិតទឹកភ្នែកឈាម ដែលគ្របដណ្តប់មកលើគ្រួសារខ្ញុំក្នុងចិត្តពិតជាស្រវាស្រទេញមែន។

អាថ៌កំបាំងនៅពីក្រោយវាំងននជីវិត ពិតជាខ្មៅងងឹតខ្លាំងណាស់ ទុក្ខញាំញីពេញប្រាណ ដែលពិបាកឲ្យយើងឆ្លុះបញ្ចាំងពីដំណើរនៃខ្សែជីវិតក្រឡាប់ចាក់យ៉ាងណាបានឡើយ។ ក្នុងសង្គមបិសាចខ្មៅនោះ គឺរស់កំដរថ្ងៃស្លាប់ប៉ុណ្ណោះ។

អង្គការបដិវត្តន៍អ្នកយកឈ្នះលើជនជាតិខ្មែរ ស្លូតត្រង់ជាមោទនភាពនៃជ័យជម្នះរះលើគំនរទឹកភ្នែកនិងផេះផង់របស់ឈាមឯង។

មរតកចុកឈាម ឈឺចាប់អំណោយព្រហ្មលិខិតសង្គមទុច្ចរិតដល់គ្រួសារខ្ញុំ ឥតមេត្តា ទោះជាយើងស្មោះត្រង់នឹងបដិវត្តន៍ប៉ុនណាគឺគេថា យើងក្បត់ប៉ុណ្ណឹង។

(តនៅលេខក្រោយ)



កងចល័តកំពុងស្ទូងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖
ទីតាំងតម្កល់អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម នៅខេត្តបន្ទាយមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម ត្រូវបានអាជ្ញាធរគាស់ដើម្បីរក្សាទុក
បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 269, May 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.